សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច

Université Royale de Droit et des Sciences Economiques

Royal University of Law and Economics


# សារណាបញ្ចប់ការសិក្សា

# ការស៊ើបសួរចំពោះបទល្មើសរក្សាទុក ដឹកជញ្ជូន ឬជួញដូរដោយខុសច្បាប់នូវសារធាតុញៀន

ស្រាវជ្រាវពីថ្ងៃទី២៣ ខែមីនា ឆ្នាំ២០២២ ដល់ថ្ងៃទី២៣ ខែឧសភា ឆ្នាំ២០២២


ស្រាវជ្រាវដោយ

និស្សិតឈ្មោះ **ជុន ឈៀងលី**

ថ្នាក់បរិញ្ញាបត្រ **នីតិសាស្ត្រ**

ជំនាន់ទី២២

សាស្ត្រាចារ្យណែនាំ

កញ្ញា **ផៃ វិជ្ជតា**


ឆ្នាំចូលសិក្សា ២០១៨

ឆ្នាំសរសេរសារណា ២០២២

# **សេចក្តីថ្លែងអំណរគុណ**

ខ្ញុំបាទឈ្មោះ **ជុន ឈៀងលី** ជានិស្សិតថ្នាក់បរិញ្ញាបត្រនីតិសាស្ត្រ ជំនាន់ទី២២ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច។

## **សូមគោរពថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅបំផុតជូន**

លោកឪពុក **ចាន់ សៀន** និងអ្នកម្តាយ **ស៊ិន ចិន្តា** ដែលរូបលោកទាំងពីរជាអ្នកមានគុណបានផ្តល់កំណើត អប់រំទូន្មានកូនប្រកបដោយព្រហ្មវិហារធម៌ និងចិញ្ចឹមបីបាច់ថែរក្សា ផ្គត់ផ្គង់រូបកូន ព្រមទាំងឧបត្ថម្ភគ្រប់បែបយ៉ាងទាំងថវិកា សម្ភារៈ និងលះបង់គ្រប់បែបយ៉ាងដើម្បីឲ្យកូនបានបន្តការសិក្សាជំនាញនីតិសាស្ត្រលើបញ្ហានានាដែលទាក់ទងនឹងច្បាប់ ដែលធ្វើឲ្យខ្ញុំបាទក្លាយជាបុគ្គលម្នាក់មានចំណេះដឹង និងមានតម្លៃក្នុងសង្គម ជាងនេះទៅទៀត រូបលោកទាំងពីរបានលើកទឹកចិត្ត និងពុះពាររាល់គ្រប់ឧបសគ្គដើម្បីផ្តល់នូវឱកាសក្នុងការស្វែងរកចំណេះដឹង តាមរយៈការសិក្សាតាំងពីបឋមសិក្សា រហូតដល់បញ្ចប់ថ្នាក់បរិញ្ញាបត្រនីតិសាស្ត្រ នៅសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ចនេះផងដែរ។

**ឯកឧត្តម សាកលវិទ្យាធិការ សាកលវិទ្យាធិការរង ព្រឹទ្ធបុរស ព្រឹទ្ធបុរសរង សាស្ត្រាចារ្យ** និង**មន្ត្រី** ទាំងអស់ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ដែលបានបង្ហាត់បង្រៀន និងផ្ទេរនូវចំណេះដឹង ដល់ការសិក្សារបស់ខ្ញុំបាទ រហូតខ្ញុំបាទមានសមត្ថភាពព្រមទាំងចំណេះដឹងមកដល់សព្វថ្ងៃនេះ។

ជាពិសេស ខ្ញុំបាទសូមថ្លែងអំណរគុណយ៉ាងជ្រៀលជ្រៅជូនចំពោះ សាស្ត្រាចារ្យ **នៃ វិជ្ជា** ដែលជាសាស្ត្រាចារ្យណែនាំមានទេពកោសល្យ ហើយបានចំណាយពេលវេលាដ៏មានតម្លៃក្នុងការណែនាំ បង្ហាត់បង្រៀន ផ្តល់យោបល់ ពន្យល់ ព្រមទាំងបង្ហាញនូវវិធីសាស្ត្រក្នុងការសរសេរសារណានេះឡើង ដោយមានការជួយកែតម្រូវនូវចំណុចខ្វះខាតដែលមានក្នុងសារណា និងបានធ្វើឲ្យសារណានេះទទួលបានភាពល្អប្រសើរ និងសម្រេចជាស្ថាពរ។

ជាទីបញ្ចប់ ខ្ញុំបាទសូមបួងសួងដល់វត្ថុស័ក្តិសិទ្ធិទាំងអស់ដែលមានក្នុងលោក សូមប្រសិទ្ធិពរជ័យជូន **លោកឪពុក អ្នកម្តាយ ឯកឧត្តម លោកជំទាវ លោក លោកស្រី សាស្ត្រាចារ្យ មន្ត្រី** និង**មិត្តនិស្សិតទាំងអស់** ឲ្យជួបតែសេចក្តីសុខ សេចក្តីចម្រើន ព្រមទាំងជួបប្រទះនូវពុទ្ធពរទាំងបួនប្រការគឺ អាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ។

# អារម្ភកថា

ជាដំបូង ខ្ញុំបាទមានអារម្មណ៍ត្រេកអរណាស់ ដែលខ្ញុំបាទបានទទួលឱកាសក្នុងការសរសេរសារណាបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្រនីតិសាស្ត្រ ជំនាន់២២ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ក្រោមប្រធានបទ **ការស៊ើបសួចំពោះបទល្មើសរក្សាទុក ដឹកជញ្ជូន ឬជួញដូរដោយខុសច្បាប់នូវសារធាតុញៀន** ដែលជាបទល្មើសមួយកំពុងរីករាលដាល និងកើតមានឡើងយ៉ាង ច្រើនទូទាំងសកលលោក ក៏ដូចជាប្រទេសកម្ពុជាយើងផងដែរ ។ មិនត្រឹមតែប៉ុណ្ណោះ បទល្មើសនេះបានបង្កឲ្យមានផលប៉ះពាល់ និងព្យសនកម្មយ៉ាងធ្ងន់ធ្ងរដល់សង្គមបច្ចុប្បន្នរួមមាន សណ្តាប់ធ្នាប់សាធារណៈ និងសង្គម ដែលអាចបង្កឲ្យមានបទល្មើសជាច្រើនផ្សេងទៀតដូចជាអំពើលួច ហិង្សាដោយចេតនា ឃាតកម្ម និងបទល្មើសជាច្រើនទៀត ។ ដោយមានការមើលឃើញនូវផលប៉ះពាល់យ៉ាងធ្ងន់ធ្ងរដូចនេះហើយ ទើបខ្ញុំបាទបានធ្វើការជ្រើសរើស និងលើកយកប្រធានបទ **ការស៊ើបសួចំពោះបទល្មើសរក្សាទុក ដឹកជញ្ជូន ឬជួញដូរដោយខុសច្បាប់នូវសារធាតុញៀន** នៅក្នុងដំណាក់កាលនៃការស៊ើបសួររបស់ចៅក្រមស៊ើបសួរ យកមកធ្វើការសិក្សាស្រាវជ្រាវ និងធ្វើបទបង្ហាញការពារសម្រាប់បញ្ចប់ថ្នាក់បរិញ្ញាបត្រនីតិសាស្ត្រ ជំនាន់២២ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច របស់ខ្ញុំបាទ។

ម្យ៉ាងវិញទៀត គោលបំណងនៃការសិក្សាស្រាវជ្រាវប្រធានបទសារណានេះ និងបានចងក្រងឡើងទុកសម្រាប់ជាឯកសារដើម្បី ចូលរួមក្នុងការចែករំលែកនូវចំណេះដឹង ព្រមទាំងបង្ការ ទប់ស្កាត់ការរីករាលដាលនៃបទល្មើសគ្រឿងញៀនទូទាំងប្រទេសកម្ពុជាឲ្យកាន់តែប្រសើរឡើង ជៀសវាងឲ្យបាននូវឥទ្ធិពលអាក្រក់របស់គ្រឿងញៀន ដែលបង្កឲ្យមានភាពអសន្តិសុខក្នុងសង្គម និងប៉ះពាល់ដល់សណ្តាប់ធ្នាប់សាធារណៈ និងដើម្បីឲ្យសាធារណៈជនទាំងអស់ ក៏ដូចជាមិត្តនិស្សិតបានយល់ឲ្យកាន់តែច្បាស់ពីនីតិវិធីនៃការស៊ើបសួរចំពោះបទល្មើសគ្រឿងញៀន នៅដំណាក់កាលចៅក្រមស៊ើបសួរ ដែលជាដំណាក់កាលមួយនៅក្នុងរឿងព្រហ្មទណ្ឌ។

ខ្ញុំបាទសូមទទួលយកការរិះគន់ កែតម្រូវ ដើម្បីស្ថាបនាឲ្យបានកាន់តែប្រសើរពីសំណាក់លោក លោកស្រី សាស្ត្រាចារ្យ មិត្តនិស្សិត និងសាធារណៈជនទាំងអស់គ្រប់ពេលវេលា និងទទួលការគោរពរាប់អានអំពីខ្ញុំបាទ។

ជាទីបញ្ចប់ ខ្ញុំបាទសូមគោរពជូនពរដល់លោក លោកស្រី សាស្ត្រាចារ្យ មិត្តនិស្សិត និងសាធារណៈជនទាំងអស់ ឲ្យជួបតែពុទ្ធពរទាំងបួនប្រការគឺ អាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ។

# មាតិកា

**ទំព័រ**

**សេចក្តីផ្តើម** ...................................................... ១

**ជំពូកទី១**

**ការបើកការស៊ើបសួរ និងរក្សាទុកវត្ថុតាង**

**ផ្នែកទី១៖ ការបើកការស៊ើបសួរ** ...................................................... ៤

**កថាខណ្ឌទី១៖ ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ** ...................................................... ៦

**កថាខណ្ឌទី២៖ លក្ខខណ្ឌនៃការបើកការស៊ើបសួរ** ...................................................... ៧

**ផ្នែកទី២៖ ការរក្សាទុកវត្ថុតាង** ...................................................... ៩

**កថាខណ្ឌទី១៖ ការបិទស្លាកបោះត្រាលើវត្ថុតាង** ...................................................... ៩

**កថាខណ្ឌទី២៖ ការថែរក្សាវត្ថុតាង** ...................................................... ៩

**កថាខណ្ឌទី៣៖ ការបង្កក និងការឃាត់ទុកទ្រព្យសម្បត្តិ** ...................................................... ១០

**ជំពូកទី២**

**ការស៊ើបសួរ**

**ផ្នែកទី១៖ ការស៊ើបសួរ** ...................................................... ១១

**កថាខណ្ឌទី១៖ ការជូនដំណឹងអំពីការដាក់ឲ្យស្ថិតក្រោមការពិនិត្យ** ...................................................... ១១

**កថាខណ្ឌទី២៖ ការឃុំខ្លួនបណ្តោះអាសន្ន** ...................................................... ១៤

ក. ការឃុំខ្លួនជនត្រូវចោទដែលជានីតិជន ...................................................... ១៥

ខ. ការឃុំខ្លួនជនត្រូវចោទដែលជាអនីតិជន ...................................................... ១៦

**កថាខណ្ឌទី៣៖ ការមិនឃុំខ្លួនជនត្រូវចោទ** ...................................................... ១៦

ក. ការសម្រេចមិនឃុំខ្លួនជនត្រូវចោទ ...................................................... ១៧

ខ. ការដាក់ជនត្រូវចោទឲ្យស្ថិតនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ ...................................................... ១៧

**កថាខណ្ឌទី៤៖ ការសួរចម្លើយជនត្រូវចោទ** ...................................................... ១៩

**ផ្នែកទី២៖ ការពិសោធន៍ និងធ្វើកោសលវិច័យ** ...................................................... ២០

**កថាខណ្ឌទី១៖ ការធ្វើកោសលវិច័យ** ...................................................... ២០

ក. ដីកាចាត់តាំងអ្នកជំនាញ ...................................................... ២១

ខ. អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន ...................................................... ២២

គ. លទ្ធផលកោសលវិច័យ ...................................................... ២៣

ឃ. ចំណាត់ថ្នាក់គ្រឿងញៀន ........................................ ២៤
**កថាខណ្ឌទី២៖ ការប្រគល់វត្ថុឲ្យទៅម្ចាស់ដើមវិញ** ........................................ ២៥
ក. ការប្រគល់វត្ថុដែលចាប់យកឲ្យទៅម្ចាស់ដើមវិញ ........................................ ២៥
ខ. ការប្រគល់ និងបើកទីតាំងវិញ ........................................ ២៦
**កថាខណ្ឌទី៣៖ ការស្រាវជ្រាវ** ........................................ ២៦
ក. ការស៊ើបសួរដោយចៅក្រមស៊ើបសួរ ........................................ ២៧
ខ. ការចាត់ឲ្យស៊ើបសួរជំនួស ........................................ ២៧
**កថាខណ្ឌទី៤៖ វិធានការនិរន្តរាយ** ........................................ ២៨
ក. ដីកាបង្គាប់ឲ្យចូលខ្លួន ........................................ ២៩
ខ. ដីកាបង្គាប់ឲ្យនាំខ្លួន ........................................ ៣០
គ. ដីកាបង្គាប់ឲ្យចាប់ខ្លួន ........................................ ៣០
ឃ. ដីកាបង្គាប់ឲ្យឃុំខ្លួន ........................................ ៣២

**ជំពូកទី៣**

**ការបិទការស៊ើបសួរ**

**ផ្នែកទី១៖ ការបិទការស៊ើបសួរ** ........................................ ៣៤
**កថាខណ្ឌទី១៖ យោបល់របស់ព្រះរាជអាជ្ញា** ........................................ ៣៤
ក. ការស្នើសុំឲ្យបំពេញកិច្ចដោយព្រះរាជអាជ្ញា ........................................ ៣៤
ខ. ដីកាសន្និដ្ឋានស្ថាពរ ........................................ ៣៥
**កថាខណ្ឌទី២៖ ដីកាដំណោះស្រាយ** ........................................ ៣៦
ក. ការបញ្ជូនរឿងទៅជំនុំជម្រះ ........................................ ៣៧
ខ. ការសម្រេចលើកលែងចោទប្រកាន់ ........................................ ៣៨
**ផ្នែកទី២៖ សភាស៊ើបសួរ នៃសាលាឧទ្ធរណ៍** ........................................ ៣៩
**កថាខណ្ឌទី១៖ ការប្តឹងទៅសភាស៊ើបសួរចំពោះដីកាសម្រេច** ........................................ ៣៩
**កថាខណ្ឌទី២៖ ការប្តឹងសុំមោឃភាពនីតិវិធី** ........................................ ៤២
**សេចក្តីសន្និដ្ឋាន** ........................................ ៤៥
**អនុសាសន៍** ........................................ ៤៨
**ឯកសារយោង**
**បញ្ជីឧបសម្ព័ន្ធ**

# សេចក្តីផ្តើម

# សេចក្តីផ្តើម

នៅក្នុងបណ្តារប្រទេសមួយចំនួនធំលើសកលលោក កំពុងតែមានការផលិត ការចរាចរណ៍ ការជួញដូរ និងការប្រើប្រាស់គ្រឿងញៀនយ៉ាងច្រើន ក្នុងនោះក៏មានព្រះរាជាណាចក្រកម្ពុជាយើងផងដែរ ដែលទទួលបាននូវផលអាក្រក់ពីគ្រឿងញៀន ហើយប្រភេទសារធាតុញៀនមួយចំនួនត្រូវបានគេយកមកប្រើប្រាស់ដែលបម្រើផលប្រយោជន៍ផ្នែកវេជ្ជសាស្ត្រ តែសារធាតុញៀនមួយចំនួនទៀតត្រូវបានគេផលិតចែកចាយ ជួញដូរ និងប្រើប្រាស់ ដែលជះឥទ្ធិពលអាក្រក់ដល់សណ្តាប់ធ្នាប់សង្គមយ៉ាងធ្ងន់ធ្ងរ និងប៉ះពាល់ដល់ធនធានមនុស្សជាច្រើន ជាពិសេសដល់កុមារដែលជាអ្នកជំនាន់ក្រោយ ដែលជាទំពាំងស្នងឫស្សី ។ បើទោះជាមាត្រា៦០ នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាបានចែងថា *"ពលរដ្ឋមានសិទ្ធិលក់ដូរផលិតផលរបស់ខ្លួនដោយសេរី"* ក៏ដោយច្បាប់ចាត់ទុកថាការរក្សាទុក ការដឹកជញ្ជូន ឬការជួញដូរគ្រឿងញៀនជាអំពើខុសច្បាប់ដែលកំណត់ឲ្យមានការផ្តន្ទាទោសតាមច្បាប់ ដោយហេតុថាការចរាចរណ៍នេះជាអំពើខុសច្បាប់ដែលផ្តល់ផលអាក្រក់ដល់សង្គម រួមមានអំពើអសន្តិសុខដល់សង្គម ប៉ះពាល់សណ្តាប់ធ្នាប់សាធារណៈ និងបង្កឲ្យមានបទល្មើសផ្សេងៗទៀតបង្កឡើងដោយអ្នកញៀនថ្នាំ ជាងនេះទៅទៀតមាត្រា៦៤ នៃរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជាបានចែងថា *"រដ្ឋហាមឃាត់ និងផ្តន្ទាទោសជាទម្ងន់ដល់ជនណាដែលនាំចូល ផលិត លក់ដូរ គ្រឿងញៀន"* ក្នុងន័យនេះ រដ្ឋធម្មនុញ្ញដែលជាច្បាប់កំពូល និងជាច្បាប់គោលរបស់រដ្ឋ បានការពារនូវការចរាចរណ៍ ការផលិតគ្រឿងញៀន ហេតុនេះ ព្រះរាជាណាចក្រកម្ពុជាបានអនុម័តច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន នៅថ្ងៃទី២៥ ខែវិច្ឆិកា ឆ្នាំ២០១១ ដែលប្រកាសឲ្យប្រើប្រាស់ដោយព្រះរាជក្រមលេខ នស/រកម/០១១២/០០១ ចុះថ្ងៃទី០២ ខែមករា ឆ្នាំ២០១២ ដែលកំណត់អំពីស្ថាប័ន អាជ្ញាធរ មានសមត្ថកិច្ចមួយចំនួនដែលមានសមត្ថកិច្ចចំពោះបទល្មើសគ្រឿងញៀន ។ ដោយមើលឃើញនូវផលប៉ះពាល់ដ៏គ្រោះថ្នាក់ដល់សង្គមជាតិបែបនេះហើយ រាជរដ្ឋាភិបាលបានយកចិត្តទុកដាក់ក្នុងការបង្ការ ការការពារ និងទប់ស្កាត់រាល់សកម្មភាពទាំងឡាយណាដែលជាសកម្មភាពដែលជាអំពើខុសច្បាប់ក្នុងការបង្ក្រាបការដាំដុះ ការផលិត ការចរាចរណ៍ ការចាត់ចែង ការសម្រួលឲ្យប្រើប្រាស់ ការរក្សាទុក ដឹកជញ្ជូន ជួញដូរ និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន ដើម្បីទប់ស្កាត់រាល់បទល្មើសទាំងឡាយដែលពាក់ព័ន្ធជាមួយនឹងបទល្មើសគ្រឿងញៀន ។

នៅក្នុងនីតិវិធីព្រហ្មទណ្ឌរបស់តុលាការដែលមានដំណាក់កាលស៊ើបសួរ ជាដំណាក់កាលមួយក្នុងនីតិវិធីព្រហ្មទណ្ឌដោយចៅក្រមស៊ើបសួដែលមានសមត្ថកិច្ចស្វែងរកនូវការពិត ដោយរកឲ្យឃើញនូវភស្តុតាងដាក់បន្ទុក និងដោះបន្ទុកលើជនត្រូវចោទ មិនតែប៉ុណ្ណោះ នីតិវិធីនៃការស៊ើបសួរនេះពិតជាមានសារប្រយោជន៍យ៉ាងខ្លាំងសម្រាប់ការអនុវត្តលើបទល្មើសរក្សាទុក ដឹកជញ្ជូន និងជួញដូរដោយខុសច្បាប់នូវសារធាតុញៀននេះ ។ ការស៊ើបសួរត្រូវតែគោរពតាម និងអនុលោមតាមមាត្រា២៥២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ មិនដូច្នេះទេ ការស៊ើបសួរ

អាចត្រូវបាន ភាគីដែលទាក់ទិនក៏ដូចជាមេធាវីការពារសិទ្ធិឲ្យជនត្រូវចោទប្ដឹងមោឃភាព ចំពោះនីតិវិធីនៃការស៊ើបសួរនោះ ហើយការប្ដឹងមោឃភាពនេះសភាស៊ើបសួរ ដែលជាសភានៅមួយក្នុងតុលាការជាន់ខ្ពស់ជាអ្នកសម្រេច ។ ដោយការស៊ើបសួរត្រូវធ្វើឡើងជាសម្ងាត់ដោយពុំអាចបង្ហាញជាសាធារណៈ ឬប្រាប់គគ្នាបានទេ ដែលជាហេតុធ្វើឲ្យនីតិវិធីនៃការស៊ើបសួរមិនមានភាពល្អប្រសើរ និងពុំសូវមានប្រសិទ្ធិភាព ។ ការស៊ើបសួរចំពោះបទល្មើសគ្រឿងញៀនមានភាពចាំបាច់ណាស់ ប្រសិនបើបទល្មើសនេះមានបរិមាណសារធាតុញៀនច្រើន និងមានជនត្រូវចោទដែលបានគេចខ្លួន ដែលបានកំពុងរត់គេចខ្លួន មិនតែប៉ុណ្ណោះ ការរកឲ្យឃើញនូវសារធាតុសុទ្ធទៅលើសារធាតុដែលមានតម្រុយជាគ្រឿងញៀន គឺត្រូវចំណាយពេលដើម្បីធ្វើការពិសោធន៍ លើសពីនេះទៅទៀត ការធ្វើពិសោធន៍នេះគឺមានតែមន្ទីរពិសោធន៍ នៃអគ្គលេខាធិការអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀនប៉ុណ្ណោះ ដែលជាស្ថាប័នមានសមត្ថកិច្ចក្នុងការធ្វើកោសលវិច័យស្វែងរកជាតុសុទ្ធ នៃសារធាតុញៀននោះ ព្រមទាំងទទួលស្គាល់អ្នកជំនាញដោយរដ្ឋមន្ត្រីក្រសួងយុត្តិធម៌តាមរយៈសេចក្ដីសម្រេច ។ ការបញ្ជូនសំណាកគ្រឿងញៀនដែលយកមកធ្វើកោសលវិច័យនោះផងដែរ គឺមានលក្ខណៈពិបាកដោយសារត្រូវបានចំណាយពេលវេលាដោយសារចម្ងាយសម្រាប់ការដឹកជញ្ជូន មកមន្ទីរពិសោធន៍ នៃអគ្គលេខាធិការដ្ឋានអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀននោះ។

ដោយមើលឃើញនូវផលប៉ះពាល់ និងគ្រោះថ្នាក់ដ៏ធ្ងន់ធ្ងររបស់គ្រឿងញៀនមកលើសង្គមបែបនេះហើយ ទើបនីតិវិធីរបស់តុលាការ ក៏ដូចជាចៅក្រមស៊ើបសួរត្រូវសម្រេចសេចក្ដីឲ្យបានច្បាស់លាស់ និងត្រឹមត្រូវទៅតាមច្បាប់ដែលបានកំណត់ ហេតុដូច្នេះហើយ ទើបនៅក្នុងនីតិវិធីព្រហ្មទណ្ឌ មានការបើកការស៊ើបសួរចំពោះអង្គហេតុនៃបទល្មើសដែលពាក់ព័ន្ធជាមួយនឹងបទល្មើសគ្រឿងញៀនថា ៖

តើការបើកការស៊ើបសួរចំពោះបទល្មើសរក្សាទុក ដឹកជញ្ជូន ឬជួញដូរដោយខុសច្បាប់នូវសារធាតុញៀននោះមានសារសំខាន់ដែរ ឬទេ?

តើនីតិវិធីនៃការស៊ើបសួរចំពោះបទល្មើសរក្សាទុក ដឹកជញ្ជូន ឬជួញដូរដោយខុសច្បាប់នូវសារធាតុញៀននេះប្រព្រឹត្តទៅយ៉ាងដូចម្ដេច?

ការស្រាវជ្រាវចងក្រងជាឯកសារសារណានេះឡើង មានគោលបំណងបង្ហាញឲ្យឃើញនូវនីតិវិធីនៃការស៊ើបសួររបស់ចៅក្រមស៊ើបសួរ ដោយការស៊ើបសួរចំពោះបទល្មើសរក្សាទុក ដឹកជញ្ជូន ឬជួញដូរដោយខុសច្បាប់នូវសារធាតុញៀននេះ មានភាពប្រទាក់ក្រឡាទៅនឹងស្ថាប័នណាខ្លះដែលមានសមត្ថកិច្ច និងជាអ្នកធ្វើសកម្មភាពមួយចំនួនដែលចៅក្រមស៊ើបសួរប្រគល់ឲ្យ ។ ការស៊ើបសួរនេះផងដែរ ពិតជាមានសារប្រយោជន៍ណាស់សម្រាប់ជនត្រូវចោទក្នុងដំណាក់កាលនៃការស៊ើបសួរ បើទោះជាការស៊ើបសួរត្រូវការរយៈពេលមួយសម

ស្របដែលច្បាប់បានកំណត់ដើម្បីកឲ្យឃើញនូវការពិតក៏ដោយ ក៏រយៈពេលនៃការស៊ើបសួរនោះជនត្រូវចោទមានសិទ្ធិក្នុងការអនុវត្តនូវសិទ្ធិរបស់ខ្លួនមួយចំនួនដែលច្បាប់ផ្ដល់ឲ្យ។

វិសាលភាពនៃការសិក្សាស្រាវជ្រាវសារណានេះ គឺឆ្លុះបញ្ចាំងឲ្យឃើញត្រឹមតែការអនុវត្តចំពោះនីតិវិធី នៃការស៊ើបសួរចំពោះបទល្មើស រក្សាទុក ដឹកជញ្ជូន ឬជួញដូរដោយខុសច្បាប់នូវសារធាតុញៀន នៅក្នុងដែនដីនៃព្រះរាជាណាចក្រកម្ពុជា តែប៉ុណ្ណោះ ដែលជាសមត្ថកិច្ចរបស់ចៅក្រមស៊ើបសួរនៃសាលាដំបូងរាជធានី-ខេត្តទូទាំងប្រទេសកម្ពុជា។

ក្នុងការស្រាវជ្រាវ និងចងក្រងជាឯកសារសារណានេះ ខ្ញុំបាទបានធ្វើការស្រាវជ្រាវ និងដកស្រង់មាត្រាច្បាប់ដែលមានក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧ និងច្បាប់ស្ដីពីការត្រួតពិនិត្យគ្រឿងញៀន ឆ្នាំ២០១២ ដែលជាមូលដ្ឋានក្នុងការសរសេរ បន្ថែមពីនេះ ខ្ញុំបាទបានសិក្សាស្រាវជ្រាវលើលិខិតបទដ្ឋានគតិយុត្តជាតិ និងអន្តរជាតិ ព្រះរាជក្រឹត្យ អនុក្រឹត្យ ច្បាប់ និងឯកសារផ្សេងៗទៀត ។ ក្រៅពីបានសិក្សាដកស្រង់ចេញពីឯកសារលិខិតបទដ្ឋានគតិយុត្ត ខ្ញុំបាទបានសាកសួរសាស្ត្រាចារ្យដឹកនាំសារណា មន្ត្រីអនុវត្តច្បាប់ដែលមានបទពិសោធន៍ក្នុងការអនុវត្តផ្ទាល់ និងសាស្ត្រាចារ្យដែលបានបង្រៀនខ្ញុំបាទកន្លងមកផងដែរ មុននឹងឈានដល់ការសម្រេចបាននូវអត្ថបទសារណាមួយនេះឡើង។

ការចងក្រងជាឯកសារសារណានេះឡើងមកត្រូវបានបែងចែកជា៣ជំពូកធំៗ ដែលរួមមាន៖

**ជំពូកទី១៖ ការបើកការស៊ើបសួរ និងរក្សាទុកវត្ថុតាង**

**ជំពូកទី២៖ ការស៊ើបសួរ**

**ជំពូកទី៣៖ ការបិទការស៊ើបសួរ**

# ជំពូកទី១
# ការបើកការស៊ើបសួរ និងរក្សាទុកវត្ថុតាង

# ជំពូកទី១
# ការបើកការស៊ើបសួរ និងរក្សាទុកវត្ថុតាង

## ផ្នែកទី១៖ ការបើកការស៊ើបសួរ

ការបើកកាស៊ើបសួរជាជម្រើសនៃការចោទប្រកាន់មួយរបស់តំណាងអយ្យការ[1] ដែលត្រូវបានធ្វើឡើងដោយព្រះរាជអាជ្ញា ឬព្រះរាជអាជ្ញារង នៃអយ្យការអមសាលាដំបូងរាជធានី-ខេត្ត តាមរយៈដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ ទៅចៅក្រមស៊ើបសួរណាមួយ ។ ក្នុងករណីបទឧក្រិដ្ឋ ព្រះរាជអាជ្ញាត្រូវតែបើកការស៊ើបសួរចំពោះបទល្មើសរក្សាទុក ដឹកជញ្ជូន ឬជួញដូរដោយខុសច្បាប់នូវសារធាតុញៀន គេអាចសម្មតថាជាបទឧក្រិដ្ឋ ឬមជ្ឈិមទៅលើបរិមាណនៃគ្រឿងញៀន ។ តំណាងអយ្យការធ្វើការចោទប្រកាន់ដោយផ្អែកលើភស្តុតាងដាក់បន្ទុក និងឯកសារជាភស្តុតាងរបស់មន្ត្រីនគរបាលយុត្តិធម៌បានកសាង និងបញ្ជូនមកស្ថាប័នអយ្យការដើម្បីធ្វើការចោទប្រកាន់ ។ ជនគ្រប់រូបមានសិទ្ធិការពារខ្លួនតាមផ្លូវតុលាការ[2] ។ គ្រប់អនីតិជនមានអាយុក្រោម១៤ឆ្នាំ ដែលជាប់សង្ស័យថាបានប្រព្រឹត្តអំពើដែលជាបទល្មើស ពុំអាចត្រូវបានឃាត់ខ្លួនឡើយ ហើយមន្ត្រីនគរបាលយុត្តិធម៌ត្រូវប្រគល់អនីតិជននោះទៅអ្នកតំណាងដែលច្បាប់បានកំណត់ និងត្រូវបញ្ជូនសំណុំរឿងទៅព្រះរាជអាជ្ញា[3]។

អង្គការអយ្យការធ្វើការចោទប្រកាន់ពីបទល្មើសព្រហ្មទណ្ឌ និងសន្និដ្ឋានឲ្យតុលាការអនុវត្តច្បាប់[4] ។ អង្គការអយ្យការធានារ៉ាប់រងការអនុវត្តសេចក្តីសម្រេចខាងបទព្រហ្មទណ្ឌ។

បណ្តឹងអាជ្ញាត្រូវអនុវត្តក្នុងនាមផលប្រយោជន៍ទូទៅដោយអយ្យការ ។ អយ្យការធ្វើការចោទប្រកាន់បទល្មើសព្រហ្មទណ្ឌដែលពាក់ព័ន្ធជាមួយអនីតិជន[5] ។ ក្នុងករណីព្រះរាជអាជ្ញាពិនិត្យសំណុំរឿងឃើញថា អំពើប្រព្រឹត្តនោះមានសហចារី អ្នកផ្តើមគំនិត ឬអ្នកសមគំនិតជាអនីតិជនផង ព្រះរាជអាជ្ញាអាចសម្រេចចេញដីកាបំបែកសំណុំរឿងរវាងអនីតិជន និងនីតិជនឲ្យដាច់ដោយឡែកពីគ្នា[6]។

•ការកាន់កាប់ ការលាក់ទុក សន្និធិ[7] និងសកម្មភាពប្រហាក់ប្រហែលផ្សេងទៀតដោយខុសច្បាប់នូវសារធាតុញៀន គឺជាអំពើ **រក្សាទុកដោយខុសច្បាប់នូវសារធាតុញៀន**[8]។

---

[1] ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧, មាត្រា៤៤ និងមាត្រា១២៤

[2] រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ១៩៩៣, មាត្រា៣៨ កថាខណ្ឌ៧

[3] ច្បាប់ស្តីពីយុត្តិធម៌អនីតិជន ឆ្នាំ២០១៦, មាត្រា១៤

[4] ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧,មាត្រា២៧ កថាខណ្ឌ១

[5] ច្បាប់ស្តីពីយុត្តិធម៌អនីតិជន ឆ្នាំ២០១៦, មាត្រា២៤

[6] ច្បាប់ស្តីពីយុត្តិធម៌អនីតិជន ឆ្នាំ២០១៦, មាត្រា៣០

[7] វចនានុក្រមសម្តេចព្រះសង្ឃរាជជួន ណាត, សន្និធិ ជាការសន្សំទុក

[8] ច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ឆ្នាំ២០១១, មាត្រា៤០ កថាខណ្ឌ១

•ការបញ្ជូនតាមគ្រប់រូបភាពដែលនាំឲ្យមានការផ្លាស់ទី ពីទីកន្លែងមួយ ទៅទីកន្លែងមួយទៀត ពីមនុស្សម្នាក់ទៅមនុស្សម្នាក់ទៀត ឬពីប្រទេសមួយទៅប្រទេសមួយទៀតដោយខុសច្បាប់នូវសារធាតុញៀនជាអាទិ៍ តាមរយៈការផ្ញើ ការចរាចរ ការនាំចូល ឬការនាំចេញ គឺជាអំពើ **ដឹកជញ្ជូនដោយខុសច្បាប់នូវសារធាតុញៀន**[9]។

•ការផ្តល់សម្រាប់លក់ ការលក់ ការទិញដើម្បីលក់ ឬការដោះដូរដោយខុសច្បាប់នូវសារធាតុញៀនគឺជាអំពើ **ជួញដូរដោយខុសច្បាប់នូវសារធាតុញៀន**[10]។

តំណាងអយ្យការ អាចធ្វើការចោទប្រកាន់ទៅលើជនត្រូវចោទណាមួយបានដោយផ្អែកតាមប្រភេទ និងចំណាត់ថ្នាក់នៃគ្រឿងញៀន ដោយការសន្មតអំពីប្រភេទ និងចំណាត់ថ្នាក់នៃគ្រឿងញៀនដែលចាប់យកនោះដែរត្រូវបានកំណត់ដោយអ្នកជំនាញ ដែលជាគណៈកម្មការចូលរួមក្នុងការធ្វើតេស្តបឋម ឬការធ្វើតេស្តជំហានដំបូងដើម្បីស្វែងរកសារធាតុញៀន ។ តេស្តពណ៌ដែលមន្ត្រីនគរបាលយុត្តិធម៌ប្រើប្រាស់មានដូចជា[11]៖ ម៉ាគ្វីតេស្ត (Marquis), ស៊ីម៉ុនតេស្ត(Simon), ស្កុតតេស្ត(Scott Test), ហ្វាសប្លូ ប៊ូសាលី តេស្ត(Fast Blue Salt) និងចិនកាវ តេស្ត(Chenkao) ដែលឧបករណ៍តេស្តខាងលើនេះ អាចបង្ហាញអំពីលទ្ធផលជាបឋមសម្រាប់ជាតម្រុយអាចសន្មតអំពីប្រភេទនៃគ្រឿងញៀន ដោយមិនសូវមានភាពស្មុគស្មាញ និងប្រើប្រាស់ពេលវេលាឆាប់រហ័សក្នុងការធ្វើតេស្តលើសារធាតុដែលសង្ស័យជាសារធាតុញៀននោះ ។ ការធ្វើតេស្តបឋមនេះ ត្រូវបានធ្វើឡើងជាកំណត់ហេតុមួយ ដើម្បីជាមូលដ្ឋានក្នុងការចោទប្រកាន់របស់តំណាងអយ្យការ ដោយកំណត់ហេតុនោះបានបញ្ជាក់អំពីប្រភេទនៃសារធាតុញៀននោះ ហើយតំណាងអយ្យការសម្រេចធ្វើការចោទប្រកាន់ទៅតាមប្រភេទ និងចំណាត់ថ្នាក់នៃគ្រឿងញៀន ដែលមានកំណត់ក្នុងមាត្រា៥ មាត្រា៤០ និងមាត្រា៤៨ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ។ ប្រភេទនៃគ្រឿងញៀននីមួយៗ បានកំណត់ក្នុងតារាងឧបសម្ព័ន្ធថ្នាំញៀន និងសារធាតុញៀនមានឥទ្ធិពលលើប្រព័ន្ធប្រសាទ និងសារធាតុសម្រាប់ផលិតគ្រឿងញៀន នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ឆ្នាំ២០១១[12] ។

បច្ចុប្បន្នមន្ត្រីនគរបាលយុត្តិធម៌ ដែលគេឃើញមានក្នុងប្រតិបត្តិការបង្ក្រាបរាល់បទល្មើសពាក់ព័ន្ធជាមួយនឹងបទល្មើសគ្រឿងញៀនមានដូចជា៖ មន្ទីរប្រឆាំងបទល្មើសគ្រឿងញៀន នៃអគ្គស្នងការនគរបាលជាតិ, កងរាជអាវុធហត្ថលើផ្ទៃប្រទេស ដែលមានការិយាល័យប្រឆាំងគ្រឿងញៀននៅតាមបណ្តាកងរាជអាវុធហត្ថរាជធានី ខេត្ត, ស្នងការរាជធានី-ខេត្ត ដែលមានការិយាល័យប្រឆាំងគ្រឿងញៀន រួមទាំងអធិការនគរបាលក្រុង-ស្រុក-ខណ្ឌ

[9] ច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ឆ្នាំ២០១១, មាត្រា៤០ កថាខណ្ឌ២

[10] ច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ឆ្នាំ២០១១, មាត្រា៤០ កថាខណ្ឌ៣

[11] នាយឧត្តមសេនីយ មាស វីរិទ្ធ អគ្គលេខាធិការអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន "ការយល់ដឹងពីលក្ខណៈបច្ចេកទេសទាក់ទងនឹងបទល្មើសគ្រឿងញៀន" ទំព័រ៩

[12] តារាងឧបសម្ព័ន្ធមានចំនួន០៤តារាង ដែលបញ្ជាក់អំពីចំណាត់ថ្នាក់គ្រឿងញៀន

ដែលបានចុះបង្ក្រាប និងអនុវត្តវិធានការនានាដែលធានាឲ្យបាននូវការការពារ ការបង្ក្រាប ការបង្ការ និងចូលរួមទប់ស្កាត់យ៉ាងសកម្មលើបទល្មើសគ្រឿងញៀននេះ ។ ជាងនេះទៅទៀតក៏មានមន្ត្រីជំនាញមួយចំនួនទៀតដែលមានសមត្ថកិច្ចក្នុងការត្រួតពិនិត្យរាល់ការលួចដឹកជញ្ជូនដោយខុសច្បាប់នូវសារធាតុញៀន តាមរយៈជើងហោះហើរ ឬតាមរយៈការប្រើប្រាស់មធ្យោបាយដឹកជញ្ជូនផ្សេងៗ តាមច្រកព្រំដែន កំពង់ផែ ឬអាកាសយានដ្ឋានជាដើម។

**កថាខណ្ឌទី១៖ ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ**

ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួររបស់តំណាងអយ្យការ[13] ដែលប្តឹងទៅចៅក្រមស៊ើបសួរ ដោយការស៊ើបសួរអាចបើកប្រឆាំងលើបុគ្គលម្នាក់ ឬច្រើន ដោយមានការចង្អុលប្រាប់ឈ្មោះ ឬប្រឆាំងលើអញ្ញាតជន ដូចនេះរាល់ការបើកការស៊ើបសួរតំណាងអយ្យការអាចបើកប្រឆាំងលើបុគ្គលដែលមានអត្តសញ្ញាណ និងបុគ្គលដែលពុំមានអត្តសញ្ញាណ ប្រសិនបើយល់ថាមានប្រយោជន៍។

ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរត្រូវកំណត់ទម្រង់ដូចខាងក្រោម[14]៖

-**អង្គហេតុសង្ខេប** សំដៅលើការសង្ខេបអំពីអង្គហេតុ ឬព្រឹត្តិការណ៍ដែលបានកើតឡើងជាបទល្មើស[15]

-**កំណត់ឈ្មោះបទល្មើស** សំដៅលើការកំណត់ពីបទល្មើសដែលត្រូវបានចោទប្រកាន់លើជនត្រូវចោទ[16] ។

-**ការបង្ហាញពីអត្ថបទច្បាប់ដែលកំណត់ និងបង្ក្រាបបទល្មើស** សំដៅលើការកំណត់ពីមាត្រានៃបទល្មើសដែលមានចែងជាធរមាន[17]។

-**ឈ្មោះបុគ្គលដែលត្រូវបើកការស៊ើបសួរ ប្រសិនបើអាចកំណត់បាន** សំដៅដល់ការកំណត់អត្តសញ្ញាណរបស់ជនដែលត្រូវបានដាក់ឲ្យស្ថិតនៅក្រោមការពិនិត្យ ហើយប្រសិនបើមិនអាចកំណត់ឈ្មោះបានទេ តំណាងអយ្យការអាចចោទប្រកាន់ប្រឆាំងនឹងអញ្ញាតជនបាន[18]។

ចៅក្រមស៊ើបសួរមិនអាចបំពេញកិច្ចស៊ើបសួរដោយឯកឯងបានទេ ប្រសិនបើគ្មានដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួររបស់ព្រះរាជអាជ្ញា[19] ។ ក្នុងន័យនេះអាចកំណត់បានថារាល់ការស៊ើបសួររបស់ចៅក្រមស៊ើបសួរត្រូវតែស៊ើបសួរចំពោះការចង្អុលបង្ហាញ ដែលមានក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួររបស់តំណាងអយ្យការ

[13] ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ ដូចមានក្នុងឧបសម្ព័ន្ធទី១

[14] ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧, មាត្រា៤៤ កថាខណ្ឌ៣

[15] អង្គហេតុនេះ តំណាងអយ្យការអាចសង្ខេបអំពីសកម្មភាពប្រព្រឹត្តបទល្មើសដែលបានមកពីរបាយការណ៍របស់សមត្ថកិច្ចដែលមានក្នុងរបាយការសំយោគ, របាយការណ៍សរុប ឬរបាយការណ៍ដែលបញ្ជាក់អំពីសកម្មភាពនោះ។

[16] ឧទាហរណ៍ ជនត្រូវចោទត្រូវបានចោទប្រកាន់ពីបទ៖ ជួញដូរដោយខុសច្បាប់នូវសារធាតុញៀន។

[17] ឧទាហរណ៍ ច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន មាត្រា៤០ បទជួញដូរដោយខុសច្បាប់នូវសារធាតុញៀន។

[18] ក្នុងករណីជនល្មើសមិនត្រូវបានគេកំណត់ឈ្មោះជាក់លាក់ណាមួយទេ នោះតំណាងអយ្យការមានអំណាចក្នុងការចោទប្រកាន់ចំពោះអញ្ញត្តិជនដែលមានក្នុងអង្គហេតុនោះ។

[19] ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧, មាត្រា១២៤ កថាខណ្ឌ៣

តែប៉ុណ្ណោះ ។ ក្នុងករណីចៅក្រមស៊ើបសួររកឃើញនូវអង្គហេតុថ្មីដែលជាបទល្មើសព្រហ្មទណ្ឌនៅពេលស៊ើបសួរ ចៅក្រមស៊ើបសួរធ្វើការស៊ើបសួរអំពីអង្គហេតុថ្មីនេះ តាមដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរបន្ថែម បើគ្មានដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរបន្ថែមទេ ចៅក្រមស៊ើបសួរគ្មានអំណាចក្នុងការស៊ើបសួរអំពីអង្គហេតុថ្មីនោះឡើយ[20] ។ អង្គហេតុថ្មី ដែលមានលេចចេញពីបទល្មើសរក្សាទុក ដឹកជញ្ជូន ឬជួញដូរដោយខុសច្បាប់នូវសារធាតុញៀន អាចជាបទល្មើសសំអាតប្រាក់[21] ដែលការសម្អាតប្រាក់នេះគឺបានមកពីផលនៃបទល្មើសជួញដូរដោយខុសច្បាប់នូវសារធាតុញៀន ឬបទល្មើសផ្សេងៗទៀត ។ ប្រសិនបើគេរកឃើញថាបទល្មើសនេះមានលក្ខណៈ និងទ្រង់ទ្រាយធំ ហើយផលនៃបទល្មើសនេះមានច្រើន តំណាងអយ្យការអាចសម្រេចបំបែកសំណុំរឿងជាពីរ ដោយមួយជាបទល្មើសគ្រឿងញៀន ហើយសំណុំរឿងមួយទៀតជាបទល្មើសសម្អាតប្រាក់ ដើម្បីមានភាពងាយស្រួលក្នុងការស៊ើបសួរស្វែងរកនូវការពិត។

ចំពោះបទល្មើសរក្សាទុក ដឹកជញ្ជូន ឬជួញដូរដោយខុសច្បាប់នូវសារធាតុញៀន ដែលមានចែងក្នុងច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀនក្នុង**មាត្រា៤០** ចំពោះគ្រឿងញៀនដែលចាត់ថ្នាក់នៅក្នុង**តារាងទី១** និង**ទី២** ក្នុង**មាត្រា៥** នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។

ចំពោះបទល្មើសរក្សាទុក ដឹកជញ្ជូន ឬជួញដូរដោយខុសច្បាប់នូវសារធាតុញៀន ដែលមានចែងក្នុងច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀនក្នុង**មាត្រា៤៨** ចំពោះគ្រឿងញៀនដែលចាត់ថ្នាក់នៅក្នុង**តារាងទី៣** ក្នុង**មាត្រា៥** នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។

### កថាខណ្ឌទី២៖ លក្ខខណ្ឌនៃការបើកការស៊ើបសួរ

ការស៊ើបសួរត្រូវធ្វើដោយខានពុំបានចំពោះបទឧក្រិដ្ឋ ក្នុងករណីនេះព្រះរាជអាជ្ញាត្រូវមើលទៅលើបរិមាណ និងប្រភេទនៃគ្រឿងញៀន ប្រសិនបើគ្រឿងញៀនមានបរិមាណ និងប្រភេទអាចស្ថិតនៅក្នុងបទឧក្រិដ្ឋ ព្រះរាជអាជ្ញាត្រូវធ្វើការបើកការសើបសួរ ។ ចំពោះបទមជ្ឈិម ការស៊ើបសួរអាចធ្វើក៏បាន ឬមិនធ្វើក៏បាន[22] ។ ចំពោះបទល្មើសរក្សាទុក ដឹកជញ្ជូន ឬជួញដូរដោយខុសច្បាប់នូវសារធាតុញៀនជាបទល្មើសព្រហ្មទណ្ឌដែលមានចែងក្នុងច្បាប់ព្រហ្មទណ្ឌដោយឡែក ហើយការកំណត់ថាជាបទមជ្ឈិម ឬឧក្រិដ្ឋ មិនអាចមើលទៅលើបរិមាណនៃគ្រឿងញៀនទាំងមូលបានទេ ដោយមូលហេតុគ្រឿងញៀននីមួយៗមានប្រភេទខុសគ្នា ចំណែកការផ្តន្ទាទោសក៏មានលក្ខណៈខុសគ្នាទៅតាមប្រភេទនៃគ្រឿងញៀន ។ ម្យ៉ាងវិញទៀតការកំណត់បានថាជាបទមជ្ឈិម ឬឧក្រិដ្ឋ បានលុះត្រាតែគេអាចរកឃើញនូវសារធាតុសុទ្ធលើគ្រឿងញៀននោះ ធៀបទៅនឹងបរិមាណ នៃគ្រឿងញៀននោះ។

[20] ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧, មាត្រា១២៥

[21] ច្បាប់ស្តីពីការប្រឆាំងការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម ឆ្នាំ២០២០

[22] ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧, មាត្រា១២២

តំណាងអយ្យការទទួលសំណុំរឿងដែលកសាងដោយមន្ត្រីនគរបាលយុត្តិធម៌ ដូចនេះមុននឹងសម្រេចបើកការស៊ើបសួរ តំណាងអយ្យការអាចពិនិត្យលើប្រភេទ និងបរិមាណនៃគ្រឿងញៀន ដែលមិនទាន់រកឃើញនូវធាតុសុទ្ធ ហើយប្រសិនបើបរិមាណគ្រឿងញៀន និងប្រភេទនៃគ្រឿងញៀននោះ ស្ថិតនៅក្នុងបទមជ្ឈិម ឬមិនស្ថិតនៅក្នុងបទឧក្រិដ្ឋទេ តំណាងអយ្យការអាចសម្រេចបើកការស៊ើបសួរក៏បាន ឬមិនចាំបាច់ក៏បាន។

មនុស្សម្នាក់ៗ មានសិទ្ធិឲ្យទទួលស្គាល់ពីបុគ្គលិកលក្ខណៈគតិយុត្តរបស់ខ្លួននៅគ្រប់ទីកន្លែង[23] ដូចនេះរាល់ជនទាំងឡាយណាដែលសង្ស័យ ឬមានតម្រុយក្នុងការប្រព្រឹត្តបទល្មើសណាមួយនោះ ជននោះត្រូវបានច្បាប់ការពារសិទ្ធិ និងផលប្រយោជន៍ បើទោះជាជនបរទេស ឬជាជនជាតិណាមួយក៏ដោយ មិនតែប៉ុណ្ណោះ ក្នុងករណីដែលជនត្រូវចោទនោះត្រូវបានចោទប្រកាន់ ឬត្រូវបានឃុំខ្លួន នោះតំណាងអយ្យការ ឬចៅក្រមស៊ើបសួរត្រូវរាយការណ៍ជូនរដ្ឋមន្ត្រីក្រសួងយុត្តិធម៌ដើម្បីធ្វើសេចក្តីរាយការណ៍អំពីការឃុំខ្លួន និងការចោទប្រកាន់លើជននោះ ។ រដ្ឋមន្ត្រីក្រសួងយុត្តិធម៌រាយការណ៍ជូនស្ថានទូតរបស់ជនត្រូវចោទ ដើម្បីជារបាយការណ៍អំពីការចោទប្រកាន់ ឬឃុំខ្លួនលើជននោះ។

មនុស្សគ្រប់រូបមានសិទ្ធិស្មើគ្នាចំពោះមុខច្បាប់ និងមានសិទ្ធិទទួលបានការការពារពីច្បាប់ស្មើគ្នា ដោយគ្មានការរើសអើង មនុស្សគ្រប់រូបមានសិទ្ធិទទួលការការពារស្មើៗគ្នាប្រឆាំងនឹងការរើសអើងណា ដែលរំលោភលើសេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស ព្រមទាំងប្រឆាំងនឹងការញុះញង់ឲ្យមានការរើសអើង[24] លើសពីនេះទៅទៀតក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០១០ បានកំណត់ថាការញុះញង់ឲ្យមានការរើសអើងជាបទល្មើសព្រហ្មទណ្ឌ[25] ដែលកំណត់ថា "អំពើញុះញង់ដោយផ្ទាល់តាមមធ្យោបាយណាមួយ ដោយការប្រើប្រាស់សម្តី សំណេរ គំនូរ តាមការផ្សព្វផ្សាយជាសាធារណៈ ឬតាមគ្រប់មធ្យោបាយទូរគមនាគមន៍សោតទស្សន៍សម្រាប់សាធារណៈជន ឲ្យប្រព្រឹត្តការរើសអើង ការគុំគួន ឬហិង្សាចំពោះបុគ្គលណាមួយ ឬក្រុមណាមួយ ដែលមូលហេតុបុគ្គលនោះជាសមាជិក ឬមិនមែនជាសមាជិកនៃ**ជាតិពន្ធុ**[26] **ក្រុមជាតិ ពូជសាសន៍** ឬនៃ**សាសនា**ណាមួយជាកំណត់" ដូចនេះប្រសិនបើជនបរទេស ឬជនដែលមានពូជសាសន៍ ឬសាសនា ផ្សេងពីប្រជាជនកម្ពុជាយើងក៏ដោយច្បាប់ក៏បានការពារជនទាំងនោះឲ្យមានសិទ្ធិស្មើគ្នាចំពោះមុខច្បាប់ រួមទាំងផ្តន្ទាទោសលើជនណាដែលបង្កឲ្យមានការញុះញង់នោះតាមច្បាប់ផងដែរ ។

[23] សេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស អនុម័តដោយមហាសន្និបាតអង្គការសហប្រជាជាតិ ឆ្នាំ១៩៤៨, មាត្រា៦

[24] សេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស អនុម័តដោយមហាសន្និបាតអង្គការសហប្រជាជាតិ ឆ្នាំ១៩៤៨, មាត្រា៧

[25] ក្រមព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០១០, មាត្រា៤៩៦

[26] ជាតិពន្ធុ សំដៅលើអត្តសញ្ញាណរបស់ក្រុមមនុស្សដែលមានទំនាក់ទំនងនឹងគ្នា តាមរយៈវប្បធម៌ សាសនា ភាសា ប្រវត្តសាស្ត្រ និងទីតាំងភូមិសាស្ត្រ

## ផ្នែកទី២៖ ការរក្សាទុកវត្ថុតាង

វត្ថុតាងដែលត្រូវបានសង្ស័យជាគ្រឿងញៀនត្រូវរក្សាទុកក្នុងកញ្ចប់ ប្រអប់ ឬហឹប និងបិទស្លាកបោះត្រា នេះអាចកំណត់បានថារាល់វត្ថុតាងដែលមានតម្រុយជាគ្រឿងញៀន ត្រូវបានរក្សាទុកយ៉ាងល្អ ដោយត្រូវប្រាកដថា វត្ថុតាងនោះមិនត្រូវបានគេលួចដកហូតបានពីក្នុងកញ្ចប់ ប្រអប់ ឬហឹបដែលរក្សាវត្ថុតាងនោះ វត្ថុតាងជាភស្តុតាងដ៏សំខាន់មួយសម្រាប់រកឲ្យឃើញនូវការពិតចំពោះបទល្មើស រក្សាទុក ដឹកជញ្ជូន ឬជួញដូរដោយខុសច្បាប់នូវសារធាតុញៀន ។ ការប្រគល់វត្ថុតាងនេះមកតុលាការដើម្បីធ្វើការរក្សាទុក និងចាត់ការតាមនីតិវិធីច្បាប់ត្រូវមានកំណត់ហេតុប្រគល់ និងទទួលវត្ថុតាងនោះ ជៀសវាងមានការបាត់បង់ និងកំណត់អំពីអ្នកដែលមានសមត្ថកិច្ចក្នុងការថែរក្សាវត្ថុតាងនោះ[27]។

### កថាខណ្ឌទី១៖ ការបិទស្លាកបោះត្រាលើវត្ថុតាង

មន្ត្រីនគរបាលយុត្តិធម៌អាចចាប់យកវត្ថុតាង ។ មន្ត្រីនគរបាលយុត្តិធម៌ត្រូវបិទស្លាកបោះត្រាលើវត្ថុតាងនោះ[28] ។ នេះបង្ហាញឲ្យឃើញថារាល់វត្ថុតាងដែលត្រូវបានចាប់យកដោយមន្ត្រីនគរបាលយុត្តិធម៌ត្រូវបានបិទស្លាក និងបោះត្រាលើវត្ថុតាងដើម្បីធានាឲ្យបាននូវការរក្សាទុកដោយមិនអាចលួចដកហូតយកវត្ថុតាងនោះបាន។

ក្រោយពីបានបង្ហាញវត្ថុដែលចាប់បានដល់អ្នកកាន់កាប់ទីកន្លែង ឬសាក្សីពីរនាក់មើលរួច មន្ត្រីនគរបាលយុត្តិធម៌ ត្រូវធ្វើកំណត់ហេតុស្ដីពីការចាប់យកដែលរួមមានបញ្ជីសារពើភ័ណ្ឌ នៃវត្ថុដែលចាប់យកនោះ ។ កំណត់ហេតុស្ដីពីការចាប់យកត្រូវមានចុះហត្ថលេខា ឬផ្ដិតម្រាមដៃអ្នកដែលកាន់កាប់ទីកន្លែង ឬដោយសាក្សីពីរនាក់[29]។ ដូចនេះរាល់ការចាប់យកវត្ថុតាងដែលមិនមែនជាកម្មសិទ្ធិរបស់អ្នកកាន់កាប់ទីកន្លែងទេ មន្ត្រីនគរបាលយុត្តិធម៌ត្រូវឲ្យអ្នកកាន់កាប់ទីកន្លែង ឬសាក្សីពីរនាក់ដើម្បីចុះហត្ថលេខា ឬផ្ដិតស្នាមម្រាមដៃលើកំណត់ហេតុចាប់យកនោះ។

ក្នុងករណីការឆែកឆេរជាបទល្មើសមិនជាក់ស្ដែង មន្ត្រីនគរបាលយុត្តិធម៌ជាបឋមត្រូវទទួលបានការយល់ព្រមច្បាស់លាស់ និងពិតប្រាកដពីអ្នកកាន់កាប់ទីកន្លែង[30] ។ ការយល់ព្រមត្រូវធ្វើឡើងជាលាយលក្ខណអក្សរដោយសរសេរផ្ទាល់ដៃអ្នកកាន់កាប់ទីកន្លែង ក្នុងករណីដែលអ្នកកាន់កាប់ទីកន្លែងមិនចេះអក្សរនោះត្រូវសរសេរឲ្យបានច្បាស់ថាមិនចេះអក្សរ។

### កថាខណ្ឌទី២៖ ការថែរក្សាវត្ថុតាង

ក្រៅពីការចុះនិទ្ទេស កំណត់ហេតុត្រូវបន្ថែមនូវនិទ្ទេសដូចខាងក្រោម៖

[27] ដូចមានក្នុងឧបសម្ព័ន្ធទី២

[28] ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧, មាត្រា៩២ កថាខណ្ឌ១

[29] ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧, មាត្រា៩២ កថាខណ្ឌ២

[30] ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧, មាត្រា១១៣ កថាខណ្ឌ២

-ថ្ងៃ ខែ ឆ្នាំ និងទីកន្លែងរកឃើញ

-ប្រភេទ ទម្ងន់នៃវត្ថុដែលសង្ស័យថាជាគ្រឿងញៀន

-វិធីថ្លឹងដែលបានធ្វើ

-បញ្ជាក់ពីការធ្វើតេស្ត និងលទ្ធផលនៃការតេស្តនោះ ប្រសិនបើអាចធ្វើបាន[31]។

ការរក្សាទុកនូវកញ្ចប់ ប្រអប់ ឬហឹបដែលដាក់វត្ថុតាងនៅកន្លែងណាមួយ ការផ្លាស់ប្តូរទីកន្លែងនៃការរក្សាទុក ឬការប្រែប្រួលសភាពដើមនៃបញ្ចប់ ប្រអប់ ឬហឹបត្រូវធ្វើកំណត់ហេតុ[32] ។ ដូចនេះរាល់ការរក្សាទុកនូវវត្ថុតាងពិតជាមានសារសំខាន់ណាស់ក្នុងការធានាឲ្យបាននូវភាពយុត្តិធម៌ ត្រឹមត្រូវក្នុងការវិនិច្ឆ័យសេចក្តី និងធានាបាននូវការធ្វើកោសលវិច័យប្រកបដោយភាពត្រឹមត្រូវ និងច្បាស់លាស់។

**កថាខណ្ឌទី៣៖ ការបង្កក និងការឃាត់ទុកទ្រព្យសម្បត្តិ**

ក្នុងករណីដែលត្រូវបានគេរកឃើញថា ផលនៃបទល្មើសគ្រឿងញៀននេះបានក្លាយទៅជាទ្រព្យសម្បត្តិរបស់ជនត្រូវចោទ ឬជនណាមួយដែលកាន់កាប់លើទ្រព្យសម្បត្តិដែលជាផលនៃបទល្មើស នោះចៅក្រមស៊ើបសួរអាចចេញដីកាសម្រេចបង្កកទ្រព្យសម្បត្តិ ដែលបានមកពីផលនៃបទល្មើសនោះ ។ ដីកាសម្រេចនេះត្រូវចេញជាបន្ទាន់ក្នុងគោលបំណងហាមឃាត់ ការលក់ ការផ្តត់ផ្គង់ ភតិសន្យា ការផ្ទេរ កាបំប្លែង ការធ្វើមរតក ឬអនុប្បទានការចល័ត ឬការប្រើប្រាស់ចំពោះទ្រព្យសម្បត្តិទាំងនោះ រងចាំសេចក្តីសម្រេចពីតុលាការ ។ បើទោះជាការបង្កកទ្រព្យនេះមិនស្ថិតនៅច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀនក៏ដោយ ប្រសិនបើគេរកឃើញនូវទ្រព្យសម្បត្តិដែលកំណត់បានថាទាក់ទង ឬជាផលនៃបទល្មើសកំណត់ថាជាបទល្មើសសម្អាតប្រាក់ ហើយតុលាការអាចសម្រេចលើការបង្កក និងរឹបអូសចំពោះទ្រព្យសម្បត្តិដែលជាផលនៃបទល្មើសនោះបាន[33] ។

[31] ច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ឆ្នាំ២០១១, មាត្រា៨១ កថាខណ្ឌ៤

[32] ច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ឆ្នាំ២០១១, មាត្រា៨១ កថាខណ្ឌ៦

[33] ច្បាប់ស្តីពីការប្រឆាំងការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម ឆ្នាំ២០២០, មាត្រា៣១,មាត្រា៣២ និងមាត្រា៣៣

# ជំពូកទី២
# ការស៊ើបសួរ

# ជំពូកទី២

# ការស៊ើបសួរ

## ផ្នែកទី១៖ ការស៊ើបសួរ

ការស៊ើបសួរត្រូវតែជាការសម្ងាត់[34] ដើម្បីធានាដល់ការស៊ើបសួរឲ្យកាន់តែមានភាពប្រសើរ និងរក្សាទុកនូវភស្តុតាងដាក់បន្ទុក និងដោះបន្ទុកដែលបាននឹងកំពុងស្វែងរក ។ បុគ្គលទាំងឡាយដែលត្រូវបានចូលរួមក្នុងការស៊ើបសួរជាពិសេសចៅក្រម មេធាវី ក្រឡាបញ្ជី នគរបាល កងរាជអាវុធហត្ថ មន្ត្រីរាជការ អ្នកជំនាញ អ្នកបកប្រែភាសា គ្រូពេទ្យ និងបុគ្គលដែលមានសមត្ថកិច្ចក្នុងនីតិវិធី ត្រូវរក្សាការសម្ងាត់នៃវិជ្ជាជីវៈ[35] ក្នុងនោះបង្ហាញឲ្យឃើញថាការស៊ើបសួរត្រូវតែរក្សាការសម្ងាត់ផ្នែកវិជ្ជាជីវៈ ដោយមិនត្រូវបានយកមកបង្ហាញ មិនត្រូវប្រាប់ ឬត្រូវបានផ្តល់ព័ត៌មាន នេះទៅជនណាមួយឡើយដែលការបង្ហាញព័ត៌មាននេះអាចមានការប្រែប្រួលទៅលើភស្តុតាងជាឯកសារ ឬសាក្សីដែលធ្វើឲ្យការស៊ើបសួរនោះពុំមានភាពត្រឹមត្រូវ ។ ការមិនបានរក្សាការសម្ងាត់ក្នុងការស៊ើបសួរជាបទល្មើសព្រហ្មទណ្ឌ[36] ដែលកំណត់ថាបុគ្គលដែលកាន់កាប់ព័ត៌មានដែលមានលក្ខណៈអាថ៌កំបាំង ដោយមូលហេតុនៃស្ថានភាព មុខរបរ មុខងារ ឬបេសកកម្មរបស់ខ្លួន ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី**០១ខែ ដល់០១ឆ្នាំ** និងពិន័យជាប្រាក់ពី **១០០.០០០(មួយសែន)រៀល ដល់ ២.០០០.០០០ (ពីរលាន)រៀល** ប្រសិនបើបុគ្គលនោះបង្ហាញព័ត៌មាននេះដល់បុគ្គលដែលគ្មានសមត្ថកិច្ចដើម្បីដឹងព័ត៌មាននេះ ។ មិនមែនជាបទល្មើសទេ ក្នុងករណីដែលច្បាប់អនុញ្ញាត ឬតម្រូវឲ្យបង្ហាញអាថ៌កំបាំង ។ ដូចនេះចំណុចខាងលើបានចងនូវកាតព្វកិច្ចមួយសម្រាប់បុគ្គលដែលចូលរួមក្នុងការស៊ើបសួរដែលធ្វើដូចនេះដើម្បីធានាដល់ប្រសិទ្ធិភាពក្នុងការស៊ើបសួរ និងដើម្បីកុំឲ្យមានភាពមិនប្រក្រតីណាមួយក្នុងការស៊ើបសួររបស់ចៅក្រមស៊ើបសួរ។

ចៅក្រមស៊ើបសួរបានទទួលបណ្តឹងដែលប្តឹងសុំដាក់ជនត្រូវចោទឲ្យស្ថិតក្រោមការពិនិត្យពីបទ រក្សាទុក ដឹកជញ្ជូន ឬជួញដូរដោយខុសច្បាប់នូវសារធាតុញៀន តាមរយៈដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួររបស់តំណាងអយ្យការ ។

### កថាខណ្ឌទី១៖ ការជូនដំណឹងអំពីការដាក់ឲ្យស្ថិតក្រោមការពិនិត្យ

នៅពេលដែលចៅក្រមទទួលបានសំណុំរឿងស៊ើបសួរ ដែលបានប្តឹងសុំឲ្យដាក់ឲ្យស្ថិតក្រោមការពិនិត្យរបស់តំណាងអយ្យការ នៅពេលចូលបង្ហាញខ្លួនលើកដំបូង[37] ចៅក្រមស៊ើបសួរពិនិត្យអត្តសញ្ញាណជនត្រូវចោទ

[34] ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧, មាត្រា១២១ កថាខណ្ឌ១

[35] ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧, មាត្រា១២១ កថាខណ្ឌ២

[36] ក្រមព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០១០, មាត្រា៣១៤ បទ ប៉ះពាល់ដល់អាថ៌កំបាំងខាងវិជ្ជាជីវៈ

[37] កំណត់ហេតុស្តីពីការបង្ហាញខ្លួនលើកដំបូង ដូចមានក្នុងឧបសម្ព័ន្ធទី៣

ប្រាប់ជនត្រូវចោទឲ្យបានដឹងរឿងរ៉ាវដែលចោទប្រកាន់ និងប្រាប់អំពីឈ្មោះបទល្មើសដែលកំណត់ដោយច្បាប់ ។ ចៅក្រមស៊ើបសួរប្រាប់ជនត្រូវចោទថា ខ្លួនអាចឆ្លើយ ឬមិនព្រមឆ្លើយ ឬមិនឆ្លើយបានដោយសេរី និទ្ទេសស្តីពីការប្រាប់នេះត្រូវចុះនៅក្នុងកំណត់ហេតុនៅពេលចូលបង្ហាញខ្លួនលើកដំបូង[38] ។ ដូចនេះការចូលបង្ហាញខ្លួនលើកដំបូងនៅចំពោះមុខចៅក្រមស៊ើបសួរជនត្រូវចោទមានសិទ្ធិមួយចំនួនដូចខាងលើ ដែលចៅក្រមស៊ើបសួរមិនអាចរំលោភបំពានលើសិទ្ធិរបស់ជនត្រូវចោទបានឡើយ។

ចំពោះជនត្រូវចោទ ដែលជាអនីតិជនក្នុងដំណាក់កាលស៊ើបសួរ និងត្រូវជូនដំណឹងអំពីការដាក់ឲ្យស្ថិតនៅក្រោមការពិនិត្យ ដោយចៅក្រមស៊ើបសួរត្រូវផ្ទៀងផ្ទាត់ និងត្រួតពិនិត្យអត្តសញ្ញាណអនីតិជន ហើយប្រាប់អនីតិជននោះឲ្យដឹងអំពីរឿងរ៉ាវដែលចោទប្រកាន់ ព្រមទាំងឈ្មោះបទល្មើសដែលកំណត់នៅក្នុងច្បាប់[39] ព្រមទាំងប្រាប់ពីសិទ្ធិជាមូលដ្ឋានមួយចំនួនដូចខាងក្រោម[40]៖

១.សិទ្ធិមិនផ្តល់ចម្លើយក្នុងករណីមាន ឬគ្មានមេធាវី

២.សិទ្ធិមិនទទួលការបង្ខិតបង្ខំឲ្យឆ្លើយដាក់បន្ទុកលើខ្លួនឯង

៣.សិទ្ធិរក្សាការសម្ងាត់របស់នៃជីវិតឯកជន

៤.សិទ្ធិទទួលបានការពិនិត្យសុខភាព និងព្យាបាល

៥.សិទ្ធិទទួលបានការឲ្យដំណឹងអំពីបទចោទប្រកាន់

៦.សិទ្ធិក្នុងការជូនដំណឹងអំពីការចាប់ខ្លួនទៅដល់អ្នកតំណាងដែលច្បាប់បានកំណត់

៧.សិទ្ធិទទួលបានជំនួយពីមេធាវីដោយការជ្រើសរើស ឬដោយការចាត់តាំងដោយមិនយកកម្រៃ តាំងពីដំណាក់កាលដំបូងបំផុតនៃនីតិវិធី

៨.សិទ្ធិឲ្យមានការចូលរួមពីអ្នកតំណាងដែលច្បាប់បានកំណត់នៅគ្រប់ដំណើរការរឿងក្តី ប្រសិនបើការចូលរួមនេះមិនផ្ទុយនឹងឧត្តមប្រយោជន៍របស់អនីតិជន

៩.សិទ្ធិទទួលបានជំនួយពីអ្នកបកប្រែភាសាដោយមិនយកកម្រៃ កាលបើមានការចាំបាច់

១០.សិទ្ធិបង្ហាញភស្តុតាង

១១.សិទ្ធិស្នើសុំឲ្យកោះហៅសាក្សី និងសួរសាក្សី

១២.សិទ្ធិស្នើសុំអនុញ្ញាតនៅក្រៅឃុំ

១៣.សិទ្ធិស្នើសុំឲ្យកែប្រែវិធានការត្រួតពិនិត្យតាមផ្លូវតុលាការ

[38] ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧, មាត្រា១៤៣ កថាខណ្ឌ១

[39] ច្បាប់ស្តីពីយុត្តិធម៌អនីតិជន ឆ្នាំ២០១៦ មាត្រា៣៣ កថាខណ្ឌ១

[40] ច្បាប់ស្តីពីយុត្តិធម៌អនីតិជន ឆ្នាំ២០១៦, មាត្រា៦

១៤.សិទ្ធិទំនាក់ទំនងជាមួយស្ថានទូត ស្ថានកុងស៊ុល ក្នុងករណីអនីតិជនជាជនបរទេស

១៥.សិទ្ធិផ្សេងៗទៀត ដែលមានចែងក្នុងបទដ្ឋានគតិយុត្តជាធរមាន។

ប្រសិនបើជនត្រូវចោទមានឆន្ទៈក្នុងការឆ្លើយ ចៅក្រមត្រូវទទួលចម្លើយនោះភ្លាម ។ ចៅក្រមស៊ើបសួរត្រូវប្រាប់ឲ្យបានដឹងពីសិទ្ធិរបស់ខ្លួនក្នុងការជ្រើសរើសមេធាវី ឬសុំចាត់មេធាវីឲ្យខ្លួនដោយអនុលោមតាមច្បាប់ស្តីពីលក្ខន្តិកៈមេធាវី ក្នុងករណីនេះចៅក្រមស៊ើបសួរអាចស្នើសុំចាត់តាំងមេធាវីម្នាក់ ឬច្រើនតាមរយៈរដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ។

ចំពោះជនត្រូវចោទដែលជាអនីតិជនត្រូវមានមេធាវីអមជានិច្ច[41] ប្រសិនបើជនត្រូវចោទជាជនក្រីក្រ ពុំមានលទ្ធភាពក្នុងការពឹងពាក់ដោយខ្លួនឯងទេ ចៅក្រមស៊ើបសួរត្រូវស្នើសុំចាត់តាំងមេធាវីការពារសិទ្ធិឲ្យជនត្រូវចោទ។

ក្នុងករណីចាំបាច់ចៅក្រមអាចស្នើសុំអ្នកបកប្រែ ដោយអ្នកបកប្រែចាំបាច់ត្រូវធ្វើសម្បថទៅតាមជំនឿសាសនារបស់ខ្លួន ដែលបញ្ជាក់ថាខ្លួននឹងជួយដល់តុលាការ ព្រមទាំងធ្វើឲ្យបានត្រឹមត្រូវតាមចម្លើយរបស់ជនត្រូវចោទ ហើយទោះបីជាករណីណាក៏ដោយអ្នកបកប្រែមិនអាចជា ចៅក្រម ក្រឡាបញ្ជី នគរបាល កងរាជអាវុធហត្ថ ភាគី ឬជាសាក្សីឡើយ[42]។

គ្រប់កំណត់ហេតុរបស់ចៅក្រមស៊ើបសួរត្រូវតែមានចុះសេចក្តីដូចខាងក្រោម[43]៖

-ឈ្មោះរបស់ចៅក្រមស៊ើបសួរ

-ឈ្មោះក្រឡាបញ្ជី

-លេខ ថ្ងៃ ខែ ឆ្នាំ សំណុំរឿង

-កាលបរិច្ឆេទនៃដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ

-ប្រភេទនៃបទល្មើស ដែលចង្អុលប្រាប់នៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ

-កាលបរិច្ឆេទនៃការធ្វើកំណត់ហេតុ។

ទំព័រនីមួយៗនៃកំណត់ហេតុត្រូវតែចុះហត្ថលេខាដោយចៅក្រមស៊ើបសួរ និងក្រឡាបញ្ជី ។ កំណត់ហេតុមិនត្រូវឲ្យមានចន្លោះបន្ទាត់ទេ ការឆូតលុប ឬការយោងត្រូវតែបញ្ជាក់ដោយហត្ថលេខារបស់ចៅក្រមស៊ើបសួរ និងក្រឡាបញ្ជី នៅរឹមទំព័រ[44]។

[41] ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧, មាត្រា១៤៣ កថាខណ្ឌ៤

[42] ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧, មាត្រា១៤៤

[43] ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧, មាត្រា២៤០ កថាខណ្ឌ១

[44] ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧, មាត្រា២៤០ កថាខណ្ឌ២

ទំព័រនីមួយៗនៃកំណត់ហេតុស្តីពីការចូលបង្ហាញខ្លួនលើកដំបូង ត្រូវចុះហត្ថលេខារបស់ចៅក្រម ក្រឡាបញ្ជី សាមីខ្លួននៅរឹមទំព័រ ។ កាលណាដែលជនត្រូវចោទបានឆ្លើយចម្លើយទាំងនេះត្រូវកត់ត្រាជាលាយលក្ខណ៍ អក្សរឲ្យបានត្រឹមត្រូវនៅក្នុងកំណត់ហេតុ។

**កថាខណ្ឌទី២៖ ការឃុំខ្លួនបណ្តោះអាសន្ន**

ជនគ្រប់រូបមានសិទ្ធិរស់រានមានជីវិត មានសេរីភាព និងមានសន្តិសុខផ្ទាល់ខ្លួន[45] ជាគោលការណ៍ជនត្រូវគ្រប់រូបត្រូវតែមានសេរីភាព ប៉ុន្តែជនត្រូវចោទក៏អាចត្រូវបានឃុំខ្លួនប្រសិនបើអំពើរបស់ជននោះធ្វើឲ្យមានភាពអសន្តិសុខដល់សង្គម និងសណ្តាប់ធ្នាប់សាធារណៈ ហើយការឃុំខ្លួននេះក៏មិនត្រូវឲ្យជននោះ ត្រូវទទួលរងការធ្វើទារុណកម្មប្រព្រឹត្តមកលើខ្លួន ឬទណ្ឌកម្មឯទៀត ដែលឃោរឃៅ អមនុស្សធម៌ ឬបន្ថោកបន្ទាបឡើយ[46] ។ ក្នុងករណីពិសេសជនត្រូវចោទអាចត្រូវឃុំខ្លួនបណ្តោះអាសន្ន[47] ការឃុំខ្លួនបណ្តោះអាសន្ននេះត្រូវមានសំអាងហេតុត្រឹមត្រូវមួយដែលកំណត់ក្នុងដីកាសម្រេច ។

ចៅក្រមស៊ើបសួរអាចចេញដីកាបង្គាប់ឲ្យឃុំខ្លួន[48] ដែលក្នុងដីកានេះគឺបញ្ជាដល់ប្រធានពន្ធនាគារ ឬមណ្ឌលឃុំខ្លួនឲ្យទទួល និងឃុំខ្លួនជនត្រូវចោទ ។ ចៅក្រមស៊ើបសួរអាចនឹងចេញដីកាបង្គាប់ឲ្យឃុំខ្លួនបានលុះត្រាតែជនត្រូវចោទជាកម្មវត្ថុ នៃដីកាសម្រេចឲ្យឃុំខ្លួនបណ្តោះអាសន្ន[49] ។ គ្មានជនណាម្នាក់ត្រូវបានចាប់ខ្លួន ឃុំខ្លួន និងនិរទេសខ្លួន ដោយបំពានឡើយ[50]។

ដីកាសម្រេចឲ្យឃុំខ្លួនបណ្តោះអាសន្ន[51] បញ្ជាក់ពីមូលហេតុនៃការឃុំខ្លួនបណ្តោះអាសន្ន ហើយដីកានេះត្រូវជូនដំណឹងទៅជនត្រូវចោទ មេធាវី និងតំណាងអយ្យការភ្លាម ដោយដីកានេះជនត្រូវចោទ និងតំណាងអយ្យការមានសិទ្ធិក្នុងការប្តឹងឧទ្ធរណ៍ ក្នុងរយៈពេល៥(ប្រាំ)ថ្ងៃ បន្ទាប់ពីបានទទួលដំណឹងពីដីកាសម្រេចនេះ[52]។

ការពិភាក្សាដេញដោល[53] ត្រូវបានយកមកអនុវត្តក្នុងករណីសួរចម្លើយទល់នឹងជនត្រូវចោទ ដោយមានការធ្វើកំណត់ហេតុស្តីពីការពិភាក្សាដេញដោលចំពោះមុខ ហើយក្នុងអត្ថន័យនៃការធ្វើកំណត់ហេតុនេះគឺសម្រេចអំពីការឃុំខ្លួន ឬមិនឃុំខ្លួនលើជនត្រូវចោទ ។ តំណាងអយ្យការអាចចូលរួមពិភាក្សាដេញដោលចំពោះមុខនេះ

[45] រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ១៩៩៣, មាត្រា៣២ កថាខណ្ឌ១
[46] សេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស របស់មហាសន្និបាតអង្គការសហប្រជាជាតិ ឆ្នាំ១៩៤៨, មាត្រា៥
[47] ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧, មាត្រា២០៣
[48] ដីកាបង្គាប់ឲ្យឃុំខ្លួន ដូចមានក្នុងឧបសម្ព័ន្ធទី៧
[49] ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧, មាត្រា២២០
[50] សេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស របស់មហាសន្និបាតអង្គការសហប្រជាជាតិ ឆ្នាំ១៩៤៨, មាត្រា៩
[51] ដីកាសម្រេចឲ្យឃុំខ្លួនបណ្តោះអាសន្ន ដូចមានក្នុងឧបសម្ព័ន្ធទី៦
[52] ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧, មាត្រា២៦៧ និងមាត្រា២៧០
[53] កំណត់ហេតុស្តីពីការពិភាក្សាដេញដោលចំពោះមុខ ដូចមានក្នុងឧបសម្ព័ន្ធទី៤

ឬដោយមានការបញ្ជាក់ពីការស្នើសុំឲ្យឃុំខ្លួនលើជនត្រូវចោទ តាមរយៈដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ ឬ ដីកាសន្និដ្ឋានស្នើសុំឲ្យឃុំខ្លួនបណ្ដោះអាសន្នដែលភ្ជាប់មកជាមួយសំណុំរឿង ។ ជនត្រូវចោទ ព្រះរាជអាជ្ញា និង មេធាវីអាចលើកសំណួរបានដោយមានការអនុញ្ញាតពីចៅក្រមស៊ើបសួរ[54] ។

ការឃុំខ្លួនបណ្ដោះអាសន្នអាចអនុវត្តបានតែក្នុងករណីចោទប្រកាន់ពីបទឧក្រិដ្ឋ ឬបទមជ្ឈិមដែលច្បាប់ កំណត់ផ្ដន្ទាទោសដាក់ពន្ធនាគារស្មើ ឬលើសពី១ឆ្នាំ[55] ។ ការឃុំខ្លួនបណ្ដោះអាសន្នត្រូវមានមូលហេតុដូចខាង ក្រោមសម្រាប់ជាសំអាងហេតុ[56]៖

-ដើម្បីបញ្ចប់បទល្មើស ឬបង្ការបទល្មើសមិនឲ្យកើតជាថ្មី

-ដើម្បីរារាំងកុំឲ្យមានការគាបសង្កត់លើសាក្សី ឬជនរងគ្រោះ ឬដើម្បីរារាំងកុំឲ្យមានការត្រូវរ៉ូវគ្នា រវាងជន ត្រូវចោទ និងអ្នកសមគំនិត

-ដើម្បីរក្សាភស្តុតាង ឬតម្រុយជាសម្ភារៈ

-ដើម្បីធានារក្សាជនត្រូវចោទ ទុកជូនតុលាការចាត់ការតាមនីតិវិធី

-ដើម្បីការពារសន្តិសុខឲ្យជនត្រូវចោទ

-ដើម្បីធានារក្សាសណ្ដាប់ធ្នាប់សាធារណៈកុំឲ្យមានការច្របូកច្របល់ ដែលបណ្ដាលមកពីបទល្មើស។

**ក. ការឃុំខ្លួនជនត្រូវចោទដែលជានីតិជន**

ការឃុំខ្លួនចំពោះនីតិជនដែលត្រូវបានចោទប្រកាន់ពីបទឧក្រិដ្ឋ មានរយៈពេលមិនលើសពី៦ (ប្រាំមួយ) ខែ ហើយចៅក្រមអាចពន្យាពេលនៃការឃុំខ្លួនបណ្ដោះអាសន្ន ២(ពីរ)ដងគត់ ដោយក្នុងម្ដងមានរយៈពេល ៦ (ប្រាំមួយ)ខែ ដូចនេះការឃុំខ្លួនបណ្ដោះអាសន្នលើជនត្រូវចោទដែលជានីតិជនមានរយៈពេលសរុបមិនលើសពី ១៨(ដប់ប្រាំបី)ខែ មិនតែប៉ុណ្ណោះការពន្យាពេលឃុំខ្លួនលើជនត្រូវចោទក្នុងមួយលើកៗ ត្រូវមានដីកាសំអាងហេតុ ត្រឹមត្រូវ និងច្បាស់លាស់[57]។

ការឃុំខ្លួនចំពោះនីតិជនដែលត្រូវបានចោទប្រកាន់ពីបទមជ្ឈិម មានរយៈពេលមិនលើសពី ៤(បួន)ខែ ហើយចៅក្រមអាចធ្វើការពន្យាពេលឃុំខ្លួនជនត្រូវចោទបានតែម្ដងគត់ដោយមិនលើសពី ២(ពីរ)ខែ ដោយដីកា មានសំអាងហេតុត្រឹមត្រូវ និងច្បាស់លាស់[58] ដូចនេះ ចៅក្រមស៊ើបសួរអាចឃុំខ្លួនជនត្រូវចោទបណ្ដោះអាសន្ន ក្នុងរយៈពេលសរុបមិនលើសពី ៦(ប្រាំមួយ)ខែ។

---

[54] ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧, មាត្រា១៤១ កថាខណ្ឌ១

[55] ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧, មាត្រា២០៤

[56] ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧, មាត្រា២០៥

[57] ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧, មាត្រា២០៨

[58] ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧, មាត្រា២០៩

### ខ. ការឃុំខ្លួនជនត្រូវចោទដែលជាអនីតិជន

ចំពោះអនីតិជនដែលមានអាយុតិចជាង ១៤(ដប់បួន)ឆ្នាំ មិនអាចត្រូវបានឃុំខ្លួនបណ្ដោះអាសន្នទេ[59] ប៉ុន្តែតំណាងអយ្យការអាចនឹងធ្វើការចោទប្រកាន់ និងដំណើរការនីតិវិធីជាធម្មតា ហើយមូលហេតុនៃការមិនទទួលខុសត្រូវព្រហ្មទណ្ឌទាក់ទងទៅនឹងអាយុនេះផងដែរ ក៏ពុំអាចជាមូលហេតុនៃការតម្កល់រឿងទុកឥតចាត់ការឡើយ ។

•ចំពោះអនីតិជនដែលមានអាយុចាប់ពី ១៤(ដប់បួន)ឆ្នាំ ដល់ក្រោម ១៨(ដប់ប្រាំបី)ឆ្នាំ ដែលត្រូវបានចោទប្រកាន់ពី**បទឧក្រិដ្ឋ** ត្រូវបានកំណត់អំពីការឃុំខ្លួនដូចខាងក្រោម[60]៖

-សម្រាប់អនីតិជនដែលមានអាយុតិចជាង ១៦(ដប់ប្រាំមួយ)ឆ្នាំ ការឃុំខ្លួនបណ្ដោះអាសន្នត្រូវធ្វើឡើងដោយមិនអាចលើស ៤(បួន)ខែ បានទេ។

-សម្រាប់អនីតិជនដែលមានអាយុចាប់ពី ១៦(ដប់ប្រាំមួយ)ឆ្នាំ ដល់ក្រោម ១៨(ដប់ប្រាំបី)ឆ្នាំ ការឃុំខ្លួនបណ្ដោះអាសន្នត្រូវធ្វើឡើងដោយមិនអាចលើស ៦(ប្រាំមួយ)ខែ បានទេ។

•ចំពោះអនីតិជនដែលមានអាយុចាប់ពី ១៤(ដប់បួន)ឆ្នាំ ដល់ក្រោម ១៨(ដប់ប្រាំបី)ឆ្នាំ ដែលត្រូវបានចោទប្រកាន់ពី**បទមជ្ឈិម** ត្រូវបានកំណត់ដូចខាងក្រោម[61] ៖

-សម្រាប់អនីតិជនដែលមានអាយុតិចជាង ១៦(ដប់ប្រាំមួយ)ឆ្នាំ ការឃុំខ្លួនបណ្ដោះអាសន្នត្រូវធ្វើឡើងដោយមិនអាចលើស ២(ពីរ)ខែ បានទេ។

-សម្រាប់អនីតិជនដែលមានអាយុចាប់ពី ១៦(ដប់ប្រាំមួយ)ឆ្នាំ ដល់ក្រោម ១៨(ដប់ប្រាំបី)ឆ្នាំ ការឃុំខ្លួនបណ្ដោះអាសន្នត្រូវធ្វើឡើងដោយមិនអាចលើស ៤(បួន)ខែ បានទេ។

✍**សម្គាល់**៖ ការឃុំខ្លួនបណ្ដោះអាសន្នចំពោះអនីតិជនមិនត្រូវលើសពីពាក់កណ្ដាលអប្បរមា នៃទោសដែលច្បាប់បានកំណត់សម្រាប់អនីតិជនឡើយ ។ ចៅក្រមអាចសម្រេចឃុំខ្លួនបណ្ដោះអាសន្នលើជនត្រូវចោទបន្ទាប់ពីបានឆ្លងកាត់ការបង្ហាញខ្លួនលើកដំបូង និងពិភាក្សាដេញដោលចំពោះមុខ។

### កថាខណ្ឌទី៣៖ ការមិនឃុំខ្លួនជនត្រូវចោទ

ក្នុងករណីតំណាងអយ្យការបានចោទប្រកាន់លើជនត្រូវចោទពីបទ រក្សាទុក ដឹកជញ្ជូន ឬជួញដូរដោយខុសច្បាប់នូវសារធាតុញៀន ហើយត្រូវបញ្ជូនមកចៅក្រមស៊ើបសួរជាអ្នកចាត់ការបន្តក្នុងការសាកសួរចម្លើយនិងផ្អែកតាមសកម្មភាពរបស់ជនត្រូវចោទ រួមទាំងចម្លើយដោះបន្ទុករបស់ជនត្រូវចោទ ដែលជាមូលដ្ឋានអាចឲ្យ

---

[59] ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧, មាត្រា២១២ វាក្យខណ្ឌ១

[60] ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧, មាត្រា២១៣

[61] ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧, មាត្រា២១៤

ចៅក្រមស៊ើបសួរជឿទុកចិត្តបាន ចៅក្រមស៊ើបសួរប្រើប្រាស់ឆន្ទានុសិទ្ធិដោយយល់ឃើញថាការឃុំខ្លួនដែលជាជម្រើសចុងក្រោយមិនត្រូវយកមកប្រើប្រាស់ ហើយការឃុំខ្លួនមិនចាំបាច់ចំពោះជនត្រូវចោទ ចៅក្រមស៊ើបសួរអាចសម្រេចដាក់ជនត្រូវចោទឲ្យស្ថិតនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការបាន ដោយចៅក្រមស៊ើបសួរដាក់នូវកាតព្វកិច្ចមួយចំនួនចំពោះជនត្រូវចោទ ។ ការសម្រេចអំពីការមិនឃុំខ្លួននេះ ចៅក្រមស៊ើបសួរត្រូវជូនដំណឹងទៅតំណាងអយ្យការអំពីដីកាសម្រេចដាក់ជនត្រូវចោទឲ្យស្ថិតនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ និងដីកាសម្រេចមិនឃុំខ្លួនបណ្ដោះអាសន្ន[62] ប្រសិនបើតំណាងអយ្យការបានប្ដឹងសុំឲ្យចៅក្រមស៊ើបសួរធ្វើការឃុំខ្លួនលើជនត្រូវចោទនោះ។

**ក. ការសម្រេចមិនឃុំខ្លួនជនត្រូវចោទ**

កាលណាចៅក្រមស៊ើបសួរ បានទទួលដីកាសន្និដ្ឋានសុំឲ្យឃុំខ្លួនបណ្ដោះអាសន្នលើជនត្រូវចោទរបស់ព្រះរាជអាជ្ញា ហើយមិនធ្វើតាមការស្នើសុំឲ្យឃុំខ្លួនជនត្រូវចោទតាមការស្នើសុំនោះទេ ចៅក្រមស៊ើបសួរត្រូវចេញក្នុងរយៈពេល០៥ថ្ងៃ នូវដីកាសម្រេចមិនឃុំខ្លួនបណ្ដោះអាសន្ន ដោយមិនចាំបាច់មានសំអាងហេតុទេ ។ ដីកានេះត្រូវជូនដំណឹងជាបន្ទាន់ដល់អ្នកប្ដឹងសុំ[63]។

ប្រសិនបើចៅក្រមស៊ើបសួរមិនបានសម្រេចក្នុងរយៈពេល០៥ថ្ងៃ តំណាងអយ្យការអាចធ្វើពាក្យប្ដឹងទៅសភាស៊ើបសួរ ដែលនឹងសម្រេចជំនួសចៅក្រមស៊ើបសួរ ។ តំណាងអយ្យការមានសិទ្ធិប្ដឹងទៅសភាស៊ើបសួរចំពោះដីកាសម្រេចមិនឃុំខ្លួនបណ្ដោះអាសន្នរបស់ចៅក្រមស៊ើបសួរ ប្រសិនបើយល់ឃើញថាការឃុំខ្លួនពិតជាចាំបាច់ក្នុងករណីបទល្មើសរក្សាទុក ដឹកជញ្ជូន ឬជួញដូរដោយខុសច្បាប់នូវសារធាតុញៀននេះ ។

**ខ. ការដាក់ជនត្រូវចោទឲ្យស្ថិតនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ**

ចៅក្រមស៊ើបសួរអាចដាក់ជនត្រូវចោទឲ្យនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ[64] បានគ្រប់ពេលវេលា ប្រសិនបើជនត្រូវចោទនេះ ត្រូវបានចោទប្រកាន់អំពីបទល្មើសដែលត្រូវផ្ដន្ទាទោសដាក់ពន្ធនាគារ[65] ។ ការដាក់ជនត្រូវចោទឲ្យស្ថិតនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការនេះ គឺតម្រូវឲ្យជនត្រូវចោទគោរព និងអនុវត្តនូវកាតព្វកិច្ចមួយ ឬច្រើនដូចខាងក្រោម[66]៖

១.មិនត្រូវចេញពីព្រំប្រទល់ដែនដីដែលកំណត់ដោយចៅក្រមស៊ើបសួរ។

២.មិនត្រូវផ្លាសប្ដូរលំនៅឋានដោយគ្មានការអនុញ្ញាតពីចៅក្រមស៊ើបសួរ។

---

[62] ដីកាសម្រេចមិនឃុំខ្លួនបណ្ដោះអាសន្ន ដូចមានក្នុងឧបសម្ព័ន្ធទី៨

[63] ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧, មាត្រា២០៧

[64] ដីកាសម្រេចដាក់ជនត្រូវចោទឲ្យស្ថិតនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ មានក្នុងឧបសម្ព័ន្ធទី៩

[65] ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧, មាត្រា២២៣ កថាខណ្ឌ១

[66] ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧, មាត្រា២២៣ កថាខណ្ឌ២

៣.មិនត្រូវទៅទីកន្លែងខ្លះដែលកំណត់ដោយចៅក្រមស៊ើបសួរ។

៤.ត្រូវចូលបង្ហាញខ្លួនតាមការកំណត់នៅអង្គភាពនគរបាល ឬកងរាជអាវុធហត្ថដែលចាត់តាំងដោយចៅក្រមស៊ើបសួរ។

៥.ត្រូវឆ្លើយតបនឹងការកោះហៅពីបុគ្គលគ្រប់បុគ្គលដែលចាត់តាំងដោយចៅក្រមស៊ើបសួរ។

៦.ប្រគល់ជូនការិយាល័យក្រឡាបញ្ជីគ្រប់ឯកសារបញ្ជាក់ពីអត្តសញ្ញាណ។

៧.មិនត្រូវបើកបររថយន្ត។

៨.មិនត្រូវទទួល ឬជួបបុគ្គលមួយចំនួនដែលចង្អុលបង្ហាញដោយចៅក្រមស៊ើបសួរ។

៩.ដាក់ប្រាក់ធានាដែលចំនួនប្រាក់ធានា និងថេរវេលាបង់ប្រាក់នេះត្រូវបានកំណត់ដោយចៅក្រមស៊ើបសួរដោយផ្អែកទៅលើធនធានរបស់ជនត្រូវចោទ។

១០.មិនត្រូវកាន់កាប់ ឬយកតាមខ្លួននូវអាវុធ ។ ត្រូវប្រគល់ជូនដល់ការិយាល័យក្រឡាបញ្ជីនូវអាវុធដែលជនត្រូវចោទកាន់កាប់។

១១.ត្រូវប្រគល់ខ្លួនឲ្យពេទ្យពិនិត្យព្យាបាល និងដាយថាហេតុ ដាក់ឲ្យស្ថិតនៅក្រោមរបបព្យាបាលរោគក្នុងមន្ទីរពេទ្យ។

១២.មិនត្រូវធ្វើសកម្មភាពខាងវិជ្ជាជីវៈខ្លះ។

ដីកាសម្រេចដាក់ជនត្រូវចោទឲ្យស្ថិតនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ ត្រូវជូនដំណឹងទៅតំណាងអយ្យការ និងជនត្រូវចោទដើម្បីឲ្យបានដឹងអំពីកាតព្វកិច្ចមួយចំនួនរបស់ជនត្រូវចោទ[67] ។ ជនត្រូវចោទ តំណាអយ្យការអាចធ្វើការស្នើសុំទៅចៅក្រមស៊ើបសួរបានគ្រប់ពេលវេលាសម្រាប់ការ កែប្រែកាតព្វកិច្ចមួយចំនួនក្នុងដីកាសម្រេចដាក់ជនត្រូវចោទឲ្យស្ថិតនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ ហើយក្នុងករណីចៅក្រមស៊ើបសួរមិនបានសម្រេចអំពីការស្នើសុំរបស់តំណាងអយ្យការ ឬជនត្រូវចោទទេ ក្នុងរយៈពេល៥ថ្ងៃ ជនត្រូវចោទ ឬតំណាងអយ្យការដែលជាអ្នកស្នើសុំអាចប្ដឹងទៅសភាស៊ើបសួរដើម្បីសម្រេចជំនួសចៅក្រមស៊ើបសួរបាន ។ ក្នុងករណីផុតបណ្ដឹងឧទ្ធរណ៍ចំពោះដីកាសម្រេចនេះ ហើយជនត្រូវចោទមិនអនុវត្តតាមកាតព្វកិច្ចដែលមានក្នុងដីកាសម្រេចដាក់ជនត្រូវចោទឲ្យស្ថិតក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការទេ សកម្មភាពនោះអាចជាសំអាងហេតុដែលចៅក្រមស៊ើបសួរចេញដីកាបង្គាប់ឲ្យចាប់ខ្លួនជនត្រូវចោទ។

ចំពោះអនីតិជនដែលមានអាយុក្រោម១៤ឆ្នាំ ដែលមិនទាន់ដល់នីតិភាពសម្រាប់ការទទួលខុសត្រូវព្រហ្មទណ្ឌ ចៅក្រមស៊ើបសួរមិនអាចដាក់ជននោះឲ្យស្ថិតនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការទេ[68]។

[67] ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧, មាត្រា២២៦ កថាខណ្ឌ២

[68] ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧, មាត្រា២២៤

**កថាខណ្ឌទី៤៖ ការសួរចម្លើយជនត្រូវចោទ**

ជនត្រូវចោទត្រូវបានសួរចម្លើយដោយចៅក្រមស៊ើបសួរ ដោយមានក្រឡាបញ្ជីអមជាអ្នកធ្វើកំណត់ហេតុ ឬកក់ត្រារាល់ចម្លើយរបស់ជនត្រូវចោទ[69] ហើយប្រសិនបើជនត្រូវចោទមានមេធាវីការពារសិទ្ធិ នោះជនត្រូវចោទអាចឆ្លើយនៅតែចំពោះមុខមេធាវីរបស់ខ្លួនតែប៉ុណ្ណោះ ។ ប៉ុន្តែក្នុងករណីចៅក្រមស៊ើបសួរបានកោះហៅមេធាវីត្រឹមត្រូវ ហើយពុំឃើញមេធាវីចូលរួមក្នុងនីតិវិធីតាមកាលកំណត់ទេ ចៅក្រមស៊ើបសួរអាចសួរចម្លើយជនត្រូវចោទដោយគ្មានវត្តមានមេធាវី ។ ចម្លើយរបស់ជនត្រូវចោទក្នុងដំណាក់កាលចៅក្រមស៊ើបសួរចៅក្រមបានប្រាប់ពីសិទ្ធិរបស់ជនត្រូវចោទរួចរាល់ហើយ ដូចនេះជនត្រូវចោទអាចឆ្លើយអង្គហេតុ និងមូលហេតុដែលត្រូវបានគេឃាត់ខ្លួនបញ្ជូនមកសាលាដំបូងរាជធានី-ខេត្ត ប្រសិនបើជនត្រូវចោទបដិសេធ ឬឯកភាពយល់ព្រមយកចម្លើយរបស់ខ្លួនដែលបានឆ្លើយនៅដំណាក់កាលមន្ត្រីនគរបាលយុត្តិធម៌ និងដំណាក់កាលអយ្យការ ចៅក្រមស៊ើបសួរត្រូវបញ្ជាក់ឲ្យបានច្បាស់ ហើយក្នុងករណីជនត្រូវចោទបដិសេធចំពោះចម្លើយរបស់ខ្លួននៅដំណាក់កាលណាមួយ ឬទាំងពីរដំណាក់កាល ហើយចៅក្រមអាចសាកសួរអំពីមូលហេតុដែលបដិសេធនោះ ។ ឧទាហរណ៍៖ ជនត្រូវចោទបានបដិសេធចម្លើយក្នុងដំណាក់កាលមន្ត្រីនគរបាលយុត្តិធម៌ ដោយមូលហេតុថាពេលដែលខ្លួនឆ្លើយនោះ ពុំមានស្មារតីគ្រប់គ្រាន់ក្នុងការឆ្លើយ ឬមានការភ័យខ្លាចជាដើម។

ជនត្រូវចោទដែលជាអនីតិជនត្រូវមានមេធាវីអមជានិច្ច ក្នុងអំឡុងពេលស្តាប់ចម្លើយនៅចំពោះមុខចៅក្រមស៊ើបសួរ ក្នុងករណីគ្មានការជ្រើសរើសចៅក្រមស៊ើបសួរត្រូវចាត់តាំងមេធាវីការពារសិទ្ធិឲ្យជនត្រូវចោទដែលជាអនីតិជននោះ ដោយស្របតាមច្បាប់លក្ខន្តិកៈមេធាវី[70] ។ មិនតែប៉ុណ្ណោះ ក្នុងនីតិវិធីស្តាប់ចម្លើយរបស់អនីតិជនត្រូវធ្វើឡើងដោយសម្ងាត់ និងប្រើប្រាស់នីតិវិធីកុមារមេត្រី[71] ដែលសំដៅដល់ដំណើរការ និងនីតិវិធីដែលពាក់ព័ន្ធនឹងការលើកទឹកចិត្តឲ្យអនីតិជនចូលរួមក្នុងរឿងក្តី តាមរយៈការប្រើប្រាស់ភាសា និងអាកប្បកិរិយាក្នុងកម្រិតដែលអនីតិជនអាចយល់បាន និងក្នុងបរិយាកាសដែលផ្តល់ឲ្យអនីតិជននូវសុវត្ថិភាព សន្តិសុខ សិទ្ធិ និងតម្រូវការជាមូលដ្ឋាន។

បទរក្សាទុក ដឹកជញ្ជូន ឬជួញដូរដោយខុសច្បាប់នូវសារធាតុញៀន ដែលភាគច្រើនជាបទល្មើសជាក់ស្តែងដោយមានការឃាត់ខ្លួនដោយមន្ត្រីនគរបាលយុត្តិធម៌ និងកសាងសំណុំរឿងបញ្ជូនមកអយ្យការអមសាលាដំបូងរាជធានី-ខេត្ត ដើម្បីធ្វើការចោទប្រកាន់ បន្ទាប់ពីតំណាងអយ្យការបានចោទប្រកាន់លើជនត្រូវចោទរួចមកតំណាងអយ្យការអាចបញ្ជូនរឿងទៅចៅក្រមស៊ើបសួរដើម្បីចាត់ការបន្ត ហើយប្រសិនបើជនត្រូវចោទមានមេធាវីការពារ

[69] កំណត់ហេតុស្តីពីការសួរចម្លើយជនត្រូវចោទ ដូចមានក្នុងឧបសម្ព័ន្ធទី៥

[70] ច្បាប់ស្តីពីយុត្តិធម៌អនីតិជន ឆ្នាំ២០១៦, មាត្រា៣២ កថាខណ្ឌ២

[71] ច្បាប់ស្តីពីយុត្តិធម៌អនីតិជន ឆ្នាំ២០១៦, មាត្រា៤ ចំណុច៧

សិទ្ធិ នោះរាល់ចម្លើយរបស់ជនត្រូវចោទគ្រប់ដំណាក់កាលដោយរាប់ចាប់ពីដំណាក់កាលមន្ត្រីនគរបាលយុត្តិធម៌ បន្ទាប់ពីធ្វើការឃាត់ខ្លួនបាន២៤(ម្ភៃបួន)ម៉ោង ដំណាក់កាលអយ្យការ និងដល់ដំណាក់កាលចៅក្រមស៊ើបសួរ ។ ប្រសិនបើជនត្រូវចោទពុំព្រមឆ្លើយដោយរង់ចាំមេធាវីការពារសិទ្ធិដើម្បីអមចម្លើយ ចៅក្រមសម្រេចលើកពេលសួរចម្លើយទៅពេលក្រោយទៀត ដោយកំណត់កាលបរិច្ឆេទកោះហៅមេធាវីឲ្យបានត្រឹមត្រូវ[72]។

ចៅក្រមស៊ើបសួរអាចធ្វើការសាកសួរទាំងដាក់បន្ទុក និងដោះបន្ទុកទៅលើជនត្រូវចោទចំពោះបទល្មើសដែលតំណាងអយ្យការបានធ្វើការចោទប្រកាន់ ពុំមានការបង្ខិតបង្ខំណាមួយដើម្បីឲ្យជនត្រូវចោទឆ្លើយអ្វីដែលជាការដាក់បន្ទុកដល់ខ្លួនឡើយក្នុងពេលសាកសួរចម្លើយ ដោយចៅក្រមស៊ើបសួរបានប្រាប់សិទ្ធិរបស់ជនត្រូវចោទក្នុងការបង្ហាញខ្លួនលើកដំបូង[73] ។

## ផ្នែកទី២៖ ការពិសោធន៍ និងធ្វើកោសលវិច័យ

ចៅក្រមស៊ើបសួរមានសមត្ថកិច្ចក្នុងការស្រាវជ្រាវរកភស្តុតាងដាក់បន្ទុក និងដោះបន្ទុកទៅលើជនត្រូវ-ចោទ ដែលការស្រាវជ្រាវនេះស្តែងចេញពីការធ្វើកោសលវិច័យលើវត្ថុតាងដែលជាកិច្ចសំខាន់ ការស៊ើបសួរដោយចុះពិនិត្យ និងស្រាវជ្រាវផ្ទាល់ ឬប្រគល់សិទ្ធិជូននគរបាលយុត្តិធម៌ ឬចៅក្រមស៊ើបសួរនៃសាលាដំបូងណាម្នាក់ដើម្បីបំពេញកិច្ចស៊ើបសួរនោះ ។ ការស្រាវជ្រាវរបស់ចៅក្រមស៊ើបសួរ គឺមានគោលបំណងរកឲ្យឃើញនូវការពិតនិងរកឲ្យឃើញនូវអត្ថិភាពនៃបទល្មើសរក្សាទុក ដឹកជញ្ជូន ឬជួញដូរដោយខុសច្បាប់នូវសារធាតុញៀន ដែលតំណាងអយ្យការបានធ្វើការចោទប្រកាន់លើជនត្រូវចោទ។

### កថាខណ្ឌទី១៖ ការធ្វើកោសលវិច័យ

ចៅក្រមស៊ើបសួរចាត់តាំងមន្ត្រីជំនាញដើម្បីធ្វើកោសលវិច័យ លើវត្ថុតាងដែលមានតម្រុយជាសារធាតុញៀន ដើម្បីរកឲ្យឃើញនូវសារធាតុសុទ្ធរបស់សារធាតុញៀននោះ ហើយប្រសិនបើជាលទ្ធផលបញ្ជាក់ថាពុំមានសារធាតុញៀនទេ ចៅក្រមស៊ើបសួរសម្រេចដោះលែងជនត្រូវចោទឲ្យមានសេរីភាពដោយឥតលក្ខខណ្ឌ ប្រសិនបើមានភស្តុតាង និងការអះអាងត្រឹមត្រូវ ។ ផ្ទុយទៅវិញ ក្នុងករណីចៅក្រមស៊ើបសួរយល់ឃើញថា អំពើនោះជាបទល្មើសដែលផ្អែកលើធាតុផ្សំនៃបទល្មើស គ្រង់ធាតុផ្សំអត្តនោម័តដែលសំដៅលើគោលបំណងរបស់ជនត្រូវ-ចោទនោះជនត្រូវចោទនៅតែមានពិរុទ្ធភាពក្នុងការប្រព្រឹត្តបទល្មើស បើទោះជាការធ្វើកោសលវិច័យលើវត្ថុតាងដោយជាលទ្ធផលពុំមែនជាសារធាតុញៀនក៏ដោយ ។ នៅពេលដែលមានបញ្ហាបច្ចេកទេសកើតឡើង ចៅក្រមស៊ើបសួរអាចបង្គាប់ឲ្យធ្វើកោសលវិច័យដោយឯកឯង ឬតាមពាក្យសុំរបស់ព្រះរាជអាជ្ញា ឬជនត្រូវចោទ[74] ។

[72] ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧, មាត្រា១៤៥ កថាខណ្ឌ១

[73] ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧, មាត្រា១៤៣

[74] ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧, មាត្រា១៦២ កថាខណ្ឌ១

ចៅក្រមដែលមានសមត្ថកិច្ចត្រូវដកយកជាបន្ទាន់នូវសំណាកយ៉ាងតិច៣(បី)កញ្ចប់ ឬតាមចំនួនដែលត្រូវការជាចាំបាច់ នៅចំពោះមុខអ្នកកាន់កាប់ទីកន្លែង ឬជនដែលពាក់ព័ន្ធជាមួយបទល្មើស ឬចំពោះមុខសាក្សី ០២នាក់ ប្រសិនបើគ្មានអ្នកកាន់កាប់ទីកន្លែង ឬជនដែលពាក់ព័ន្ធក្នុងបទល្មើស ដើម្បីជាភស្តុតាង និងជាការកត់សម្គាល់ភិនភាគនៃវត្ថុដែលសង្ស័យថាជាគ្រឿងញៀនដែលបានចាប់យក[75] ។ សំណាកនីមួយៗ ត្រូវដាក់ក្នុងបញ្ចប់ បិទស្លាកបោះត្រាជាសម្គាល់នៅលើកញ្ចប់ និងស្លាកត្រូវកត់ចំណាំប្រភេទ ទម្ងន់នៃវត្ថុដែលនៅខាងក្នុង[76] បន្ទាប់ពីការដកសំណាកហើយ ត្រូវបិទស្លាក ត្រូវបិទស្លាកបោះត្រាឡើងវិញលើបញ្ចប់ដើម និងត្រូវធ្វើកំណត់ហេតុមួយ[77] បញ្ជាក់អំពីចំនួនសំណាកដែលត្រូវបានដកយក ប្រភេទ និងទម្ងន់ នៃវត្ថុដែលសង្ស័យថាជាគ្រឿងញៀនដែលមាននៅក្នុងកញ្ចប់នីមួយៗ ព្រមទាំងការផ្លាស់ប្តូរទៅលើស្លាក និងត្រាដើម ។ កំណត់ហេតុ និងការសរសេរបញ្ជាក់ទាំងអស់លើសំណាកនីមួយៗ និងការបិទស្លាកបោះត្រាដែលបានធ្វើឡើងវិញ ត្រូវចុះអត្តសញ្ញាណ និងហត្ថលេខារបស់បុគ្គលដែលបានចូលរួមក្នុងកិច្ចប្រតិបត្តិការដកសំណាកនេះ ។

**ក. ដីកាចាត់តាំងអ្នកជំនាញ**

បញ្ជីថ្នាក់ជាតិត្រូវបានរៀបចំឡើងដោយរដ្ឋមន្ត្រីក្រសួងយុត្តិធម៌[78] ដែលមានសេចក្តីសម្រេច[79] ចេញដោយក្រសួងយុត្តិធម៌ ហើយការទទួលស្គាល់អ្នកជំនាញធ្វើកោសលវិច័យនេះ ត្រូវបានកំណត់ការទទួលស្គាល់មានរយៈពេល**១ឆ្នាំ** គិតពីថ្ងៃចុះហត្ថលេខាលើសេចក្តីសម្រេច[80] ហើយការស្នើសុំបន្តរបស់អ្នកជំនាញកោសលវិច័យ ត្រូវធ្វើឡើងយ៉ាងយឺតបំផុតក្នុងរយៈពេល១ខែ មុនពេលអស់សុពលភាពនៃសេចក្តីសម្រេចនោះ[81] ។

អ្នកជំនាញត្រូវបានចាត់តាំងដោយចៅក្រមស៊ើបសួរ[82] ។ ដីកាត្រូវបញ្ជាក់អំពីបេសកកម្មរបស់អ្នកជំនាញព្រមទាំងរយៈពេលដែលត្រូវបំពេញបេសកកម្មនេះ ។ បេសកកម្មអាចទាក់ទងទៅនឹងបញ្ហាដែលមានលក្ខណៈបច្ចេកទេសតែប៉ុណ្ណោះ ។ ប្រសិនបើជាការគួរ ចៅក្រមស៊ើបសួរប្រគល់វត្ថុដែលចាប់បានមួយផ្នែក ឬទាំងអស់

[75] ច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ឆ្នាំ២០១១, មាត្រា៨២ កថាខណ្ឌ១
[76] ច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ឆ្នាំ២០១១, មាត្រា៨២ កថាខណ្ឌ២
[77] កំណត់ហេតុស្តីពីការបើក និងបិទសំណាកយកទៅធ្វើកោសលវិច័យ ដូចមានក្នុងឧបសម្ព័ន្ធទី១១
[78] ក្រមនីតិវិធីព្រហ្មទណ្ឌ, មាត្រា១៦៣ កថាខណ្ឌ១ វាក្យខណ្ឌ២ និងច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ឆ្នាំ២០១១, មាត្រា៨២
[79] សេចក្តីសម្រេចស្តីពីការទទួលស្គាល់មន្ត្រីជំនាញក្នុងការធ្វើកោសលវិច័យគ្រឿងញៀន និងសារធាតុញៀនលេខ១០កយ.សសរ/២១ ចុះថ្ងៃទី១៣ ខែមេសា ឆ្នាំ២០២១ របស់ក្រសួងយុត្តិធម៌
[80] ប្រការ២ នៃសេចក្តីសម្រេចស្តីពីការទទួលស្គាល់មន្ត្រីជំនាញក្នុងការធ្វើកោសលវិច័យគ្រឿងញៀន និងសារធាតុញៀនលេខ១០កយ.សសរ/២១ ចុះថ្ងៃទី១៣ ខែមេសា ឆ្នាំ២០២១ របស់ក្រសួងយុត្តិធម៌
[81] សេចក្តីសម្រេចស្តីពីការទទួលស្គាល់មន្ត្រីជំនាញក្នុងការធ្វើកោសលវិច័យគ្រឿងញៀន និងសារធាតុញៀន ដូចមានក្នុងឧបសម្ព័ន្ធទី២៦
[82] ដីកាចាត់តាំងអ្នកជំនាញ ដូចមានក្នុងឧបសម្ព័ន្ធទី១២

នោះជូនអ្នកជំនាញ ។ ចៅក្រមស៊ើបសួរត្រូវធ្វើកំណត់ហេតុស្តីពីការប្រគល់វត្ថុដែលចាប់បាន ហើយអ្នកជំនាញអាចបំបែកស្លាកដែលបិទដើម្បីធ្វើកោសលវិច័យបាន[83] ។

កោសលវិច័យតាមបច្ចេកទេសវិទ្យាសាស្ត្រដោយអ្នកជំនាញ ដែលទទួលស្គាល់ដោយក្រសួងយុត្តិធម៌ ដើម្បីឲ្យបានដឹងអំពីប្រភេទធាតុផ្សំ និងកម្រិតធាតុសកម្មរបស់គ្រឿងញៀនដែលបានដកយកត្រូវធ្វើដោយឆាប់បំផុតបន្ទាប់ពីការដកយក ដើម្បីជៀសវាងការខូចខាត ការថយចុះនូវសារធាតុ រូបធាតុ និងជាតិគីមីនៃវត្ថុនោះ ។ អ្នកជំនាញត្រូវបញ្ជាក់ក្នុងរបាយការណ៍របស់ខ្លួននូវចំនួនសំណាកដែលគេបានប្រគល់ឲ្យ អំពីប្រភេទ និងទម្ងន់នៃគ្រឿងញៀនដែលមានក្នុងសំណាកនីមួយៗ ចំនួនសំណាកដែលបានប្រើប្រាស់ធ្វើកោសលវិច័យ ហើយប្រសិនបើមាន ត្រូវបញ្ជាក់ចំនួនដែលបានប្រមូលមកវិញសល់ពីការធ្វើកោសលវិច័យ និងការប្រែប្រួលទៅលើសំណាកនោះ[84]។

**ខ. អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន**

អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន ជាស្ថាប័នអនុវត្តគោលនយោបាយរបស់រាជរដ្ឋាភិបាល ក្នុងការប្រយុទ្ធប្រឆាំងគ្រឿងញៀន[85]។

អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន ដែលមានអក្សរកាត់ **(អ.ជ.ប.គ.ញ)** ត្រូវបានបង្កើតឡើងដោយព្រះរាជក្រឹត្យលេខ នស/រកត/០៥០៩/៦០៨ ចុះថ្ងៃទី៣០ ខែឧសភា ឆ្នាំ២០០៩ ស្តីពីការរៀបចំ និងប្រព្រឹត្តទៅនៃអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន ដោយក្នុងនោះអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀននេះ មានអគ្គលេខាធិការដ្ឋានមួយជាសេនាធិការ និងគណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀនរាជធានីខេត្តជាខ្សែបណ្តោយ[86] ។ អគ្គលេខាធិការត្រូវនៅក្រោមការដឹកនាំផ្ទាល់របស់អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន ។ ឧបនាយករដ្ឋមន្ត្រី ១រូបជាប្រធានអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន[87]។

អគ្គលេខាធិការដ្ឋានអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន ត្រូវបានបង្កើតដោយអនុក្រឹត្យស្តីពីការរៀបចំ និងប្រព្រឹត្តរបស់អគ្គលេខាធិការដ្ឋាន នៃអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀនលេខ ១៣ អនក្រ.បក ចុះថ្ងៃទី២៦ខែកុម្ភៈ ឆ្នាំ២០០៧ របស់រាជរដ្ឋាភិបាល[88] ។ អនុក្រឹត្យនេះបានកំណត់អំពីតួនាទី មុខងារ សមត្ថកិច្ច

[83] ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧, មាត្រា៨២

[84] ច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ឆ្នាំ២០១១, មាត្រា៨៣

[85] ច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ឆ្នាំ២០១១, មាត្រា៧

[86] ព្រះរាជក្រឹត្យស្តីពីការរៀបចំ និងប្រព្រឹត្តទៅនៃអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន, មាត្រា៣ កថាខណ្ឌ១

[87] ព្រះរាជក្រឹត្យស្តីពីការរៀបចំ និងប្រព្រឹត្តទៅនៃអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន មាត្រា១, ឯកឧត្តម នាយឧត្តមសេនីយ៍ ឧបនាយករដ្ឋមន្ត្រី កែ គឹមយ៉ាន ប្រធានអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន

[88] អនុក្រឹត្យស្តីពីការបង្កើត និងប្រព្រឹត្តទៅនៃអគ្គលេខាធិការអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន ដូចមានក្នុងឧបសម្ព័ន្ធទី១៣

និងរៀបចំរចនាសម្ព័ន្ធរបស់អគ្គលេខាធិការដ្ឋានអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន[89] ។ អគ្គលេខាធិការដ្ឋានអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀនមាននាយកដ្ឋាន និងអង្គភាពដែលមានថ្នាក់ស្មើនាយកដ្ឋានចំនួន០៧ ដែលក្នុងនោះមានមន្ទីរពិសោធន៍គ្រឿងញៀន[90] ដែលជាមន្ទីរពិសោធន៍ ស្វែងរកសារធាតុសុទ្ធលើគ្រឿងញៀន និងសារធាតុគីមីផ្សំដែលជាសារធាតុហាមឃាត់ក្នុងគោលបំណងក្នុងការផលិត ឬផ្សំឡើងជាសារធាតុញៀន ។

មន្ទីរពិសោធន៍គ្រឿងញៀនមានភារកិច្ចក្នុងការវិភាគរកគុណភាព បរិមាណសារធាតុញៀន និងគីមីផ្សំគ្រឿងញៀន ដែលក្រសួង-ស្ថាប័នមានសមត្ថកិច្ចប្រគល់ជូន និងផ្តល់ជូននៃលទ្ធផលនៃការវិភាគនេះវិញ[91]។ ដូចនេះភារកិច្ចរបស់មន្ទីរពិសោធន៍ នៃអគ្គលេខាធិការដ្ឋានអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន មានភារកិច្ចស្វែងរកនូវសារធាតុសុទ្ធ ឬគុណភាព នៃសារធាតុញៀន និងគីមីផ្សំគ្រឿងញៀន ព្រមទាំងផ្តល់នូវលទ្ធផល នៃការពិសោធន៍នេះទៅវិញដល់ក្រសួង ឬស្ថាប័ននោះវិញ។

មានតែមន្ទីរពិសោធន៍ នៃអគ្គលេខាធិការដ្ឋានអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀនទេ ដែលមានសមត្ថកិច្ចក្នុងការស្រាវជ្រាវ វិភាគរកគុណភាព បរិមាណសារធាតុញៀន និងគីមីផ្សំគ្រឿងញៀន ដែលចៅក្រមស៊ើបសួរ នៃសាលាដំបូងណាមួយប្រគល់ជូន ហើយត្រូវផ្តល់នូវលទ្ធផលដែលរកឃើញនោះ ទៅឲ្យចៅក្រមស៊ើបសួរវិញបន្ទាប់ពីបានធ្វើពិសោធន៍ស្វែងរករួចរាល់។

**គ. លទ្ធផលកោសលវិច័យ**

លទ្ធផលកោសលវិច័យលើគ្រឿងញៀន ត្រូវតែចេញដោយមន្ទីរពិសោធន៍ នៃអគ្គលេខាធិការដ្ឋានអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន ដែលមានអ្នកជំនាញធ្វើកោសលវិច័យគ្រឿងញៀន ហើយទទួលស្គាល់ដោយក្រសួងយុត្តិធម៌ ដូចមានក្នុងសេចក្តីសម្រេចស្តីពីការទទួលស្គាល់មន្ត្រីជំនាញក្នុងការធ្វើកោសលវិច័យគ្រឿងញៀន និងសារធាតុញៀនលេខ ១០កយ.សសរ/២១ ចុះថ្ងៃទី១៣ ខែមេសា ឆ្នាំ២០២១ របស់ក្រសួងយុត្តិធម៌ ។

កាលណាការធ្វើកោសលវិច័យត្រូវបានបញ្ចប់ អ្នកជំនាញធ្វើរបាយការណ៍ដែលនៅក្នុងនោះ ដោយត្រូវពណ៌នាយ៉ាងច្បាស់អំពីប្រតិបត្តិការរបស់ខ្លួន និងធ្វើសេចក្តីសន្និដ្ឋាន ។ អ្នកជំនាញត្រូវបញ្ជាក់ថាបានធ្វើដោយផ្ទាល់ខ្លួននូវប្រតិបត្តិការដែលពណ៌នានៅក្នុងរបាយការណ៍ ដោយរបាយការណ៍ត្រូវចុះកាលបរិច្ឆេទ និងចុះហត្ថលេខា[92] ។

[89] អនុក្រឹត្យស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់អគ្គលេខាធិការដ្ឋាន នៃអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន, មាត្រា១

[90] អនុក្រឹត្យស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់អគ្គលេខាធិការដ្ឋាន នៃអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន, មាត្រា៤ ចំណុច៧

[91] អនុក្រឹត្យស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់អគ្គលេខាធិការដ្ឋាន នៃអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន, មាត្រា១៣ ចំណុច២

[92] ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧, មាត្រា១៦៨ កថាខណ្ឌ១

លទ្ធផលកោសលវិច័យលើគ្រឿងញៀន ត្រូវបញ្ជាក់ពីភាគរយនៃសារធាតុសុទ្ធលើគ្រឿងញៀននោះ និង បញ្ជាក់អំពីចំណាត់ថ្នាក់នៃគ្រឿងញៀន ដោយកំណត់ថាគ្រឿងញៀននោះស្ថិតនៅក្នុងតារាងនៃចំណាត់ថ្នាក់ណាមួយនៃគ្រឿងញៀន។

អ្នកជំនាញត្រូវបញ្ជាក់ក្នុងរបាយការណ៍របស់ខ្លួននូវចំនួនសំណាកដែលគេបានប្រគល់ឲ្យ អំពីប្រភេទ និងទម្ងន់នៃគ្រឿងញៀនដែលមានក្នុងសំណាកនីមួយៗ ចំនួនសំណាកដែលបានប្រើប្រាស់ធ្វើកោសលវិច័យ ហើយប្រសិនបើមាន ត្រូវបញ្ជាក់ចំនួនដែលបានប្រមូលមកវិញសល់ពីការធ្វើកោសលវិច័យ និងការប្រែប្រួលទៅលើសំណាកនោះ[93]។

**ឃ. ចំណាត់ថ្នាក់គ្រឿងញៀន**

គ្រឿងញៀនត្រូវបានគេធ្វើចំណាត់ថ្នាក់[94] ដើម្បីអាចកំណត់ឲ្យបាននូវប្រភេទនៃរុក្ខជាតិ សារធាតុគីមីផ្សំ និងសារធាតុញៀនដែលមានលក្ខណៈបណ្តាលឲ្យមានគ្រោះថ្នាក់ ឬគ្រោះថ្នាក់ធ្ងន់ធ្ងរ និងប្រភេទណាដែលមានប្រយោជន៍ខាងវេជ្ជសាស្ត្រ ឬគ្មានប្រយោជន៍ខាងវេជ្ជសាស្ត្រ ។ ដោយយល់ឃើញដូចនេះហើយ ទើបប្រភេទ នៃរុក្ខជាតិមួយចំនួននៅបណ្តារប្រទេសមួយចំនួន ដោយមានការមើលឃើញនូវប្រយោជន៍ និងពុំមានគ្រោះថ្នាក់ធ្ងន់ធ្ងរ រាជរដ្ឋាភិបាលនៃប្រទេសនោះអនុញ្ញាតឲ្យមានការដាំដុះ ដើម្បីជាប្រយោជន៍ ប៉ុន្តែត្រូវស្ថិតនៅក្រោមច្បាប់ ដោយការដាំដុះមានលក្ខណៈគ្រួសារ ឬមានបរិមាណតិចតួចប៉ុណ្ណោះ។

គ្រឿងញៀនត្រូវបានធ្វើចំណាត់ថ្នាក់ដូចខាងក្រោម[95]៖

<u>តារាងទី១៖</u> រុក្ខជាតិ និងសារធាតុញៀនដែលបណ្តាលឲ្យ**មានគ្រោះថ្នាក់ធ្ងន់ធ្ងរ** ហើយ**ពុំមានផលប្រយោជន៍ខាងវេជ្ជសាស្ត្រ**។

<u>តារាងទី២៖</u> រុក្ខជាតិ និងសារធាតុញៀនដែលបណ្តាលឲ្យ**មានគ្រោះថ្នាក់ធ្ងន់ធ្ងរ** ប៉ុន្តែ**មានផលប្រយោជន៍ខាងវេជ្ជសាស្ត្រ**។

<u>តារាងទី៣៖</u> រុក្ខជាតិ និងសារធាតុញៀនដែលបណ្តាលឲ្យ**មានគ្រោះថ្នាក់** ប៉ុន្តែ**មានផលប្រយោជន៍ខាងវេជ្ជសាស្ត្រ**។

<u>តារាងទី៤៖</u> សារធាតុគីមីផ្សំទាំងឡាយ ដែលបានចាត់ថ្នាក់ក្នុងអនុសញ្ញារបស់អង្គការសហប្រជាជាតិប្រឆាំងនឹងការចរាចរគ្រឿងញៀនខុសច្បាប់ និងសារធាតុដែលធ្វើឲ្យប៉ះពាល់ប្រព័ន្ធសរសៃប្រសាទឆ្នាំ

[93] ច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ឆ្នាំ២០១១, មាត្រា៨៣ វាក្យខណ្ឌ២

[94] ចំណាត់ថ្នាក់នៃគ្រឿងញៀន ដូចមានក្នុងឧបសម្ព័ន្ធទី១៤

[95] ច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ឆ្នាំ២០១១, មាត្រា៥, ក្នុងតារាងនីមួយៗមានចែងលំអិតនៅក្នុងឧបសម្ព័ន្ធនៃច្បាប់នេះ។

១៩៨៨ ឬក្នុងការអនុវត្តអនុសញ្ញានេះប្រឆាំងនឹងការចរាចរគ្រឿងញៀនខុសច្បាប់ ។ ក្នុងតារាងទី៤ នៃ ត្រូវបានបែងចែកជា២បន្ថែមទៀត។

**កថាខណ្ឌទី២៖ ការប្រគល់វត្ថុឲ្យទៅម្ចាស់ដើមវិញ**

ការប្រគល់វត្ថុដែលចាប់យកឲ្យទៅម្ចាស់ដើមវិញ អាចធ្វើទៅបានប្រសិនបើការប្រគល់នោះមិនប៉ះពាល់ដល់នីតិវិធីនៃការស៊ើបសួរ ចៅក្រមស៊ើបសួរត្រូវសុំយោបល់របស់តំណាងអយ្យការ ចំពោះពាក្យស្នើសុំវត្ថុដែលចាប់យកនោះ ដោយការសម្រេចអំពីការប្រគល់ ឬមិនប្រគល់វត្ថុដែលចាប់យកនេះ អ្នកដាក់ពាក្យសុំអាចប្ដឹងទៅសភាស៊ើបសួរ នៃសាលាឧទ្ធរណ៍ ដែលមានសមត្ថកិច្ច ចំពោះដីកាសម្រេចមិនប្រគល់វត្ថុដែលចាប់យកឲ្យទៅម្ចាស់ដើមវិញ ក្នុងរយៈពេល០៥ថ្ងៃ គិតចាប់ពីថ្ងៃទទួលដំណឹងអំពីដីកាសម្រេចមិនប្រគល់វត្ថុនេះ។

**ក. ការប្រគល់វត្ថុដែលចាប់យកឲ្យទៅម្ចាស់ដើមវិញ**

ការប្រគល់វត្ថុដែលចាប់យកឲ្យទៅម្ចាស់ដើមវិញដោយចៅក្រមស៊ើបសួរ ប្រសិនបើមិនទាន់ចេញដីកាដំណោះស្រាយនៅឡើយទេ ចៅក្រមស៊ើបសួរមានសមត្ថកិច្ចក្នុងការប្រគល់សងវត្ថុដែលចាប់យកទៅម្ចាស់ដើមវិញ កាលណាកម្មសិទ្ធិនេះគ្មានការជំទាស់អ្វីប្រាកដប្រជាទេ ។ ចៅក្រមស៊ើបសួរសម្រេចតាមដីកាដែលមានសំអាងហេតុ ក្រោយពីបានទទួលយោបល់ពីតំណាងអយ្យការ ។ ដីកាសម្រេចត្រូវឲ្យដំណឹងជាបន្ទាន់ទៅអ្នកប្ដឹង និងមេធាវីនៃអ្នកប្ដឹងប្រសិនបើមាន ។ មិនគួរប្រគល់សងទៅអ្នកប្ដឹងសុំទេកាលណាវិធានការនេះអាចបង្កជាឧបសគ្គ ដល់ការសំដែងឲ្យឃើញការពិត ។ វត្ថុដែលមានគ្រោះថ្នាក់ដល់បុគ្គល ឬទ្រព្យសម្បត្តិដូចជាអាវុធ ឬជាតិផ្ទុះព្រមទាំងវត្ថុដែលការកាន់កាប់មិនស្របច្បាប់ មិនអាចត្រូវប្រគល់សងទៅឲ្យសាមីខ្លួនបានទេ ។ វត្ថុទាំងនេះត្រូវរឹបអូស ជាកម្មសិទ្ធិរបស់រដ្ឋ[96] ។ ចំពោះបទរក្សាទុក ដឹកជញ្ជូន ឬជួញដូរដោយខុសច្បាប់នូវសារធាតុញៀន ចៅក្រមស៊ើបសួរអាចពិនិត្យថា ការប្រគល់វត្ថុដែលចាប់យកនោះបណ្ដាលឲ្យមានផលប៉ះពាល់ដល់ការស៊ើបសួរ ឬមិនមានការប៉ះពាល់ ឬមានមូលដ្ឋានត្រឹមត្រូវទេក្នុងការប្រគល់វត្ថុដែលចាប់យក ។ វត្ថុដែលចាប់យកក្នុងបទល្មើសនេះយើងអាចកំណត់បានថាជាមធ្យោបាយក្នុងការប្រព្រឹត្តបទល្មើស ប៉ុន្តែកម្មសិទ្ធិករ នៃវត្ថុនោះអាចមិនមែនជាអ្នកដែលចូលរួម ឬផ្ដល់មធ្យោបាយក្នុងការប្រព្រឹត្តបទល្មើសទេ ដូចនេះការសម្រេចប្រគល់វត្ថុដែលចាប់យកឲ្យទៅម្ចាស់ដើមវិញ របស់ចៅក្រមស៊ើបសួរត្រូវមានសំអាងហេតុរួមទាំងភស្តុតាងដែលអះអាងដោយអ្នកដាក់ពាក្យសុំ ហើយត្រូវទទួលយោបល់របស់តំណាងអយ្យការ ក្នុងការប្រគល់វត្ថុដែលចាប់យកនេះ ។ វត្ថុចាប់យកដែលជាចលនវត្ថុដែលមានដូចជារថយន្ត ម៉ូតូ កង់ ទូរស័ព្ទ គ្រឿងអលង្ការ និងសម្ភារៈផ្សេងទៀតដែលការប្រគល់សម្ភារៈទាំងនោះ ត្រូវតែមិនបានផលប៉ះពាល់ដល់ការស៊ើបសួរឡើយ។

[96] ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧, មាត្រា១៦១

**ខ. ការប្រគល់ និងបើកទីតាំងវិញ**

ក្នុងករណីទីតាំងដែលប្រព្រឹត្តបទល្មើសត្រូវបានបិទ ដោយមានការអនុញ្ញាតពីតំណាងអយ្យការនោះ ទីតាំងដែលប្រព្រឹត្តបទល្មើសនោះ ពុំត្រូវឲ្យមានអ្នកចេញចូល ឬបើកដំណើរការឡើយ ។ ផ្ទុយទៅវិញទីតាំងនោះ ត្រូវបិទជាបណ្តោះអាសន្នរង់ចាំការសម្រេចរបស់តុលាការ ឬដោយការដាក់ពាក្យស្នើសុំបើកទីតាំងនោះឡើងវិញ ដោយចៅក្រមស៊ើបសួរអាចសម្រេចអំពីការបើក ឬមិនបើកទីតាំងនោះបានដោយមានការផ្តល់យោបល់ពីព្រះរាជអាជ្ញា ។ ចៅក្រមស៊ើបសួរមានសមត្ថកិច្ចក្នុងការអនុញ្ញាតឲ្យបើកទីតាំងឡើងវិញ ប្រសិនបើយល់ឃើញថាការបិទទីតាំងនេះមានផលប៉ះពាល់ខ្លាំងដល់ម្ចាស់ទីតាំង ហើយការបិទទីតាំងនោះមិនមានផលប្រយោជន៍ និងមិនប៉ះពាល់ដល់ការស៊ើបសួរ ។ ចៅក្រមស៊ើបសួរសម្រេចបើកទីតាំងដែលបានបិទនោះតាមរយៈដីកាសម្រេច ឬតាមរយៈដីកាដំណោះស្រាយដែលជាកិច្ចសម្រេចចុងក្រោយរបស់ខ្លួន[97] ។ បន្ទាប់ពីចៅក្រមទទួលបានពាក្យស្នើសុំបើកទីតាំងនេះចៅក្រមស៊ើបសួរអាចសម្រេចអំពីការបើក ឬសម្រេចអំពីការបដិសេធលើពាក្យស្នើសុំបើកទីតាំងនេះ ហើយប្រសិនមានការសម្រេចអនុញ្ញាតឲ្យប្រគល់ និងបើកទីតាំងឡើងវិញ នោះសមាសភាពដែលចូលរួមក្នុងការបិទទីតាំងនោះ ត្រូវតែជាសមាសភាពដើម្បីចូលរួមក្នុងការបើកទីតាំងឡើងវិញផងដែរ ក្នុងករណីចៅក្រមស៊ើបសួរសម្រេចមិនអនុញ្ញាឲ្យបើកទីតាំងវិញទេ បើទោះជានោះអ្នកដាក់ពាក្យស្នើសុំមិនមែនភាគីក្នុងសំណុំរឿងក៏ដោយក៏អ្នកដាក់ពាក្យស្នើសុំនោះមានសិទ្ធិក្នុងការប្តឹងទៅសភាស៊ើបសួរ នៃសាលាឧទ្ធរណ៍ចំពោះដីកាសម្រេចបដិសេធក្នុងការបើកទីតាំងរបស់ចៅក្រមស៊ើបសួរក្នុងរយៈពេល០៥ថ្ងៃ គិតចាប់ពីថ្ងៃទទួលបានដំណឹងពីដីកាសម្រេចបដិសេធពាក្យសុំនោះ[98] ។ ផ្ទុយទៅវិញក្នុងករណីចៅក្រមស៊ើបសួរមិនបានសម្រេច ឬដោយផុតសមត្ថកិច្ចដោយចេញដីកាដំណោះស្រាយរួចហើយ នោះការសម្រេចអំពីការប្រគល់ ឬមិនប្រគល់ ទីតាំងនោះ ត្រូវស្ថិតនៅក្រោមសមត្ថកិច្ចរបស់តុលាការជំនុំជម្រះ ដោយការសម្រេចនេះត្រូវសម្រេចនៅក្នុងសាលក្រមព្រហ្មទណ្ឌ ។

**កថាខណ្ឌទី៣៖ ការស្រាវជ្រាវ**

ចៅក្រមស៊ើបសួរអាចបំពេញកិច្ចស៊ើបសួររបស់ខ្លួន ដោយការចុះដល់ទីកន្លែងកើតហេតុដោយចៅក្រមស៊ើបសួរ រួមជាមួយក្រឡាបញ្ជី ឬបំពេញកិច្ចនេះតាមរយៈដីកាចាត់ឲ្យស៊ើបសួរជំនួសដោយប្រគល់សិទ្ធិឲ្យមន្ត្រីនគរបាលយុត្តិធម៌ជាអ្នកស៊ើបសួរជំនួស ឬចៅក្រមស៊ើបសួរណាមួយជាអ្នកស៊ើបសួរជំនួសខ្លួន ។ ប៉ុន្តែយ៉ាងណាមិញ ផ្អែកតាមស្ថានភាពបច្ចុប្បន្ន រួមជាមួយនិងកាលៈទេសៈចៅក្រមស៊ើបសួរអាចសុំឲ្យមន្ត្រីនគរបាលយុត្តិធម៌ជាអ្នកមានសមត្ថកិច្ច ឬសុំឲ្យចៅក្រមស៊ើបសួរនៃសាលាដំបូងផ្សេង ជាអ្នកស៊ើបសួរជំនួសនូវកិច្ចខ្លះ

[97] ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧, មាត្រា២៤៨

[98] ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧, មាត្រា២៧០ កថាខណ្ឌ៣

ដែលមានបញ្ជាក់ក្នុងដីកាចាត់ឲ្យស៊ើបសួរជំនួស[99] ចៅក្រមស៊ើបសួរអាចស្វែងរកលើអញ្ញាតជន ឬជនត្រូវចោទដែលត្រូវបានគេចខ្លួនដោយពុំមានសាវតាច្បាស់លាស់ ។

**ក. ការស៊ើបសួរដោយចៅក្រមស៊ើបសួរ**

ចៅក្រមស៊ើបសួរអាចចុះដល់ទីកន្លែងកើតហេតុ និងទីកន្លែងដែលមានតម្រុយ ជាមួយក្រឡាបញ្ជីរបស់ខ្លួននៅលើវិសាលភាពនៃសមត្ថកិច្ច នៃតុលាការជាន់ដំបូង ដើម្បីបំពេញកិច្ចស៊ើបសួរដែលខ្លួនយល់ឃើញថាមានប្រយោជន៍ជាអាទិ៍ ការពិនិត្យសម្ភារៈ ការឆែកឆេរ និងការចាប់យកវត្ថុតាង[100] ។ ចៅក្រមស៊ើបសួរអាចចុះទៅដល់ទីតាំងដោយមានអមដោយក្រឡាបញ្ជី ដោយធ្វើកិច្ចស៊ើបសួរដោយខ្លួនឯង ចំពោះបទល្មើសរក្សាទុក ដឹកជញ្ជូន ឬជួញដូរដោយខុសច្បាប់នូវសារធាតុញៀន ចៅក្រមស៊ើបសួរអាចពិនិត្យលើមធ្យោបាយក្នុងការដឹកជញ្ជូន ឬពិនិត្យលើសកម្មភាពនៃការជួញដូរដោយខុសច្បាប់នូវសារធាតុញៀនទាំងនោះ ប្រសិនបើចៅក្រមយល់ឃើញថាមានប្រយោជន៍ ចៅក្រមស៊ើបសួរអាច យកជាភស្តុតាងក្នុងការដាក់បន្ទុក ឬដោះបន្ទុកអាស្រ័យលើភស្តុតាងដែលចៅក្រមស៊ើបសួរអាចរកបាន ។

ចៅក្រមស៊ើបសួរត្រូវជូនដំណឹងទៅព្រះរាជអាជ្ញាអំពីការចុះទៅពិនិត្យនេះ ។ ក្នុងករណីនេះព្រះរាជអាជ្ញាអាចរួមដំណើរជាមួយចៅក្រមស៊ើបសួរបាន[101] ។

ប្រសិនបើការចាំបាច់ នៃការស៊ើបសួរតម្រូវ ចៅក្រមស៊ើបសួរអាចចុះទៅទីកន្លែងជាមួយក្រឡាបញ្ជី និងលើវិសាលភាពដែនដីជាតិទាំងមូល ប៉ុន្តែចៅក្រមត្រូវជូនដំណឹងជាមុនដល់ព្រះរាជអាជ្ញាអមតុលាការជាន់ដំបូងនៅក្នុងដែនដីដែលខ្លួនបានធ្វើដំណើរទៅកាន់នោះ [102]។ ឧទាហរណ៍ ចៅក្រមស៊ើបសួរនៃសាលាដំបូងខេត្តកណ្តាល អាចចុះទៅទីតាំងដែលនៅក្នុងរាជធានីភ្នំពេញ ចង្អុលបង្ហាញក្នុងអង្គហេតុដោយចៅក្រមស៊ើបសួរត្រូវជូនដំណឹងដល់ព្រះរាជអាជ្ញានៃអយ្យការអមសាលាដំបូងរាជធានីភ្នំពេញឲ្យបានជ្រាបជាមុន ។

ចៅក្រមស៊ើបសួរត្រូវធ្វើកំណត់ហេតុស្តីពីប្រតិបត្តិការរបស់ខ្លួន[103] កំណត់ហេតុនេះត្រូវយកជាសំអាងហេតុក្នុងការស៊ើបសួររបស់ចៅក្រមស៊ើបសួរ។

**ខ. ការចាត់ឲ្យស៊ើបសួរជំនួស**

ចៅក្រមស៊ើបសួរអាចស្នើឲ្យចៅក្រមស៊ើបសួរផ្សេងក្នុងករណីដែលជនត្រូវចោទនោះមិនស្ថិតនៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួន ឬមន្ត្រីនគរបាលយុត្តិធម៌ ឬអង្គភាពនគរបាលយុត្តិធម៌ បំពេញកិច្ចខ្លះតាមរយៈដីកាចាត់ឲ្យ

---

[99] ឯកឧត្តម កើត រិទ្ធ រដ្ឋមន្ត្រីក្រសួងយុត្តិធម៌

[100] ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧, មាត្រា១៣០ កថាខណ្ឌ១

[101] ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧, មាត្រា១៣០ កថាខណ្ឌ២

[102] ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧, មាត្រា១៣០ កថាខណ្ឌ៣

[103] ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧, មាត្រា១៣០ កថាខណ្ឌ៤

ស៊ើបសួរជំនួស[104] ។ ដីកាចាត់ឲ្យស៊ើបសួរជំនួស[105] បញ្ជាក់អំពីប្រភេទនៃកិច្ចដែលត្រូវធ្វើកិច្ចនោះត្រូវតែមានទំនាក់ទំនងដោយផ្ទាល់ជាមួយបទល្មើសដែលចោទប្រកាន់ ហើយដីកាចាត់ឲ្យស៊ើបសួរជំនួសមិនអាចមានលក្ខណៈទូទៅទេ ត្រូវណែនាំឲ្យបានច្បាស់លាស់ និងកំណត់អំពីថេរវេលាដែលត្រូវអនុវត្តដីកានេះ[106] ។ ចៅក្រមស៊ើបសួរ មន្ត្រីនគរបាលយុត្តិធម៌ ឬអង្គភាពនគរបាលយុត្តិធម៌ បន្ទាប់ពីបំពេញកិច្ចក្នុងការស៊ើបសួរចប់ត្រូវផ្តល់នូវលទ្ធផលនៃការស៊ើបសួរនោះ មកឲ្យចៅក្រមស៊ើបសួរឲ្យបានទាន់ពេលវេលាដើម្បីចាត់ការបន្តតាមនីតិវិធី ។

ដីកាចាត់ឲ្យស៊ើបសួរជំនួសរបស់ចៅក្រមស៊ើបសួរ ត្រូវកំណត់អំពីកិច្ចណាមួយដែលប្រគល់ឲ្យចៅក្រមស៊ើបសួរផ្សេង មន្ត្រីនគរបាលយុត្តិធម៌ ឬអង្គភាពមន្ត្រីនគរបាលយុត្តិធម៌ ដែលត្រូវបំពេញ ហើយកិច្ចនោះត្រូវតែជាប់ពាក់ព័ន្ធជាមួយនឹងអង្គហេតុដែលតំណាងអយ្យការបានចោទប្រកាន់លើជនត្រូវចោទ ដោយមិនត្រូវធ្វើការស៊ើបសួរចំពោះអង្គហេតុណាមួយមិនពាក់ព័ន្ធ និងចង្អុលបង្ហាញដោយដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ[107] ឬដីកាស្នើសុំឲ្យបំពេញកិច្ចស៊ើបសួរបន្ថែមរបស់តំណាងអយ្យការឡើយ ។ ចំពោះការអនុវត្តដីកាចាត់ឲ្យស៊ើបសួរជំនួសមន្ត្រីនគរបាលយុត្តិធម៌ស្ថិតនៅក្រោមអំណាចចៅក្រមស៊ើបសួរ ហើយត្រូវរាយការណ៍ជូនទៅចៅក្រមស៊ើបសួរតែប៉ុណ្ណោះ[108] ។

ចៅក្រមស៊ើបសួរអាចស្នើឲ្យចៅក្រមស៊ើបសួរផ្សេង ឬមន្ត្រីនគរបាលយុត្តិធម៌ ឬអង្គភាពនគរបាលយុត្តិធម៌ បំពេញកិច្ចមួយចំនួនចំពោះបទល្មើសរក្សាទុក ដឹកជញ្ជូន ឬជួញដូរដោយខុសច្បាប់នូវសារធាតុញៀន។ ឧទាហរណ៍ ស្រាវជ្រាវសាវតារ ឬអត្តសញ្ញាណជនត្រូវចោទដែលត្រូវបានគេចខ្លួន ឬស្វែងរកអត្តសញ្ញាណលើម្ចាស់វត្ថុដែលចាប់យក រួមមានស្លាកលេខម៉ូតូ រថយន្ត លេខទូរស័ព្ទ ប្រព័ន្ធសង្គម ឬបណ្តាញទំនាក់ទំនងផ្សេង ។

**កថាខណ្ឌទី៤៖ វិធានការនិរន្តរាយ**

ចៅក្រមស៊ើបសួរអាចចេញដីកាបង្គាប់ឲ្យចូលខ្លួន ដីកាបង្គាប់ឲ្យនាំខ្លួន ដីកាបង្គាប់ឲ្យចាប់ខ្លួន និងដីកាបង្គាប់ឲ្យឃុំខ្លួន[109] ។ ចំពោះបទល្មើសរក្សាទុក ដឹកជញ្ជូន ឬជួញដូរដោយខុសច្បាប់នូវសារធាតុញៀន ប្រសិនបើ ចៅក្រមស្វែងរក និងកំណត់បាននូវអត្តសញ្ញាណរបស់ជនត្រូវចោទណាមួយដែលមិនទាន់បានឃាត់ខ្លួនទេ ចៅក្រមស៊ើបសួរអាចចេញដីកាបង្គាប់ឲ្យចូលខ្លួន ឬដីកាបង្គាប់ឲ្យនាំខ្លួន ឬដីកាបង្គាប់ឲ្យចាប់ខ្លួន ប្រសិនបើបទល្មើសនោះជាបទមជ្ឈិម ឬបទឧក្រិដ្ឋ ដែលត្រូវផ្តន្ទាទោសដាក់ពន្ធនាគារ ។ ដីកានេះបង្គាប់ដល់

[104] ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧, មាត្រា១៣១ និងមាត្រា១៧៣
[105] ដីកាចាត់ឲ្យស៊ើបសួរជំនួស ដូចមានក្នុងឧបសម្ព័ន្ធទី១០
[106] ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧, មាត្រា១៧៤
[107] ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧, មាត្រា១២៤ កថាខណ្ឌ៣
[108] ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧, មាត្រា១៧៦ កថាខណ្ឌ២
[109] ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧, មាត្រា១៨៥

ជនត្រូវចោទដើម្បីបង្ហាញខ្លួននៅចំពោះមុខចៅក្រមស៊ើបសួរក្នុងគោលបំណងស្វែងរកការពិត ។ ចៅក្រមអាចចេញដីកាបង្គាប់ឲ្យចាប់ខ្លួនលើជនត្រូវចោទណាមួយដែលគេចខ្លួន ហើយត្រូវបានគេកំណត់បាននូវសាវតារជាតិរបស់ជននោះ ។

គ្មានជនណាម្នាក់ត្រូវបានចាប់ខ្លួន ឃុំខ្លួន ឬនិរទេសខ្លួនដោយបំពានឡើយ[110] ដូចគ្នានេះដែរ ចៅក្រមស៊ើបសួរអាចចេញដីកាបង្គាប់ឲ្យចាប់ខ្លួន ឬដីកាបង្គាប់ឲ្យឃុំខ្លួនទៅលើជនត្រូវចោទណាដែលត្រូវបានចោទប្រកាន់ពីបទល្មើសព្រហ្មទណ្ឌណាមួយដោយព្រះរាជអាជ្ញា ព្រមទាំងមានភស្តុតាងដាក់បន្ទុកគ្រប់គ្រាន់ក្នុងការកំណត់ថាជននោះពិតជាមានពិរុទ្ធភាព ។

### គ. ដីកាបង្គាប់ឲ្យចូលខ្លួន

ដីកាបង្គាប់ឲ្យចូលខ្លួនគឺជាដីកាចេញដោយចៅក្រមស៊ើបសួរ នៃសាលាដំបូងណាមួយ ដែលមានគោលបំណងបញ្ជាដល់បុគ្គលណាម្នាក់ឲ្យចូលទៅបង្ហាញខ្លួននៅមុខចៅក្រមស៊ើបសួរ ដោយដីកានេះអាចចេញទៅលើជនត្រូវចោទ ឬទៅលើបុគ្គលណាម្នាក់ដែលមានតម្រុយពិរុទ្ធតែប៉ុណ្ណោះ[111] ។ ដីកានេះត្រូវជូនដំណឹងដោយមន្ត្រីនគរបាលយុត្តិធម៌ ភ្នាក់ងារនគរបាលយុត្តិធម៌ ឬដោយអាជ្ញាសាលា ដោយទុកចុងដីកាឲ្យទៅជនត្រូវចោទ និងត្រូវចុះហត្ថលេខាលើដើមដីកាសម្រាប់បង្វិលជូនចៅក្រមស៊ើបសួរវិញ[112] ។ មន្ត្រីនគរបាលយុត្តិធម៌ ភ្នាក់ងារនគរបាលយុត្តិធម៌ ឬដោយអាជ្ញាសាលាត្រូវរាយការណ៍អំពីការលំបាករបស់ខ្លួនក្នុងការបញ្ជូនដីកា ឬការលំបាកក្នុងបេសកម្មរបស់ខ្លួន ។

ដីកាបង្គាប់ឲ្យចូលខ្លួនត្រូវមាននិទ្ទេសដូចខាងក្រោម[113]៖

-អត្តសញ្ញាណនៃបុគ្គលដែលពាក់ព័ន្ធ

-ថ្ងៃ ខែ ឆ្នាំ ម៉ោង និងទីកន្លែងដែលត្រូវចូលបង្ហាញខ្លួននៅមុខចៅក្រមស៊ើបសួរ

-ឈ្មោះ ឋានៈ ចៅក្រមដែលចេញដីកា។

ដីកាបង្គាប់ឲ្យចូលខ្លួន មានអានុភាពបង្គាប់ឲ្យជនត្រូវចោទ ឬជនដែលមានតម្រុយពិរុទ្ធ ឲ្យចូលមកបង្ហាញខ្លួនចំពោះមុខចៅក្រមស៊ើបសួរ ក្នុងគោលបំណងសាកសួរ ហើយប្រសិនបើចៅក្រមយល់ឃើញថាមានបទល្មើស ចៅក្រមស៊ើបសួរអាចសម្រេចឃុំខ្លួនលើជនត្រូវចោទរូបនោះ ។

[110] សេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស អនុម័តដោយមហាសន្និបាតអង្គការសហប្រជាជាតិ ឆ្នាំ១៩៤៨, មាត្រា៩

[111] ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧, មាត្រា១៨៦

[112] ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧, មាត្រា១៨៨

[113] ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧, មាត្រា១៨៧

**ខ. ដីកាបង្គាប់ឲ្យនាំខ្លួន**

ដីកាបង្គាប់ឲ្យនាំខ្លួនត្រូវបានចេញដោយចៅក្រមស៊ើបសួរ[114] ដីកានេះគឺបញ្ជាដល់កងកម្លាំងសាធារណៈឲ្យចាប់ និងនាំខ្លួនបុគ្គលណាម្នាក់ទៅចំពោះមុខចៅក្រមស៊ើបសួរ[115] ។ ដីកាបង្គាប់ឲ្យនាំខ្លួនត្រូវប្រគល់ឲ្យមន្ត្រីនគរបាលយុត្តិធម៌ជាអ្នកអនុវត្តដីកា[116] ។ ដីកាបង្គាប់ឲ្យនាំខ្លួនត្រូវផ្សព្វផ្សាយដល់អង្គភាពនគរបាល ឬកងរាជអាវុធហត្ថតាមគ្រប់មធ្យោបាយ ដើមដីកានេះត្រូវប្រគល់ជូនជាបន្ទាន់ដល់មន្ត្រីនគរបាលយុត្តិធម៌ដែលទទួលបន្ទុកអនុវត្តដីកានេះ ។ មន្ត្រីនគរបាលយុត្តិធម៌មិនអាចចូលទៅលំនៅដ្ឋានរបស់ជនត្រូវចោទនៅមុនម៉ោង ០៦ព្រឹក និងក្រោយម៉ោង១៨ បានទេ[117] មន្ត្រីនគរបាលយុត្តិធម៌ត្រូវឲ្យដំណឹងដល់ចៅក្រមស៊ើបសួរ អំពីការលំបាកទាំងអស់ក្នុងពេលអនុវត្តបេសកកម្មរបស់ខ្លួន ។

ចៅក្រមស៊ើបសួរអាចចេញដីកាបង្គាប់ឲ្យនាំខ្លួនចំពោះសាក្សីដែលជាសាក្សីសំខាន់ ដែលព្យាយាមគេចវេសមិនចូលរួមក្នុងនីតិវិធីរបស់តុលាការនៅក្នុងរឿងព្រហ្មទណ្ឌ។

ប្រសិនបើដោយមូលហេតុនៃកាលៈទេសៈ បុគ្គលដែលពាក់ព័ន្ធមិនអាចត្រូវនាំទៅបង្ហាញខ្លួនដល់ចៅក្រមស៊ើបសួរក្រោយពេលចាប់ខ្លួនបានទេ បុគ្គលនេះត្រូវតែនាំខ្លួនទៅក្នុងអង្គភាពនគរបាល ឬកងរាជអាវុធហត្ថទៅក្នុងមណ្ឌលឃុំខ្លួន ឬទៅក្នុងពន្ធនាគារ ។ បុគ្គលនេះត្រូវតែនាំខ្លួនទៅបង្ហាញខ្លួនយ៉ាងយូរបំផុតថ្ងៃបន្ទាប់ដល់ចៅក្រមស៊ើបសួរ ឬដល់អ្នកជំនួស ។ ប្រសិនបើការបង្ហាញខ្លួនមិនបានប្រព្រឹត្តទៅនៅថ្ងៃបន្ទាប់ទេ បុគ្គលពាក់ព័ន្ធត្រូវបានដោះលែងឲ្យមានសេរីភាពវិញ[118] ។

ដីកាបង្គាប់ឲ្យនាំខ្លួនត្រូវមាននិទ្ទេសដូចខាងក្រោមៈ

-អត្តសញ្ញាណនៃបុគ្គលដែលពាក់ព័ន្ធ

-ថ្ងៃ ខែ ឆ្នាំ ម៉ោង និងទីកន្លែងដែលត្រូវចូលបង្ហាញខ្លួននៅមុខចៅក្រមស៊ើបសួរ

-ឈ្មោះ ឋានៈ ចៅក្រមដែលចេញដីកា។

**គ. ដីកាបង្គាប់ឲ្យចាប់ខ្លួន**

ចៅក្រមស៊ើបសួរអាចចេញដីកាបង្គាប់ឲ្យចាប់ខ្លួន[119] ប្រសិនបើយល់ឃើញថាជនត្រូវចោទបានប្រព្រឹត្តបទល្មើសរក្សាទុក ដឹកជញ្ជូន ឬជួញដូរដោយខុសច្បាប់នូវសារធាតុញៀន ។ ដីកាបង្គាប់ឲ្យចាប់ខ្លួនអាចត្រូវ

[114] ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧, មាត្រា១៨៩

[115] ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧, មាត្រា១៩០

[116] ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧, មាត្រា១៩២ កថាខណ្ឌ១

[117] ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧, មាត្រា១៩២ កថាខណ្ឌ២ វាក្យខណ្ឌ៣

[118] ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧, មាត្រា១៩៣

[119] ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧, មាត្រា១៩៥

ចេញទៅលើជនត្រូវចោទ ឬបុគ្គលណាម្នាក់ដែលមានតម្រុយពិរុទ្ធភាព[120] ។ ដីកាបង្គាប់ឲ្យចាប់ខ្លួន គឺបញ្ជាដល់កងកម្លាំងសាធារណៈឲ្យស្រាវជ្រាវចាប់ និងនាំខ្លួនបុគ្គលនោះទៅពន្ធនាគារ ឬមណ្ឌលឃុំខ្លួន និងដល់ប្រធានពន្ធនាគារ ឬមណ្ឌលឃុំខ្លួនឲ្យទទួល និងឃុំខ្លួនបុគ្គលនោះ[121] ។

ដីកាបង្គាប់ឲ្យចាប់ខ្លួនត្រូវបានចេញលុះត្រាតែមានមូលហេតុដូចខាងក្រោម[122] ៖

-បទល្មើសដែលបានចោទប្រកាន់ជាបទឧក្រិដ្ឋ ឬមជ្ឈិម ដែលត្រូវផ្តន្ទាទោសដាក់ពន្ធនាគារ

-បុគ្គលដែលពាក់ព័ន្ធបានគេចខ្លួនមិនដឹងស្ថិតនៅទីកន្លែងណា ឬស្ថិតនៅក្រៅដែនដីនៃព្រះរាជាណាចក្រកម្ពុជា។

មុនពេលចៅក្រមចេញដីកាបង្គាប់ឲ្យចាប់ខ្លួនត្រូវតែទទួលយោបល់របស់ព្រះរាជអាជ្ញា ។ ចៅក្រមត្រូវចេញដីកានេះដោយមានថែងមូលហេតុ ក្រោយពីបានទទួលយោបល់របស់ព្រះរាជអាជ្ញា ។ ព្រះរាជអាជ្ញាធានារ៉ាប់រងផ្សព្វផ្សាយដីកាបង្គាប់ឲ្យចាប់ខ្លួន[123] របស់ចៅក្រមស៊ើបសួរ។

ការអនុវត្តដីកាបង្គាប់ឲ្យចាប់ខ្លួនត្រូវប្រគល់ឲ្យមន្រ្តីនគរបាលយុត្តិធម៌ ។ ក្នុងករណីដីកាបង្គាប់ឲ្យចាប់ខ្លួនត្រូវផ្សព្វផ្សាយទៅអង្គភាពនគរបាល ឬកងរាជអាវុធហត្ថតាមគ្រប់មធ្យោបាយ ។ ដើមដីកាត្រូវប្រគល់ក្នុងរយៈពេលយ៉ាងខ្លីបំផុតឲ្យដល់មន្រ្តីនគរបាលយុត្តិធម៌ ដែលទទួលបន្ទុកអនុវត្តដីកានេះ ។ មន្រ្តីនគរបាលយុត្តិធម៌មិនអាចចូលទៅក្នុងលំនៅដ្ឋានរបស់បុគ្គលដែលពាក់ព័ន្ធមុនម៉ោង០៦ និងក្រោយម៉ោង១៨ បានទេ ។ និងត្រូវឲ្យដំណឹងដល់ចៅក្រមអំពីការលំបាកទាំងអស់ក្នុងពេលអនុវត្តបេសកកម្មរបស់ខ្លួន[124] ។ ក្នុងករណីចាំបាច់ដីកាបង្គាប់ឲ្យចាប់ខ្លួនអាចផ្សព្វផ្សាយជាអន្តរជាតិតាមរយៈក្រសួងយុត្តិធម៌ ដោយប្រើយន្តការនានាដែលមានប្រសិទ្ធភាពក្នុងការអនុវត្ត [125]។

ប្រធានពន្ធនាគារ ឬមណ្ឌលឃុំខ្លួន ត្រូវតែទទួល និងឃុំខ្លួនជនត្រូវចោទដែលជាកម្មវត្ថុនៃដីកាបង្គាប់ឲ្យចាប់ខ្លួន ។ បុគ្គលដែលពាក់ព័ន្ធត្រូវតែបាននាំទៅបង្ហាញដល់ចៅក្រមស៊ើបសួរ ឬអ្នកជំនួសចៅក្រមស៊ើបសួរក្នុងរយៈពេលយ៉ាងខ្លីបំផុត ប្រសិនបើស្ថិតនៅក្នុងដំណាក់កាល នៃការស៊ើបសួរនៅឡើយ ។ បើបុគ្គលដែលពាក់ព័ន្ធមិនត្រូវបាននាំខ្លួនទៅបង្ហាញដល់ចៅក្រមស៊ើបសួរ ឬអ្នកជំនួសចៅក្រមស៊ើបសួរនៅថ្ងៃបន្ទាប់ពីថ្ងៃចាប់

[120] ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧, មាត្រា១៩៦ កថាខណ្ឌ១

[121] ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧, មាត្រា១៩៦ កថាខណ្ឌ២

[122] ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧, មាត្រា១៩៣ កថាខណ្ឌ២

[123] ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧, មាត្រា២៧ និងមាត្រា១៩៧

[124] ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧, មាត្រា១៩៩

[125] ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧, មាត្រា២០០

ខ្លួន បុគ្គលនេះត្រូវតែបានព្រះរាជអាជ្ញានាទីកន្លែងឃុំខ្លួនស្តាប់ចម្លើយ ។ ព្រះរាជអាជ្ញានេះធ្វើកំណត់ហេតុស្តីពីការស្តាប់ចម្លើយ ដែលត្រូវបញ្ជូនទៅចៅក្រមស៊ើបសួរ[126] ។

ប្រសិនបើជនត្រូវចោទដែលបានប្រព្រឹត្តបទល្មើសរក្សាទុក ដឹកជញ្ជូន ឬជួញដូរដោយខុសច្បាប់នូវសារធាតុញៀនជាអនីតិជន មន្ត្រីនគរបាលយុត្តិធម៌ ត្រូវជូនដំណឹងជាបន្ទាន់ទៅអ្នកតំណាងដែលច្បាប់បានកំណត់របស់អនីតិជនបន្ទាប់ពីការចាប់ខ្លួន ឬឃាត់ខ្លួនអនីតិជននោះ ។ ក្នុងករណីមិនអាចផ្តល់ដំណឹងនេះជាបន្ទាប់ត្រូវជូនដំណឹងដល់អ្នកតំណាងដែលច្បាប់បានកំណត់ ក្នុងរយៈពេលយ៉ាងខ្លីបំផុតដែលអាចធ្វើទៅបានអំពី[127]៖

-មូលហេតុនៃការចាប់ខ្លួន ឬឃាត់ខ្លួន និងប្រភេទនៃបទល្មើស

-ទីកន្លែងដែលអនីតិជនកំពុងស្នាក់នៅ

-សិទ្ធិចូលរួមរបស់អ្នកតំណាងដែលច្បាប់បានកំណត់នៅក្នុងអង្គភាពនគរបាល។

**ឃ. ដីកាបង្គាប់ឲ្យឃុំខ្លួន**

ចៅក្រមស៊ើបសួរអាចចេញដីកាបង្គាប់ឲ្យឃុំខ្លួនជនត្រូវចោទ[128] ។ ដីកាបង្គាប់ឲ្យឃុំខ្លួន គឺជាបញ្ជាដល់ប្រធានពន្ធនាគារ ឬមណ្ឌលឃុំខ្លួនឲ្យទទួល និងឲ្យឃុំខ្លួនជនត្រូវចោទនោះ[129] ចៅក្រមអាចចេញដីកាបង្គាប់ឲ្យឃុំខ្លួនលុះត្រាតែជនត្រូវចោទជាកម្មវត្ថុ នៃដីកាសម្រេចឲ្យឃុំខ្លួនបណ្តោះអាសន្ន ដូចនេះរាល់ដីកាបង្គាប់ឲ្យឃុំខ្លួនត្រូវតែមានដីកាសម្រេចឲ្យឃុំខ្លួនបណ្តោះអាសន្ន ដែលជនត្រូវចោទ ព្រះរាជអាជ្ញា អាចប្តឹងឧទ្ធរណ៍ចំពោះដីកាសម្រេចឲ្យឃុំខ្លួនបណ្តោះអាសន្ននេះបាន ។

ដីកាបង្គាប់ឲ្យឃុំខ្លួនត្រូវចុះនិទ្ទេសដូចខាងក្រោម[130]៖

-អត្តសញ្ញាណរបស់ជនត្រូវចោទ

-ប្រភេទនៃបទល្មើសដែលចោទប្រកាន់ និងអត្ថបទច្បាប់ដែលកំណត់ និងបង្ក្រាបបទល្មើស

-ឈ្មោះ និងឋានៈរបស់ចៅក្រមដែលចេញដីកា ។

ដីកាបង្គាប់ឲ្យឃុំខ្លួនត្រូវមានចុះកាលបរិច្ឆេទ ចុះហត្ថលេខាដោយចៅក្រមស៊ើបសួរ និងមានបោះត្រា ។ ការអនុវត្តទោសត្រូវគិតចាប់ពីពេលដែលចៅក្រមស៊ើបសួរចេញដីកាបង្គាប់ឲ្យឃុំខ្លួនលើជនត្រូវចោទ ។

[126] ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧, មាត្រា២០១

[127] ច្បាប់ស្តីពីយុត្តិធម៌អនីតិជន ឆ្នាំ២០១៦, មាត្រា១៨ កថាខណ្ឌ១

[128] ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧, មាត្រា២១៩

[129] ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧, មាត្រា២២០ កថាខណ្ឌ១

[130] ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧, មាត្រា២២១

ប្រធានពន្ធនាគារ ឬមណ្ឌលឃុំខ្លួនត្រូវតែទទួល និងឃុំខ្លួនបុគ្គលដែលមានដីកាបង្គាប់ឲ្យឃុំខ្លួន រហូតទាល់តែបានទទួលការឲ្យដំណឹងអំពីការដោះលែងឲ្យមានសេរីភាពវិញ ។ ប្រធានពន្ធនាគារ ឬមណ្ឌលឃុំខ្លួនរក្សាទុកដើមដីកាបង្គាប់ឲ្យឃុំខ្លួន ឬចុងដីកា ដែលបញ្ជាក់ថាត្រឹមត្រូវតាមច្បាប់ដើម ។

# ជំពូកទី៣
# ការបិទការស៊ើបសួរ

# ជំពូកទី៣

# ការបិទការស៊ើបសួរ

## ផ្នែកទី១៖ ការបិទការស៊ើបសួរ

ចៅក្រមស៊ើបសួរបន្ទាប់ពីយល់ឃើញថាសំណុំរឿងស៊ើបសួរបានស៊ើបសួររកភស្តុតាងទាំងដាក់បន្ទុក និងដោះបន្ទុករួចរាល់ហើយ ដោយយល់ឃើញថាការស៊ើបសួរមូលហើយ ចៅក្រមស៊ើបសួរអាចសម្រេចបិទការស៊ើបសួរដោយបញ្ជូនរឿងទៅព្រះរាជអាជ្ញា[131] ដើម្បីធ្វើដីកាសន្និដ្ឋានស្ថាពរ ដែលដីកានេះជាដីកាដែលសម្រេចចោទប្រកាន់ជាស្ថាពររបស់ព្រះរាជអាជ្ញា ។ ការបិទការស៊ើបសួរចៅក្រមស៊ើបសួរត្រូវជូនដំណឹងអំពីការបិទការស៊ើបសួរទៅដល់ព្រះរាជអាជ្ញា ជនត្រូវចោទ ដើមបណ្តឹងរដ្ឋប្បវេណី និងមេធាវី[132]ក្នុងរយៈពេល២ថ្ងៃបន្ទាប់ពីជូនដំណឹង ចៅក្រមស៊ើបសួរបញ្ជូនសំណុំរឿងឲ្យព្រះរាជអាជ្ញាដើម្បីពិនិត្យ[133] ។

ក្នុងករណីសំណុំរឿងជាសំណុំរឿងដែលមានជនត្រូវចោទត្រូវបានឃុំខ្លួន នោះព្រះរាជអាជ្ញាត្រូវបង្វិលសំណុំរឿងទៅចៅក្រមស៊ើបសួរវិញក្នុងរយៈពេល ១៥(ដប់ប្រាំ)ថ្ងៃ និង ១(មួយ)ខែ សម្រាប់សំណុំរឿងដែលជន-ត្រូវចោទនៅក្រៅឃុំ[134]។

### កថាខណ្ឌទី១៖ យោបល់របស់ព្រះរាជអាជ្ញា

ព្រះរាជអាជ្ញាជាម្ចាស់នៃបណ្តឹងអាជ្ញា ក្រោយពីបានទទួលសំណុំរឿងដែលចៅក្រមបញ្ជូនមកពិនិត្យហើយប្រសិនបើយល់ឃើញថាការស៊ើបសួរមិនទាន់ចប់សព្វគ្រប់ទេ ព្រះរាជអាជ្ញាអាចស្នើឲ្យចៅក្រមបំពេញកិច្ចស៊ើបសួរបន្ថែមលើចំណុចណាមួយដែលព្រះរាជអាជ្ញាយល់ឃើញថាមានប្រយោជន៍ ប៉ុន្តែក្នុងករណីព្រះរាជអាជ្ញាយល់ឃើញថាការស៊ើបសួរចប់សព្វគ្រប់ហើយ ព្រះរាជអាជ្ញាត្រូវធ្វើដីកាសន្និដ្ឋានស្ថាពរទៅចៅក្រមស៊ើបសួរដើម្បីចោទប្រកាន់ជាស្ថាពរដោយប្តឹងទៅចៅក្រមស៊ើបសួរឲ្យបញ្ជូនជនត្រូវចោទទៅតុលាការជំនុំជម្រះ ឬលើកលែងចោទប្រកាន់លើជនត្រូវចោទ ។

#### ក. ការស្នើសុំឲ្យបំពេញកិច្ចដោយព្រះរាជអាជ្ញា

ព្រះរាជអាជ្ញាយល់ឃើញថាចាំបាច់ត្រូវធ្វើកិច្ចស៊ើបសួរថ្មីទៀត[135] នោះព្រះរាជអាជ្ញាអាចធ្វើតាមរយៈការស្នើសុំឲ្យបំពេញកិច្ច[136] ។ នៅគ្រប់ពេលវេលានៃការស៊ើបសួរ ព្រះរាជអាជ្ញាអាចសុំឲ្យចៅក្រមស៊ើបសួរធ្វើកិច្ច

[131] ដីកាបញ្ជូនសំណុំរឿងឲ្យពិនិត្យ ដូចមានក្នុងឧបសម្ព័ន្ធទី១៩

[132] លិខិតជូនដំណឹង ឬជូនព័ត៌មាន ដូចមានក្នុងឧបសម្ព័ន្ធទី១៨

[133] ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧, មាត្រា២៤៦

[134] ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧, មាត្រា២៤៦ កថាខណ្ឌ៣

[135] ដីកាចាត់ឲ្យបំពេញកិច្ចស៊ើបសួរបន្ថែម មានក្នុងឧបសម្ព័ន្ធទី២០

[136] ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧, មាត្រា២៤៦ កថាខណ្ឌ២

ស៊ើបសួរណាមួយដែលខ្លួនយល់ឃើញថាមានប្រយោជន៍[137] ប្រសិនបើចៅក្រមស៊ើបសួរមិនព្រមធ្វើតាមសេចក្តីសន្និដ្ឋានរបស់ព្រះរាជអាជ្ញាទេ នោះចៅក្រមស៊ើបសួរត្រូវចេញដីកាបដិសេធនៅក្នុងរយៈពេល១៥ថ្ងៃ ដោយត្រូវមានសំអាងហេតុ ហើយត្រូវតែជូនដំណឹងដល់ព្រះរាជអាជ្ញាក្នុងរយៈពេលយ៉ាងឆាប់បំផុត ។ មិនតែប៉ុណ្ណោះប្រសិនបើចៅក្រមស៊ើបសួរមិនបានសម្រេចក្នុងរយៈពេល១៥ថ្ងៃទេ នោះព្រះរាជអាជ្ញាអាចប្តឹងដោយផ្ទាល់តាមរយៈពាក្យសុំទៅសភាស៊ើបសួរដែលសម្រេចជំនួសចៅក្រមស៊ើបសួរ[138] ។ ព្រះរាជអាជ្ញាអាចស្នើសុំឲ្យចៅក្រមស៊ើបសួរឲ្យអនុវត្តវិធានការណ៍និរន្តរាយលើជនត្រូវចោទ ដោយមានដីកាបង្គាប់ឲ្យចូលខ្លួន ដីកាបង្គាប់ឲ្យនាំខ្លួន ឬដីកាបង្គាប់ឲ្យចាប់ខ្លួន របស់ចៅក្រមស៊ើបសួរ ឬអាចឲ្យចៅក្រមស៊ើបសួររកចំណុចណាមួយដែលជាខ្លួនយល់ថាមានប្រយោជន៍ ។

**ខ. ដីកាសន្និដ្ឋានស្ថាពរ**

ដីកាសន្និដ្ឋានស្ថាពររបស់ព្រះរាជអាជ្ញា[139] អាចចេញបានដោយព្រះរាជអាជ្ញាយល់ឃើញថាមានភស្តុតាងគ្រប់គ្រាន់ក្នុងការចោទប្រកាន់ ឬកែប្រែការចោទប្រកាន់ប្រសិនបើយល់ឃើញថាមានធាតុផ្សំបទល្មើសគ្រប់គ្រាន់។ ក្នុងរយៈពេល១៥ថ្ងៃប្រសិនបើជនត្រូវចោទត្រូវបានឃុំខ្លួន និង០១ខែសម្រាប់ករណីដែលជនត្រូវចោទនៅក្រៅឃុំ ព្រះរាជអាជ្ញាបង្វិលសំណុំរឿងទៅចៅក្រមស៊ើបសួរវិញ ដោយមានដីកាសន្និដ្ឋានស្ថាពរភ្ជាប់មកជាមួយផង ហើយថេរវេលានេះត្រូវរាប់ចាប់ពីព្រះរាជអាជ្ញាបានទទួលសំណុំរឿង[140] ។ ប្រសិនបើព្រះរាជអាជ្ញាយល់ឃើញដូចចៅក្រមស៊ើបសួរដែរថា ការស៊ើបសួរត្រូវបញ្ចប់នោះព្រះរាជអាជ្ញាធ្វើដីកាសន្និដ្ឋានស្ថាពរជាលាយលក្ខណ៍អក្សរ និងមានសំអាងហេតុ ។ ព្រះរាជអាជ្ញាអាចប្តឹងសុំឲ្យចៅក្រមស៊ើបសួរសម្រេចបញ្ជូនខ្លួនជនត្រូវចោទទៅតុលាការជំនុំជម្រះ ឬក៏លើកលែងចោទប្រកាន់ ។ ការបិទការស៊ើបសួរចៅក្រមស៊ើបសួរត្រូវជូនដំណឹងអំពីការបិទការស៊ើបសួរទៅដល់ព្រះរាជអាជ្ញា ជនត្រូវចោទ ដើមបណ្តឹងរដ្ឋប្បវេណី និងមេធាវី ក្នុងរយៈពេល០២ថ្ងៃបន្ទាប់ពីជូនដំណឹងចៅក្រមស៊ើបសួរបញ្ជូនសំណុំរឿងឲ្យព្រះរាជអាជ្ញាពិនិត្យ ។ ដីកាសន្និដ្ឋានស្ថាពរជាដីកាសម្រាប់ធ្វើការចោទប្រកាន់ជាស្ថាពររបស់ព្រះរាជអាជ្ញា ដែលការចោទប្រកាន់នេះត្រូវសំអាងលើភស្តុតាងដាក់បន្ទុកដែលមាននៅក្នុងសំណុំរឿង ។

---

[137] ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧, មាត្រា១៣២ កថាខណ្ឌ១

[138] ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧, មាត្រា១៣២

[139] ដីកាសន្និដ្ឋានស្ថាពរ ដូចមានក្នុងឧបសម្ព័ន្ធទី២១

[140] ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧, មាត្រា២៤៦

**កថាខណ្ឌទី២៖ ដីកាដំណោះស្រាយ**

ដីកាដំណោះស្រាយគឺជា ដីកាចុងក្រោយបង្អស់នៃការបញ្ចប់នូវកិច្ចស៊ើបសួររបស់ចៅក្រមស៊ើបសួរ ដែលដីកានេះអាចជាដីកាអាចជាដីកាបញ្ជូនរឿងទៅជំនុំជម្រះផង ឬនិងជាដីកាលើកលែងចោទប្រកាន់ផង[141] ។ ប្រសិនបើយល់ឃើញថាជាអំពើនោះជាបទឧក្រិដ្ឋ បទមជ្ឈិម ឬបទលហុ ចៅក្រមស៊ើបសួរសម្រេចបញ្ជូនជនត្រូវចោទទៅមុខតុលាការជំនុំជម្រះ ។ ដីកាត្រូវរៀបរាប់អំពើដែលត្រូវចោទប្រកាន់ និងឈ្មោះបទល្មើសតាមច្បាប់ ។ ដីកាដំណោះស្រាយត្រូវមានសំអាងហេតុ ។ ចៅក្រមស៊ើបសួរមិនត្រូវជាប់កាតព្វកិច្ចគោរពតាមដីកាសន្និដ្ឋានស្ថាពររបស់ព្រះរាជអាជ្ញាទេ ។ ដីកាអាចជាដីកាបញ្ជូនទៅតុលាការជំនុំជម្រះចំពោះអំពើមួយចំនួន និងជាដីកាលើកលែងចោទប្រកាន់ចំពោះអំពើដទៃទៀត ។

ក្នុងករណីដែលសំណុំរឿងស៊ើបសួរពាក់ព័ន្ធនឹងអង្គហេតុច្រើន ចៅក្រមស៊ើបសួរអាចចេញដីកាដំណោះស្រាយចំពោះអង្គហេតុដែលការស៊ើបសួរបានចប់សព្វគ្រប់ និងបន្តការស៊ើបសួរចំពោះអង្គហេតុផ្សេងទៀតបាន។ ចៅក្រមស៊ើបសួរក៏អាចចេញដីកាលើកលែងចោទប្រកាន់ ចំពោះជនត្រូវចោទដែលត្រូវបានរកឃើញថា មិនមានការពាក់ព័ន្ធនឹងការប្រព្រឹត្តបទល្មើស ឬការចូលរួមប្រព្រឹត្តបទល្មើស និងធ្វើការស៊ើបសួររកអត្តសញ្ញាណជនល្មើសបន្តទៀតបាន[142] ។ ដីកាដំណោះស្រាយត្រូវជូនដំណឹងក្នុងរយៈពេលដ៏ខ្លីបំផុតដល់ព្រះរាជអាជ្ញា ជនត្រូវចោទ ដើមបណ្តឹងរដ្ឋប្បវេណី និងមេធាវី ។ ក្នុងករណីដែលមានការលើកលែងចោទប្រកាន់ដោយមូលហេតុចំពោះអត្តសញ្ញាណរបស់ជនត្រូវចោទមិនត្រូវបានស្គាល់ ឬក្នុងករណីដែលជនត្រូវចោទទទួលមរណភាព ចៅក្រមស៊ើបសួរអាចប្តឹងសុំទៅតុលាការព្រហ្មទណ្ឌ តាមដីកាបញ្ជូនឲ្យសម្រេចរឹបអូសឧបករណ៍សម្ភារៈ មូលនិធិ ផលទុន ឬទ្រព្យសម្បត្តិទាំងនោះពាក់ព័ន្ធនឹងបទល្មើស ដូននេះប្រសិនបើជនត្រូវចោទត្រូវបានលើកលែងចោទប្រកាន់នៅដំណាក់កាលនៃការស៊ើបសួរក៏ដោយ ក៏ចៅក្រមស៊ើបសួរអាចប្តឹងទៅតុលាការជំនុំជម្រះដើម្បីសម្រេចអំពីវត្ថុតាងដែលជាគ្រឿងញៀន ដើម្បីធ្វើការរឹបអូស និងបំផ្លាញចោលតាមរយៈសាលក្រម។

បុគ្គលដែលមានប្រយោជន៍ពាក់ព័ន្ធ ឬដែលអះអាងថាខ្លួនជាម្ចាស់នៃវត្ថុដែលជាការរឹបអូស មានសិទ្ធិប្តឹងឧទ្ធរណ៍ប្រឆាំងនឹងសេចក្តីសម្រេចនេះបានក្នុងរយៈពេល១ខែគិតពីថ្ងៃប្រកាសសាលក្រម ប្រសិនបើបុគ្គលនេះបានចូលរួមក្នុងនីតិវិធីជំនុំជម្រះរបស់តុលាការ និងក្នុងរយៈពេល២ខែគិតពីថ្ងៃប្រកាសផ្សាយជាសាធារណៈតាមសារព័ត៌មាន ឬមធ្យោបាយទូរគមនាគមន៍ ប្រសិនបើបុគ្គលនេះមិនបានចូលរួមនៅក្នុងនីតិវិធីតុលាការ ។ បែបបទ និងនីតិវិធីនៃការប្តឹងឧទ្ធរណ៍នេះត្រូវអនុវត្តតាមបទប្បញ្ញត្តិនៃក្រមនីតិវិធីព្រហ្មទណ្ឌ[143]។

[141] ក្រមព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧, មាត្រា២៤៧ និងមាត្រា២៤៧ថ្មី នៃច្បាប់ស្តីពីវិសោធនកម្មមាត្រា២៤១, មាត្រា៣៦៨, មាត្រា៣៧២ និងមាត្រា៣៨២នៃក្រមនីតិវិធីព្រហ្មទណ្ឌ

[142] ច្បាប់ស្តីពីវិសោធនកម្មមាត្រា២៤១,មាត្រា៣៦៨,មាត្រា៣៧២ និងមាត្រា៣៨២នៃក្រមនីតិវិធីព្រហ្មទណ្ឌ, មាត្រា២៤៧ថ្មី កថាខណ្ឌ៥

[143] ច្បាប់ស្តីពីវិសោធនកម្មមាត្រា២៤១,មាត្រា៣៦៨,មាត្រា៣៧២ និងមាត្រា៣៨២នៃក្រមនីតិវិធីព្រហ្មទណ្ឌ, មាត្រា២៤៧ថ្មី កថាខណ្ឌ៨

ដីកាដំណោះស្រាយអាចសម្រេចអំពីការប្រគល់សងទៅឲ្យម្ចាស់ដើមវិញនូវវត្ថុដែលចាប់យក[144] ។ ប៉ុន្តែការប្រគល់វត្ថុដែលចាប់យកនេះ ចៅក្រមស៊ើបសួរមិនអាចប្រគល់វត្ថុដែលជាកម្មវត្ថុនៃបទល្មើសបានទេ ជាងនេះទៅទៀតចំពោះបទល្មើសរក្សាទុក ដឹកជញ្ជូន ឬជួញដូរដោយខុសច្បាប់នូវសារធាតុញៀន ចៅក្រមស៊ើបសួរមិនអាចប្រគល់វត្ថុដែលចាប់យកជាគ្រឿងញៀនដែលជាកម្មវត្ថុនៃបទល្មើសនោះទៅវិញទេ ។ តំណាងអយ្យការអាចប្ដឹងឧទ្ធរណ៍ចំពោះដីកាដំណោះស្រាយរបស់ចៅក្រមស៊ើបសួរ។

ដីកាដំណោះស្រាយបញ្ចប់ការឃុំខ្លួនបណ្ដោះអាសន្ន[145] ។ ប្រសិនបើចៅក្រមស៊ើបសួរយល់ឃើញថាមិនមានភស្តុតាងណាមួយក្នុងការដាក់បន្ទុកលើជនត្រូវចោទ ក្នុងបទរក្សាទុក ដឹកជញ្ជូន ឬជួញដូរដោយខុសច្បាប់នូវសារធាតុញៀនទេ ចៅក្រមស៊ើបសួរអាចចេញដីកាដំណោះស្រាយដោយសម្រេចដោះលែងជនត្រូវចោទឲ្យមានសេរីភាពវិញ ដោយមានភ្ជាប់ជាមួយនឹងដីកាបង្គាប់ឲ្យដោះលែងដោយចៅក្រមស៊ើបសួរ ដើម្បីបង្គាប់ឲ្យប្រធានពន្ធនាគារ ឬមណ្ឌលឃុំខ្លួនដោះលែងជនត្រូវចោទឲ្យមានសេរីភាពវិញ ។ តំណាងអយ្យការអាចប្ដឹងទៅសភាស៊ើបសួរ ចំពោះដីកាដំណោះស្រាយរបស់ចៅក្រមស៊ើបសួរនេះ ។ ក្នុងករណីតំណាងអយ្យការប្ដឹងទៅសភាស៊ើបសួរចំពោះដីកាដំណោះស្រាយរបស់ចៅក្រមស៊ើបសួរ ចៅក្រមស៊ើបសួរមិនអាចដោះលែងជនត្រូវចោទបានទេ ដោយរក្សាទុកជនត្រូវចោទក្នុងពន្ធនាគារ ឬមណ្ឌលឃុំខ្លួន រហូតទាល់តែសភាស៊ើបសួរបានសម្រេចអំពីបណ្ដឹងឧទ្ធរណ៍នោះ[146] ។ ចៅក្រមស៊ើបសួរត្រូវជូនដំណឹងស្ដីពីការសម្រេចក្នុងដីកាដំណោះស្រាយនេះទៅតំណាងអយ្យការ ជនត្រូវចោទ និងមេធាវីការពារសិទ្ធិឲ្យជនត្រូវចោទក្នុងរយៈពេលដ៏ខ្លីបំផុត[147]។

**គ. ការបញ្ជូនរឿងទៅជំនុំជម្រះ**

ក្នុងករណីចៅក្រមស៊ើបសួររកឃើញពីសារធាតុញៀននៅក្នុងគ្រឿងញៀនដែលបានមកពីលទ្ធផលរបស់មន្ទីរពិសោធន៍ នៃអគ្គលេខាធិការដ្ឋានអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន ដែលបញ្ជាក់ថា វិជ្ជមាន(មានសារធាតុញៀន) ដែលកំណត់អំពីប្រភេទនៃសារធាតុញៀន ភាគរយនៃសារធាតុញៀនដែលយកទៅធ្វើកោសល-វិច័យ និងចំណាត់ថ្នាក់គ្រឿងញៀនរួចរាល់មក ចៅក្រមស៊ើបសួរអាចសម្រេចបញ្ជូនសំណុំរឿងទៅជំនុំជម្រះ[148] ។

ប្រសិនបើចៅក្រមស៊ើបសួរសម្រេចចេញដីកាបញ្ជូនសំណុំរឿងទៅជំនុំជម្រះ ចៅក្រមស៊ើបសួរបញ្ជូនសំណុំរឿងជាបន្ទាន់ទៅប្រធានសាលាដំបូង ដើម្បីកំណត់ពេលសវនាការជំនុំជម្រះ[149] ។ ចៅក្រមស៊ើបសួរអាច

[144] ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧, មាត្រា២៤៨

[145] ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧, មាត្រា២៤៩

[146] ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧, មាត្រា២៧៦ កថាខណ្ឌ៣

[147] លិខិតជូនដំណឹង ឬជូនព័ត៌មាន ដូចមានក្នុងឧបសម្ព័ន្ធទី២៥

[148] ដីកាសម្រេចបញ្ជូនសំណុំរឿងទៅជំនុំជម្រះ ដូចមានក្នុងឧបសម្ព័ន្ធទី២៣

[149] ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧, មាត្រា២៥០

រក្សាជនត្រូវចោទឲ្យនៅជាប់ឃុំជាប់ឃុំជាបណ្ដោះអាសន្ន[150] រហូតដល់ពេលចូលបង្ហាញខ្លួននៅមុខតុលាការ ដោយការរក្សាជនត្រូវចោទឲ្យនៅក្នុងឃុំបណ្ដោះអាសន្ននេះមានអានុភាព**រយៈពេល០៤ខែ** ហើយក្នុងករណីជនត្រូវចោទពុំត្រូវបានយកមកបង្ហាញខ្លួន នៅមុខតុលាការក្នុងរយៈពេល០៤ខែនេះទេ ផុតរយៈពេលនេះជនត្រូវចោទត្រូវបានដោះលែងឲ្យនៅក្រៅឃុំបណ្ដោះអាសន្នដោយឯកឯង[151]។

**ខ. ការសម្រេចលើកលែងចោទប្រកាន់**

ចៅក្រមស៊ើបសួរអាចចេញដីកាលើកលែងចោទប្រកាន់[152] នៅក្នុងករណីដូចខាងក្រោម[153]៖

-អំពើប្រព្រឹត្ត មិនមែនជាបទឧក្រិដ្ឋ បទមជ្ឈិម ឬបទលហុ

-ជនដែលប្រព្រឹត្តអំពើនោះនៅតែគេមិនស្គាល់

-គ្មានភស្តុតាងដាក់បន្ទុកគ្រប់គ្រាន់លើជនត្រូវចោទ

-ករណីដែលបណ្ដឹងអាជ្ញារលត់

ក្នុងករណីដែលមានការលើកលែងចោទប្រកាន់ដោយមូលហេតុអត្តសញ្ញាណរបស់ជនត្រូវចោទមិនត្រូវបានស្គាល់ ឬក្នុងករណីដែលជនត្រូវចោទទទួលមរណភាព ចៅក្រមស៊ើបសួរអាចប្ដឹងទៅតុលាការព្រហ្មទណ្ឌតាមដីកាបញ្ជូនឲ្យរឹបអូសឧបករណ៍ សម្ភារៈ មូលនិធិ ផលទុន ឬទ្រព្យសម្បត្តិទាំងនោះដែលពាក់ព័ន្ធនឹងបទល្មើសរក្សាទុក ដឹកជញ្ជូន ឬជួញដូរដោយខុសច្បាប់នូវសារធាតុញៀន ។ ក្នុងករណីនេះ តុលាការព្រហ្មទណ្ឌត្រូវសម្រេចអំពី ការរឹបអូសដោយសាលក្រមក្នុងសវនាការជាសាធារណៈ ដោយមានការចូលរួមពីតំណាងអយ្យការ និងបុគ្គលពាក់ព័ន្ធ ប្រសិនបើមាន ។ សាលក្រមដែលសម្រេចអំពីការរឹបអូសត្រូវបិទនៅទីកន្លែងដែលតុលាការបានចេញសាលក្រម ព្រមទាំងផ្សាយជាសាធារណៈតាមសារព័ត៌មានឬមធ្យោបាយទូរគមនាគមន៍សោតទស្សន៍[154] ។

កាលបើការរឹបអូសក្លាយជាស្ថាពរ វត្ថុរឹបអូសក្លាយជាកម្មសិទ្ធិរបស់រដ្ឋ ។ រដ្ឋអាចលក់ ឬបំផ្លាញចោលវត្ថុរឹបអូសនៅក្នុងទម្រង់ដែលមានចែងសម្រាប់លក់ទ្រព្យសម្បត្តិរបស់រដ្ឋ ច្បាប់អាចចែងអំពីការបំផ្លាញចោលនូវវត្ថុខ្លះផងដែរ[155] ដូចជាការបំផ្លាញគ្រឿងញៀន គឺត្រូវបានប្រព្រឹត្តឡើងជារៀងរាល់ឆ្នាំ ដោយមានការដុតបំផ្លាញ និងក្រោមការដឹកនាំដោយអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន។

---

[150] ដីកាសម្រេចរក្សាជនជាប់ចោទក្នុងឃុំជាបណ្ដោះអាសន្ន ដូចមានក្នុងឧបសម្ព័ន្ធទី២៤

[151] ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧, មាត្រា២៤៩ កថាខណ្ឌ៣

[152] ដីកាសម្រេចលើកលែងចោទប្រកាន់ ដូចមានក្នុងឧបសម្ព័ន្ធទី២២

[153] ច្បាប់ស្ដីពីវិសោធនកម្មមាត្រា២៤១,មាត្រា៣៦៨,មាត្រា៣៧២ និងមាត្រា៣៨២នៃក្រមនីតិវិធីព្រហ្មទណ្ឌ, មាត្រា២៤៧ថ្មី កថាខណ្ឌ៣

[154] ច្បាប់ស្ដីពីវិសោធនកម្មមាត្រា២៤១,មាត្រា៣៦៨,មាត្រា៣៧២ និងមាត្រា៣៨២នៃក្រមនីតិវិធីព្រហ្មទណ្ឌ, មាត្រា២៤៧ថ្មី កថាខណ្ឌ៧

[155] ក្រមព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០១០, មាត្រា១៧៨

ដីកាលើកលែងចោទប្រកាន់ត្រូវជូនដំណឹងក្នុងរយៈពេលដ៏ខ្លីបំផុតដល់ព្រះរាជអាជ្ញា និងជនត្រូវចោទ[156]។

## ផ្នែកទី២៖ សភាស៊ើបសួរ នៃសាលាឧទ្ធរណ៍

សភាស៊ើបសួរ ជាសភាមួយក្នុងចំណោម៥(ប្រាំ)នៅក្នុងសាលាឧទ្ធរណ៍ដែលមានសមត្ថកិច្ចសម្រេចលើបណ្ដឹងណាមួយចំពោះដីកាសម្រេចរបស់ចៅក្រមស៊ើបសួរ ឬបណ្ដឹងចំពោះកិច្ចនីតិវិធីនៃការស៊ើបសួរ នៅតាមសាលាដំបូងរាជធានី-ខេត្ត និងធានាឲ្យបាននូវប្រសិទ្ធិភាពនៃការស៊ើបសួរឲ្យមានភាពច្បាស់លាស់ ព្រមទាំងធានាឲ្យបាននូវការប្រើប្រាស់សិទ្ធិមួយចំនួនរបស់ភាគីក្នុងសំណុំរឿងឲ្យមានប្រសិទ្ធិភាព ។ សភាស៊ើបសួរមានសមត្ថកិច្ចលើការចេញសាលដីកាដែលសម្រេចអំពីការបណ្ដឹងឧទ្ធរណ៍ ឬបណ្ដឹងសុំមោឃភាពនីតិវិធីចំពោះកិច្ចនីតិវិធីរបស់ចៅក្រមស៊ើបសួរ ។ ក្នុងនោះអគ្គព្រះរាជអាជ្ញានៃមហាអយ្យការអមសាលាឧទ្ធរណ៍ ព្រះរាជអាជ្ញានៃសាលាដំបូង ជនត្រូវចោទ និងដើមបណ្ដឹងរដ្ឋប្បវេណី មានសិទ្ធិក្នុងការប្ដឹងទៅសភាស៊ើបសួរ ដើម្បីពិនិត្យ និងវិនិច្ឆ័យតាមផ្លូវច្បាប់ ។ កាលណាសភាស៊ើបសួរត្រូវបានប្ដឹងដោយផ្ទាល់តាមរយៈពាក្យសុំក្រឡាបញ្ជី នៃសភាស៊ើបសួរ សុំឲ្យក្រឡាបញ្ជី នៃចៅក្រមស៊ើបសួរផ្ញើមកឲ្យខ្លួននូវសំណុំរឿងនៃនីតិវិធី ឬសំណុំរឿងបង្ការទុក[157] ក្នុងន័យនេះក្រឡាបញ្ជី នៃចៅក្រមស៊ើបសួរ ត្រូវបញ្ជូនសំណុំរឿងចតចម្លងទៅសភាស៊ើបសួរ ដោយទុកសំណុំរឿងដើមដើម្បីបន្តនីតិវិធី នៃការស៊ើបសួរបន្តទៀត ។

### កថាខណ្ឌទី១៖ ការប្ដឹងទៅសភាស៊ើបសួរចំពោះដីកាសម្រេច

បណ្ដឹងឧទ្ធរណ៍ចំពោះដីកាសម្រេចមានដូចខាងក្រោម៖

ក-បណ្ដឹងឧទ្ធរណ៍ដោយអគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ និងព្រះរាជអាជ្ញា ដោយអគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ និងព្រះរាជអាជ្ញាអាចប្ដឹងឧទ្ធរណ៍ចំពោះគ្រប់ដីកាសម្រេចទាំងអស់របស់ចៅក្រមស៊ើបសួរបាន[158] ។

ខ-បណ្ដឹងឧទ្ធរណ៍ដោយជនត្រូវចោទ[159]

-ដីកាបដិសេធពាក្យសុំឲ្យធ្វើកិច្ចស៊ើបសួរ ឬស្នើសុំឲ្យបំពេញកិច្ចដោយជនត្រូវចោទ[160] ក្នុងករណីចៅក្រមស៊ើបសួរមិនបានធ្វើការបំពេញកិច្ចស៊ើបសួរតាមពាក្យសុំរបស់ជនត្រូវចោទទេ ចៅក្រមស៊ើបសួរត្រូវចេញដីកាបដិសេធពីពាក្យសុំរបស់ជនត្រូវចោទនេះឲ្យបានមុន១ខែ បន្ទាប់ពីទទួលបានពាក្យសុំ ហើយជនត្រូវចោទអាចប្ដឹងទៅសភាស៊ើបសួរបានដោយផ្ទាល់ ។ ប្រសិនបើចៅក្រមស៊ើបសួរមិនបានសម្រេចអំពីពាក្យសុំរបស់ខ្លួន

[156] ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧, មាត្រា២៤៧ កថាខណ្ឌ៥
[157] ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧, មាត្រា២៥៧ កថាខណ្ឌ២
[158] ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧, មាត្រា២៦៦
[159] ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧, មាត្រា២៦៧
[160] ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧, មាត្រា១៣៣ កថាខណ្ឌ២

ក្នុងរយៈពេល០១ខែនេះទេ មិនតែប៉ុណ្ណោះជនត្រូវចោទមានសិទ្ធិប្តឹងទៅសភាស៊ើបសួរចំពោះដីកាបដិសេធពាក្យសុំឲ្យធ្វើកិច្ចស៊ើបសួរ ឬសុំឲ្យបំពេញកិច្ចរបស់ខ្លួន។

-ដីកាមិនព្រមប្រគល់វត្ថុដែលចាប់យកឲ្យទៅម្ចាស់ដើមវិញ[161] ចៅក្រមអាចចេញដីកានេះដោយមុនពេលចេញដីកាដំណោះស្រាយ ចៅក្រមស៊ើបសួរមានសមត្ថកិច្ចក្នុងការប្រគល់សងទៅនូវវត្ថុដែលចាប់យកឲ្យទៅម្ចាស់ដើមវិញ ដោយទទួលយោបល់ពីព្រះរាជអាជ្ញា ក្នុងករណីចៅក្រមស៊ើបសួរសម្រេចមិនព្រមប្រគល់វត្ថុដែលចាប់យកឲ្យទៅម្ចាស់ដើមវិញទេក្នុងរយៈពេល៥ថ្ងៃ នោះអ្នកដាក់ពាក្យសុំវត្ថុចាប់យកនោះមានសិទ្ធិប្តឹងទៅសភាស៊ើបសួរ បើទោះបីជាអ្នកដាក់ពាក្យសុំមិនមែនជាបុគ្គលដែលនៅក្នុងនីតិវិធីនៃការស៊ើបសួរក៏ដោយ ។ ការប្រគល់ ឬមិនប្រគល់វត្ថុចាប់ឲ្យទៅម្ចាស់ដើមវិញអាចធ្វើនៅក្នុងដីកាដំណោះស្រាយដោយមានសំអាងហេតុ។

-ដីកាបដិសេធពាក្យសុំឲ្យធ្វើកោសលវិច័យ[162] ក្នុងករណីជនត្រូវចោទបានស្នើសុំឲ្យចៅក្រមស៊ើបសួរធ្វើកោសលវិច័យលើអ្វីមួយ ហើយចៅក្រមស៊ើបសួរពុំព្រមធ្វើកោសលវិច័យដូចមានក្នុងពាក្យសុំ ដោយចៅក្រមស៊ើបសួរចេញដីកាបដិសេធពាក្យសុំធ្វើកោសលវិច័យ នោះជនត្រូវចោទអាចប្តឹងចំពោះដីកាបដិសេធពាក្យសុំឲ្យធ្វើកោសលវិច័យនេះបាន ទៅសភាស៊ើបសួរជាអ្នកសម្រេច។

-ដីកាបដិសេធពាក្យសុំឲ្យធ្វើកោសលវិច័យបន្ថែម ឬសុំឲ្យធ្វើប្រតិកោសលវិច័យ[163] គ្រប់ពាក្យសុំធ្វើកោសលវិច័យបន្ថែម ឬសុំឲ្យធ្វើប្រតិកោសលវិច័យ ដែលធ្វើឡើងក្រោយផុតរយៈពេលដែលកំណត់ដោយចៅក្រមស៊ើបសួរ ត្រូវដាក់បញ្ចូលក្នុងសំណុំរឿង ប្រសិនបើចៅក្រមចេញដីកាបដិសេធពាក្យសុំឲ្យធ្វើកោសលវិច័យបន្ថែម ឬសុំឲ្យធ្វើប្រតិកោសលវិច័យ ចៅក្រមត្រូវសម្រេចដោយមានសំអាងហេតុ ។ ដីកានេះត្រូវសម្រេចក្នុងរយៈពេល១ខែ និងត្រូវឲ្យដំណឹងទៅជនត្រូវចោទជាបន្ទាន់ ។

-ដីកាស្តីពីរឿងឃុំខ្លួនបណ្តោះអាសន្ន និងត្រួតពិនិត្យតាមផ្លូវតុលាការ គឺសំដៅរាល់ដីកាសម្រេចពាក់ព័ន្ធជាមួយទៅនឹងការឃុំខ្លួនបណ្តោះអាសន្ន និងត្រួតពិនិត្យតាមផ្លូវតុលាការលើជនត្រូវចោទដែលមានជាប់កាតព្វកិច្ចតាមផ្លូវតុលាការនោះ ។ ដីកាដំណោះស្រាយបញ្ចប់ការឃុំខ្លួនបណ្តោះអាសន្ន ។ ចំពោះដីកាត្រួតពិនិត្យតាមផ្លូវតុលាការជនត្រូវចោទអាចមានមូលហេតុថាណាមួយ ឬកាតព្វកិច្ចដែលដាក់ឲ្យអនុវត្តក្នុងដីកាត្រួតពិនិត្យតាមផ្លូវតុលាការមានភាពធ្ងន់ធ្ងរពេក[164] ដែលកាតព្វកិច្ចនេះមានដូចខាងក្រោម៖

១.មិនត្រូវចេញក្រៅព្រំប្រទល់ដែនដីកំណត់ដោយចៅក្រមស៊ើបសួរ

---

[161] ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧, មាត្រា១៦១ និងមាត្រា២៤៨, "គ្រប់បុគ្គលដែលដាក់ពាក្យសុំអាចប្តឹងឧទ្ធរណ៍លើដីកាសម្រេចនេះបានបើទោះជាបុគ្គលនៅក្រៅនីតិវិធីក៏ដោយ"។

[162] ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧, មាត្រា១៦២

[163] ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧, មាត្រា១៧០ កថាខណ្ឌ៧

[164] ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧, មាត្រា២២៣

២.មិនត្រូវផ្លាសប្តូរលំនៅឋានដោយគ្មានការអនុញ្ញាតពីចៅក្រមស៊ើបសួរ

៣.មិនត្រូវទៅកាន់ទីកន្លែងខ្លះដែលកំណត់ដោយចៅក្រមស៊ើបសួរ

៤.ត្រូវចូលបង្ហាញខ្លួនតាមការកំណត់នៅអង្គភាពនគរបាល ឬកងរាជអាវុធហត្ថដែលចាត់តាំងដោយចៅក្រមស៊ើបសួរ

៥.ត្រូវឆ្លើយតបនឹងការកោះហៅពីគ្រប់បុគ្គលដែលចាត់តាំងដោយចៅក្រមស៊ើបសួរ

៦.ប្រគល់ជូនការិយាល័យក្រឡាបញ្ជីគ្រប់ឯកសារបញ្ជាក់អំពីអត្តសញ្ញាណ

៧.មិនត្រូវបើកបរ

៨.មិនត្រូវទទួល ឬជួបបុគ្គលមួយចំនួនដែលចង្អុលបង្ហាញដោយចៅក្រមស៊ើបសួរ

៩.ដាក់ប្រាក់ធានាដែលចំនួនប្រាក់ធានា និងថេរវេលាបង់ប្រាក់នេះត្រូវបានកំណត់ដោយចៅក្រមស៊ើបសួរ ដោយផ្អែកទៅលើធនធានរបស់ជនត្រូវចោទ

១០.មិនត្រូវកាន់កាប់ ឬយកតាមខ្លួននូវអាវុធ ត្រូវប្រគល់ជូនការិយាល័យក្រឡាបញ្ជី នូវអាវុធដែលជនត្រូវចោទកាន់កាប់

១១.ត្រូវប្រគល់ខ្លួនឲ្យពេទ្យពិនិត្យព្យាបាល និងជាយថាហេតុដាក់ឲ្យស្ថិតនៅក្រោមរបបព្យាបាលរោគនៅមន្ទីរពេទ្យ

១២.មិនត្រូវធ្វើសកម្មភាពខាងវិជ្ជាជីវៈខ្លះ។

ជនត្រូវចោទមានសិទ្ធិក្នុងការប្តឹងឧទ្ធរណ៍រយៈពេល០៥ថ្ងៃបន្ទាប់ពីទទួលដំណឹងពីដីកានេះ ជនត្រូវចោទមានសិទ្ធិក្នុងការប្តឹងទៅសភាស៊ើបសួរ នៃសាលាឧទ្ធរណ៍។

គ-បណ្តឹងឧទ្ធរណ៍ដោយដើមបណ្តឹងរដ្ឋប្បវេណី[165] ជាទូទៅបទល្មើសរក្សាទុក ដឹកជញ្ជូន ឬជួញដូរដោយខុសច្បាប់នូវសារធាតុញៀនពុំមានដើមបណ្តឹងរដ្ឋប្បវេណីទេ គឺមានតែបណ្តឹងអាជ្ញាតែប៉ុណ្ណោះ ។

រយៈពេលនៃបណ្តឹងឧទ្ធរណ៍ត្រូវកំណត់ដូចខាងក្រោម[166]៖

•អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ត្រូវធ្វើឡើងក្នុងរយៈពេល១(មួយ)ខែ យ៉ាងយូរគិតពីពេលប្រកាសដីកា។

•ព្រះរាជអាជ្ញា ត្រូវធ្វើឡើងក្នុងរយៈពេល៥(ប្រាំ)ថ្ងៃ ចាប់ពីថ្ងៃទទួលដំណឹងអំពីដីកាសម្រេច។

•ជនត្រូវចោទ ដើមបណ្តឹងរដ្ឋប្បវេណី ត្រូវធ្វើឡើងក្នុងរយៈពេល៥(ប្រាំ)ថ្ងៃ គិតចាប់ពីការបានទទួលដំណឹងពីដីកាសម្រេច។

[165] ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧, មាត្រា២៦៨

[166] ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧, មាត្រា២៧០

•បុគ្គលដែលនៅក្រៅនីតិវិធី ដែលជាអ្នកដាក់ពាក្យស្នើសុំវត្ថុចាប់យក ត្រូវធ្វើឡើងក្នុងរយៈពេល៥(ប្រាំ)ថ្ងៃ គិតចាប់ពីការទទួលដំណឹងអំពីដីកាសម្រេច។

**កថាខណ្ឌទី២៖ ការប្តឹងសុំមោឃភាពនីតិវិធី**

រាល់នីតិវិធីក្នុងរឿងព្រហ្មទណ្ឌ អាចត្រូវបានប្តឹងសុំមោឃភាពនីតិវិធី ប្រសិនបើការអនុវត្តមិនគោរព ឬអនុវត្តទៅតាមនីតិវិធីព្រហ្មទណ្ឌទេ ។ សភាស៊ើបសួរជាអ្នកសម្រេចអំពីសេចក្តីសម្រេចអំពីបណ្តឹងសុំមោឃភាពដោយការប្រកាសសេចក្តីសម្រេចនេះមិនអាចតវ៉ាបានទេ ។ សភាស៊ើបសួរអាចប្រកាសមិនទទួលពាក្យប្តឹងសុំមោឃកម្មនៅក្នុងករណីដូចខាងក្រោម[167]៖

១.ពាក្យប្តឹងគ្មានសំអាងហេតុ

២.ពាក្យប្តឹងសុំទាក់ទងនឹងដីកាដែលអាចប្តឹងឧទ្ធរណ៍បាន

៣.ពាក្យប្តឹងសុំគ្មានមូលកភាព[168]យ៉ាងជាក់ស្តែង

កាលណាដែលសភាស៊ើបសួរសម្រេចយល់ព្រមតាមពាក្យប្តឹង នោះសភាស៊ើបសួរត្រូវសម្រេចអំពីការមោឃកម្មនោះត្រូវធ្វើទៅលើកិច្ច ឬលិខិតផ្សេងទៀតដែរ ឬទេ ដោយកិច្ច ឬលិខិតដែលទុកជាមោឃនោះត្រូវដកចេញពីសំណុំរឿង ដោយរក្សាទុកនៅការិយាល័យក្រឡាបញ្ជីនៃសភាស៊ើបសួរ[169] ។

ក្នុងករណីសភាស៊ើបសួរសម្រេចពីពាក្យប្តឹងមោឃកម្មរួចរាល់ហើយ សភាស៊ើបសួរអាច[170]៖

១.បង្វិលសំណុំរឿងទៅចៅក្រមស៊ើបសួរវិញ សំដៅដល់ការបដិសេធលើពាក្យប្តឹងសុំ ហើយប្រគល់សំណុំរឿងទៅចៅក្រមស៊ើបសួរវិញដើម្បីបន្តនីតិវិធី

២.ដកសមត្ថកិច្ចចៅក្រមស៊ើបសួរ ហើយបញ្ជូនសំណុំរឿងទៅចៅក្រមស៊ើបសួរម្នាក់ផ្សេងទៀត សំដៅដល់ការដកហូតសំណុំរឿងរបស់ចៅក្រមស៊ើបសួរ និងប្រគល់សំណុំរឿងនោះទៅចៅក្រមស៊ើបសួរផ្សេងទៀតដើម្បីចាត់ការតាមនីតិវិធី។

៣.បន្តសមត្ថកិច្ចចៅក្រមស៊ើបសួរដោយខ្លួនឯងលើរឿងនោះ ដោយប្រធានសភាស៊ើបសួរអាចប្រគល់សិទ្ធិឲ្យទៅសមាជិកខ្លួនម្នាក់ដែលប្រើប្រាស់អំណាចជាចៅក្រមស៊ើបសួរ ។

ចំពោះបទល្មើសរក្សាទុក ដឹកជញ្ជូន ឬជួញដូរដោយខុសច្បាប់នូវសារធាតុញៀន គេសង្កេតឃើញក្នុងនីតិវិធីនៃការស៊ើបសួរគេអាចកត់សម្គាល់ចំណុចមួយចំនួនដែលអាចបណ្តាលឲ្យមានកំហុស និងបណ្តាលឲ្យមានការប្តឹងសុំមោឃភាពនីតិវិធីមានដូចខាងក្រោម៖

[167] ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧, មាត្រា២៧៩

[168] មូលកភាពសំដៅដល់ភាពសមហេតុសមផល ស្របតាមបញ្ញត្តិច្បាប់

[169] ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧, មាត្រា២៨០

[170] ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧, មាត្រា២៨១

ក.**សមត្ថកិច្ចដែនដីរបស់ចៅក្រមស៊ើបសួរ** ដោយកំណត់អំពីសមត្ថកិច្ចដែនដីដែលច្បាប់បានកំណត់ថា ចៅក្រមស៊ើបសួរដែលមានសមត្ថកិច្ចគឺចៅក្រមស៊ើបសួរនាទីកន្លែងបទល្មើស, ចៅក្រមស៊ើបសួរនាទីលំនៅឋាន ឬទីសំណាក់បុគ្គលដែលសង្ស័យថាបានប្រព្រឹត្តបទល្មើស និងចៅក្រមស៊ើបសួរនាទីកន្លែងចាប់ខ្លួនបុគ្គលដែលសង្ស័យថាបានប្រព្រឹត្តបទល្មើស[171] ។ ដោយការកំណត់នេះគឺ ដើម្បីឲ្យចៅក្រមស៊ើបសួរងាយស្រួលក្នុងការកំណត់នូវដែនសមត្ថកិច្ចរបស់ខ្លួន និងមិនប៉ះពាន់ដល់សមត្ថកិច្ចរបស់ចៅក្រមស៊ើបសួរ នៃសាលាដំបូងផ្សេងទៀត ។ ផ្ទុយទៅវិញប្រសិនបើមានករណីបទល្មើសដែលជាបទរក្សាទុក ដឹកជញ្ជូន និងជួញដូរដោយខុសច្បាប់នូវសារធាតុញៀន ដោយចៅក្រមស៊ើបសួរមានទំនាស់សមត្ថកិច្ច ហើយបានទទួលបណ្ដឹងទាំងអស់គ្នា អំពីរឿងព្រហ្មទណ្ឌអង្គហេតុតែមួយ ទំនាស់នោះត្រូវបានប្រធានសភាស៊ើបសួរជាអ្នកសម្រេច លើសពីនេះប្រសិនបើវិវាទសមត្ថកិច្ចដែនដី រវាងសភាស៊ើបសួរច្រើនត្រូវសម្រេចដោយប្រធានតុលាការកំពូល។

ខ.**ការស៊ើបសួរតាមដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួររបស់ព្រះរាជអាជ្ញា** ចៅក្រមស៊ើបសួរត្រូវកំណត់ឲ្យបាននូវការបំពេញកិច្ចស៊ើបសួររបស់ខ្លួន តាមរយៈដីការបស់ព្រះរាជអាជ្ញា ដោយមិនអាចស៊ើបសួរចំពោះអង្គហេតុផ្សេងក្រៅពីបទល្មើសដែលត្រូវបានចោទប្រកាន់ដោយព្រះរាជអាជ្ញា ឬដោយគ្មានដីកាសន្និដ្ឋានរបស់ព្រះរាជអាជ្ញាឡើយ[172] ។ ក្នុងករណីរកឃើញអង្គហេតុនៃបទល្មើសថ្មីចៅក្រមត្រូវជូនព័ត៌មានដល់ព្រះរាជអាជ្ញាដើម្បីធ្វើដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរបន្ថែម ហើយប្រសិនគ្មានដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរបន្ថែមនេះទេ ចៅក្រមគ្មានអំណាចក្នុងការស៊ើបសួរអំពីអង្គហេតុថ្មីនោះបានទេ។

គ.**អវត្តមានក្នុងនីតិវិធី** ចៅក្រម ឬក្រឡាបញ្ជី មិនត្រូវអវត្តមានក្នុងនីតិវិធីនៃការស៊ើបសួរណាមួយឡើយ លើសពីនេះ រាល់ការកត់ត្រា ការធ្វើកំណត់ហេតុលើការស្ដាប់ ឬសួរចម្លើយណាមួយឡើយ ដែលជាភារកិច្ចរបស់ក្រឡាបញ្ជី ដោយចៅក្រមមិនអាចគ្មានក្រឡាបញ្ជីអមឡើយ[173] ។ ហេតុនេះ ទើបរាល់ការធ្វើកំណត់ហេតុត្រូវមានការចុះហត្ថលេខា និងផ្ដិតស្នាមម្រាមដៃសមាសភាពចូលរួម ប្រសិនបើមិនមានបានចុះហត្ថលេខា និងការផ្ដិតស្នាមម្រាមដៃ ដោយមិនមានការបញ្ជាក់ត្រឹមត្រូវនោះទេ នោះសន្មតថាអវត្តមានក្នុងនីតិវិធី ដែលជាមូលហេតុនៃការសុំមោឃភាពនីតិវិធី។

ឃ.**វិធាន និងទម្រង់នៃកំណត់ហេតុ ឬដីកា** ដោយសំដៅទៅលើការគោរពនូវទម្រង់ណាមួយរបស់កំណត់ហេតុ ដោយកំណត់ហេតុត្រូវមានកំណត់អំពីកាលបរិច្ឆេទនៃការធ្វើកំណត់ហេតុ ត្រូវមានចុះហត្ថលេខា ឬស្នាមមេដៃ និងឈ្មោះរបស់សមាសភាពចូលរួម ។ ចំណែកវិធានដែលត្រូវបានកំណត់រួមមាន ការស៊ើបសួរត្រូវ

[171] ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧, មាត្រា១២៣
[172] ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧, មាត្រា១២៤ កថាខណ្ឌ៣
[173] ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧, មាត្រា១២៨

ធ្វើដោយខាននមិនបានចំពោះបទឧក្រិដ្ឋ ហើយចំពោះបទមជ្ឈិមការស៊ើបសួរអាចធ្វើក៏បាន ឬមិនធ្វើក៏បាន[174] ដោយវិធាននេះត្រូវតែគោរពតាម ផ្ទុយទៅវិញ ប្រសិនបើមិនគោរពទៅតាមបញ្ញត្តិនៃច្បាប់នោះទេ នោះនឹងក្លាយជាមូលហេតុមួយក្នុងការសុំមោឃភាពនីតិវិធីនៃការស៊ើបសួរ។

[174] ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧, មាត្រា១២២

# សេចក្តីសន្និដ្ឋាន

# សេចក្តីសន្និដ្ឋាន

ផ្អែកតាមខ្លឹមសារ និងអត្ថបទនៃការស្រាវជ្រាវ ដែលចងក្រងជាឯកសារសារណាខាងលើនេះ ខ្ញុំបាទយល់ឃើញថានីតិវិធីនៃការស៊ើបសួរចំពោះបទល្មើសរក្សាទុក ដឹកជញ្ជូន ឬជួញដូរដោយខុសច្បាប់នូវសារធាតុញៀននេះដែលរួមបញ្ចូលទាំងច្បាប់សារធាតុ និងច្បាប់នីតិវិធី ក្នុងដំណើរការនៃការប្រព្រឹត្តទៅចំពោះចំណាត់ការរបស់ចៅក្រមស៊ើបសួរ ពិតជាមានសារសំខាន់យ៉ាងខ្លាំងដល់ប្រយោជន៍របស់ជនត្រូវចោទ ឬជនជាប់ចោទក្នុងពេលសវនាការជំនុំជម្រះក្តី ។ ដំណាក់កាលនៃការស៊ើបសួរ គឺស្វែងរកឲ្យឃើញនូវការពិត ដោយរកឲ្យឃើញទាំងមូលហេតុក៏ដូចជាភស្តុតាងដោះបន្ទុក និងដាក់បន្ទុកលើជនត្រូវចោទ បើទោះជាជនត្រូវចោទបដិសេធថាខ្លួនមិនបានប្រព្រឹត្តដូចការចោទប្រកាន់របស់តំណាងអយ្យការក៏ដោយ ក៏ចៅក្រមស៊ើបសួរមានឆន្ទានុសិទ្ធិក្នុងការសម្រេចលើអង្គហេតុ និងភស្តុតាងដែលមានក្នុងសំណុំរឿង ។

ការស៊ើបសួរដោយមានចៅក្រមស៊ើបសួរមានឆន្ទានុសិទ្ធិគ្រប់គ្រាន់ក្នុងការសម្រេចអំពីការស៊ើបសួរ នៅក្នុងអង្គហេតុដែលតំណាងអយ្យការបានចោទប្រកាន់មកលើជនត្រូវចោទ ដោយអាចប្រគល់សិទ្ធិ និងបំពេញកិច្ចណាមួយដោយប្រើប្រាស់ដីកា ឬតាមរយៈការចុះពិនិត្យផ្ទាល់ដែលមានអមដោយក្រឡាបញ្ជី ដើម្បីធ្វើកំណត់ហេតុ និងកត់ត្រាអំពីលទ្ធផលដែលចុះពិនិត្យនោះ ក្នុងការធ្វើកោសលវិច័យលើវត្ថុតាងដែលមានតម្រុយជាគ្រឿងញៀននោះ គឺជាសមត្ថកិច្ចផ្តាច់មុខរបស់មន្ទីរពិសោធន៍ នៃអគ្គលេខាធិការអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន និងមានតែមួយប៉ុណ្ណោះដែលទទួលស្គាល់ដោយក្រសួងយុត្តិធម៌ ។ ក្នុងការស៊ើបសួរ ចៅក្រមស៊ើបសួរអាចប្រគល់វត្ថុដែលចាប់យកឲ្យទៅម្ចាស់ដើមវិញ ប្រសិនបើយល់ឃើញថា ការប្រគល់វត្ថុទាំងនោះមិនមានផលប៉ះពាល់ដល់នីតិវិធី នៃការស៊ើបសួររបស់ខ្លួនទេ ប៉ុន្តែវត្ថុដែលចាប់យកមួយចំនួនជាប្រភពព័ត៌មានដែលមានប្រយោជន៍ដល់ការស៊ើបសួរ ឬជាមធ្យោបាយសម្រាប់ប្រព្រឹត្តបទល្មើសចំពោះបទល្មើសគ្រឿងញៀន ចៅក្រមស៊ើបសួរអាចសម្រេចមិនប្រគល់ឡើយ ដោយភាគីអ្នកដាក់ពាក្យសុំវត្ថុនោះអាចប្រើប្រាស់សិទ្ធិក្នុងការប្តឹងទៅតុលាការជាន់ខ្ពស់ ដែលជាសភាស៊ើបសួរដើម្បីសម្រេចអំពីការស្នើសុំរបស់ខ្លួន ។ ក្នុងករណីលទ្ធផលដែលចេញពីមន្ទីរពិសោធន៍បញ្ជាក់ថាមានសារធាតុញៀន ឬវិជ្ជមានសារធាតុញៀន នោះត្រូវកំណត់អំពីប្រភេទនៃគ្រឿងញៀន សារធាតុសុទ្ធគិតជាភាគរយនៃសារធាតុញៀនដែលធ្វើកោសលវិច័យនោះ ព្រមទាំងកំណត់អំពីចំណាត់ថ្នាក់នៃគ្រឿងញៀន ដូចមានចែងក្នុង**មាត្រា៥** នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ដោយលទ្ធផលនេះហើយជាភស្តុតាងមួយដាក់ បន្ទុកលើជនត្រូវចោទ ។ ប៉ុន្តែក្នុងករណីដែលលទ្ធផលបញ្ជាក់ថា សារធាតុនោះមិនមានសារធាតុញៀន ឬអវិជ្ជមានសារធាតុញៀន នោះអាចជាមូលហេតុសម្រាប់ឲ្យចៅក្រមសម្រេចក្នុងការលើកលែងចោទប្រកាន់លើជនត្រូវចោទ និងដោះលែងជនត្រូវចោទឲ្យមានសេរីភាពវិញ ។ ផ្ទុយទៅវិញ ប្រសិនបើភស្តុតាងនៅតែបញ្ជាក់ថាជនត្រូវចោទរូបនោះបានប្រព្រឹត្តអំពើរក្សាទុក ដឹកជញ្ជូន ឬជួញដូរដោយខុសច្បាប់ ហើយបើទោះ

ជាលទ្ធផលកោសលវិច័យបញ្ជាក់ថាគ្មានសារធាតុញៀនក៏ដោយ ក៏ចៅក្រមអាចសម្រេចបញ្ជូនរឿងទៅតុលាការជំនុំជម្រះ ដោយសំអាងលើធាតុផ្សំនៃបទល្មើស ធាតុផ្សំអត្តនោម័ត ដែលបញ្ជាក់បានថាជនត្រូវចោទពិតជាមានចេតនាក្នុងការរក្សាទុក ដឹកជញ្ជូន ឬជួញដូរដោយខុសច្បាប់នូវគ្រឿងញៀននោះមែន រួមទាំងចម្លើយសារភាពគ្រប់ដំណាក់កាលអាចឲ្យចៅក្រមសម្រេចបានអំពីការបញ្ជូនជនត្រូវចោទ និងសំណុំរឿងនោះទៅជំនុំជម្រះ។

ប្រសិនបើចៅក្រមស៊ើបសួរយល់ឃើញថាការស៊ើបសួររបស់ខ្លួនចប់សព្វគ្រប់ហើយ ចៅក្រមស៊ើបសួរអាចបញ្ចប់ការស៊ើបសួររបស់ខ្លួន ដោយបញ្ជូនសំណុំរឿងដែលរួមមានភស្តុតាងដែលជាលទ្ធផលកោសលវិច័យនៃសារធាតុដែលមានតម្រុយជាគ្រឿងញៀននោះទៅតំណាងអយ្យការដើម្បីធ្វើការពិនិត្យ ថាការស៊ើបសួរនេះមានលក្ខណៈគ្រប់គ្រាន់សម្រាប់ដាក់បន្ទុកលើជនត្រូវចោទដែរ ឬទេ ។ ក្នុងករណីដែលតំណាងអយ្យការយល់ឃើញថាការស៊ើបសួរនៅខ្វះចន្លោះណាមួយ នោះតំណាងអយ្យការមានសិទ្ធិក្នុងការស្នើសុំឲ្យចៅក្រមស៊ើបសួរបំពេញកិច្ចស៊ើបសួរ ដោយមានចង្អុលបង្ហាញអំពីកិច្ច និងចំណុចដែលតំណាងអយ្យការយល់ឃើញថាមានប្រយោជន៍ដល់ការស៊ើបសួរ ។ ផ្ទុយទៅវិញប្រសិនបើតំណាងអយ្យការយល់ឃើញថាការស៊ើបសួរនេះមានលក្ខណៈគ្រប់គ្រាន់ និងមានភស្តុតាងដាក់បន្ទុកហើយ នោះតំណាងអយ្យការត្រូវធ្វើដីកាសន្និដ្ឋានស្ថាពរទៅចៅក្រមស៊ើបសួរក្នុងរយៈពេល១៥ថ្ងៃ ប្រសិនបើជនត្រូវចោទនៅក្នុងឃុំ និង១ខែប្រសិនបើជនត្រូវចោទនៅក្រៅឃុំ ដោយត្រូវបង្វិលសំណុំរឿងទៅចៅក្រមស៊ើបសួរ និងមានភ្ជាប់ដីកាសន្និដ្ឋានស្ថាពរទៅជាមួយផង ។ កិច្ចចុងបញ្ចប់នៃការស៊ើបសួរគឺចៅក្រមស៊ើបសួរត្រូវចេញដីកាដំណោះស្រាយ ដោយដីកានេះមានការបញ្ជូនជនត្រូវចោទទៅជំនុំជម្រះ ប្រសិនបើចៅក្រមស៊ើបសួរយល់ឃើញថានោះជា បទលហុ មជ្ឈិម ឬឧក្រិដ្ឋ និងសម្រេចលើកលែងចោទប្រកាន់បាន ដោយដីកាដំណោះស្រាយមិនជាប់កាតព្វកិច្ច ជាមួយដីកាសន្និដ្ឋានស្ថាពររបស់តំណាងអយ្យការទេ ចៅក្រមស៊ើបសួរអាចសម្រេចអំពីការលើកលែងចោទប្រកាន់ ឬបញ្ជូនរឿងទៅជំនុំជម្រះតាមការយល់ឃើញក៏ដូចជាភស្តុតាងដែលមានក្នុងសំណុំរឿង ។

សរុបសេចក្តីមក ប្រទេសកម្ពុជា ជាប្រទេសគោរពរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ១៩៩៣ សេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស កតិកាសញ្ញាអន្តរជាតិ អនុសញ្ញាអន្តរជាតិ និងច្បាប់នានា រួមមានច្បាប់សារធាតុ និងច្បាប់នីតិវិធី រួមទាំងលិខិតបទដ្ឋានគតិយុត្តផ្សេងៗ ដែលកំណត់នូវសិទ្ធិ សេរីភាព ការការពារបង្ការ ក៏ដូចជាទប់ស្កាត់ និងការដាក់ទណ្ឌកម្មលើជនដែលបានប្រព្រឹត្តអំពើដែលជាបទល្មើស ដោយផ្អែកតាមច្បាប់ជាធរមាន ដោយមានអំណាចតុលាការដែលជាអំណាចក្នុងការសម្រេចសេចក្តីអំពីការផ្តន្ទាទោស លើជនដែលបានប្រព្រឹត្តផ្ទុយទៅនឹងច្បាប់ ។ ដោយក្នុងនីតិវិធីតុលាការចំពោះបទល្មើសរក្សាទុក ដឹកជញ្ជូន ឬ ជួញដូរដោយខុសច្បាប់នូវសារធាតុញៀននោះ រួមមានស្ថាប័នអយ្យការដែលជាម្ចាស់នៃបណ្តឹងអាជ្ញា ក៏ដូចជា ចៅក្រមស៊ើបសួរជាអ្នកមានសមត្ថកិច្ចក្នុងការស្វែងរកឲ្យឃើញនូវការពិត ដោយរកទាំងមូលហេតុដោះ និងដាក់បន្ទុកលើ

ជនត្រូវចោទនោះ និងសម្រេចអំពីការបញ្ជូនជនត្រូវចោទ និងសំណុំរឿងទៅតុលាការជំនុំជម្រះ ឬលើកលែងចោទប្រកាន់លើជនត្រូវចោទ ។ ដូចគ្នានេះដែរ ក្នុងព្រឹត្តិការណ៍នៃទិវាអន្តរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន ដែលបានរៀបចំឡើងដោយអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន កាលពីថ្ងៃទី២៦ ខែមិថុនា ឆ្នាំ២០២២ ដោយនៅក្នុងព្រឹត្តិការណ៍ នៃទិវាអន្តរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀននេះនៅរាជធានីភ្នំពេញ តាមរយៈសារលិខិតលេខ ២៨ សលខ ចុះថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០២២ របស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា** បានរំលេច និងបញ្ជាឲ្យ "ត្រួតពិនិត្យសារធាតុឲ្យហ្មត់ចត់ ដើម្បីទប់ស្កាត់ការលួចបង្វែរពីជំនួញស្របច្បាប់យកទៅផលិតគ្រឿងញៀន នៅក្នុងប្រទេសកម្ពុជា" ក្នុងន័យនេះបញ្ជាក់ឲ្យឃើញថា រាជរដ្ឋាភិបាលកំពុងយកចិត្តទុកដាក់ និងតាមដាន ក៏ដូចជាការមើលឃើញនូវចំណុចដែលអាចនឹងមានការនាំចូលសារធាតុមួយចំនួនដើម្បីផលិតគ្រឿងញៀន តាមរយៈការប្រើប្រាស់រូបភាពស្របច្បាប់នៃការនាំចូលទំនិញ ក៏ដូចជាសារធាតុគីមីផ្សេងៗ ក្នុងគោលបំណងក្នុងការផលិតគ្រឿងញៀន ហើយនេះក៏ជាមធ្យោបាយក៏ដូចជា ចំណុចចាប់ផ្តើមដ៏សំខាន់មួយផងដែរ ដែលរាជរដ្ឋាភិបាលអាចសម្រេចបាននូវគោលដៅក្នុងការប្រឆាំង ការបង្ក្រាប ក៏ដូចជាបញ្ឈប់រាល់សកម្មភាពដែលជាបទល្មើសគ្រឿងញៀនកុំឲ្យមានតទៅទៀត នៅក្នុងប្រទេសកម្ពុជាយើង ។

# អនុសាសន៍

ជាចុងក្រោយ ដើម្បីចូលរួមក្នុងការកាត់បន្ថយ បង្ការ ទប់ស្កាត់ ប្រយុទ្ធប្រឆាំង និងពន្លឿនរាល់នីតិវិធីចំពោះបទល្មើសដែលពាក់ព័ន្ធជាមួយនឹងគ្រឿងញៀន ដើម្បីឲ្យប្រទេសជាតិមានសន្តិសុខសង្គម សណ្តាប់ធ្នាប់ព្រមទាំងបណ្តុះបណ្តាលជនទាំងឡាយ ដែលធ្លាប់បានប្រព្រឹត្តអំពើដែលជាបទល្មើសពាក់ព័ន្ធជាមួយនឹងគ្រឿងញៀន ខ្ញុំបាទសូមស្នើសុំផ្តល់នូវអនុសាសន៍ចំនួន៦(ប្រាំមួយ)ចំណុចសំខាន់ៗដូចខាងក្រោម៖

១-**ការរក្សាការសង្ងាត់ក្នុងការស៊ើបអង្កេត៖** ក្នុងចំណុចនេះខ្ញុំបាទយល់ឃើញថា ជាចំណុចសំខាន់មួយដែលបច្ចុប្បន្នក្នុងការស៊ើបអង្កេត ឃើញមានការបង្ហាញជាសាធារណៈនូវភិនភាគ សារតា ក៏ដូចជាវត្ថុតាងដែលជាគ្រឿងញៀនរបស់ជនសង្ស័យតាមរយៈបណ្តាញសង្គម ។ បើទោះជាជនសង្ស័យបានជាប់សង្ស័យពីបទល្មើសគ្រឿងញៀនណាមួយក៏ដោយ រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជាក៏ដូចជាច្បាប់ផ្សេងៗ បានការពារផលប្រយោជន៍របស់គាត់ ដោយពុំទាន់មានសាលក្រម ឬសាលដីកាស្ថាពរទេ ជននោះមិនទាន់ត្រូវបានគេចាត់ទុកថាជាជនដែលមានទោសទេ ហើយការបង្ហាញជាសាធារណៈបែបនេះ ពិតជាប៉ះពាល់ផលប្រយោជន៍របស់ជនសង្ស័យយ៉ាងខ្លាំង។

២-**ពង្រឹងលើការបង្ការ ទប់ស្កាត់ ប្រយុទ្ធប្រឆាំងគ្រឿងញៀន៖** ក្នុងចំណុចនេះយើងឃើញថាការប្រព្រឹត្តបទល្មើសដែលពាក់ព័ន្ធជាមួយគ្រឿងញៀន មានស្ទើគ្រប់ប្រទេសទូទាំងសកលលោកដែលក្នុងនោះប្រទេស កម្ពុជាក៏ជាប្រទេសមួយដែលកំពុងរកនូវផលប៉ះពាល់យ៉ាងខ្លាំងអំពីឥទ្ធិពល នៃគ្រឿងញៀន ដូចនេះការបង្ក្រាប រាល់បទល្មើសដែលពាក់ព័ន្ធជាមួយនឹងបទល្មើសគ្រឿងញៀន គប្បីមានការបង្ក្រាបដែលមានលក្ខណៈស្វែងរក ឲ្យឃើញនូវប្រភពនៃគ្រឿងញៀន ក៏ដូចជាកន្លែងដែលផលិតតាមរយៈជនដែលត្រូវបានឃាត់ខ្លួនពីបទល្មើសនោះ ដោយលើកទឹកចិត្តឲ្យជននោះចូលរួមក្នុងសកម្មភាពស្វែងរកប្រភពនៃការផលិតគ្រឿងញៀននោះ ឈានដល់ការបង្ក្រាបកន្លែងផលិតគ្រឿងញៀន។

៣-**ការព្យាបាល និងស្តារនីតិសម្បទា៖** ដោយជនដែលញៀនថ្នាំទាំងឡាយ ក្រៅពីជនដែលប្រព្រឹត្តបទល្មើសជួញដូរ ផលិត ដែលជាជនដែលមានបំណងត្រឹមតែទិញគ្រឿងញៀនយកមកប្រើប្រាស់តម្រូវឲ្យមានការព្យាបាល និងតាមដានយ៉ាងតឹងរឹងចំពោះអាការ ក៏ដូចជាស្ថានភាពរបស់ពួកគេទាំងស្ថាប័នរដ្ឋដែលរួមមាន មណ្ឌល និងកន្លែងបន្សាបគ្រឿងញៀនជាដើម ។ លើសពីនេះសេវាព្យាបាលតាមរយៈមន្ទីរពេទ្យឯកជនតម្រូវឲ្យមានតម្លៃសមរម្យ ក្នុងគោលបំណងជួយដល់សង្គមជាតិរបស់យើង។

៤-**ការពន្លឿននីតិវិធីច្បាប់៖** ការធ្វើកោសល្យវិច័យសព្វថ្ងៃ មានតែមន្ទីរពិសោធន៍នៃអគ្គលេខាធិការ នៃអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀនតែមួយប៉ុណ្ណោះ ដែលទទួលស្គាល់ដោយក្រសួងយុត្តិធម៌ ដែលចំនួននៃមន្ទីរពិសោធន៍នេះ មានលក្ខណៈតិចនៅឡើយ ដែលជាហេតុធ្វើឲ្យមានការយឺតយ៉ាវ

ចំពោះការធ្វើកោសលវិច័យ ដោយសាលាដំបូងដែលមានចម្ងាយឆ្ងាយមានផលពិបាកយ៉ាងខ្លាំង ចំពោះការដឹកជញ្ជូនសំណាកគ្រឿងញៀន ដើម្បីយកទៅធ្វើកោសលវិច័យ និងផ្ញើនូវលទ្ធផលកោសល-វិច័យមកសាលាដំបូងវិញ ហេតុនេះគប្បីបង្កើត និងអនុញ្ញាតឲ្យមានមន្ទីរពិសោធន៍បន្ថែមទៀតដើម្បីពន្លឿននូវការធ្វើកោសលវិច័យនេះ។

៥-**ការត្រួតពិនិត្យសារធាតុគីមីផ្សំ៖** ការត្រួតពិនិត្យសារធាតុគីមីផ្សំពិតជាមានសារសំខាន់ណាស់ ដែលការត្រួតពិនិត្យនេះគឺត្រួតពិនិត្យអំពីជំនួញ ឬសារធាតុគីមីផ្សំ ជៀងវាងការបំប្លែងសារធាតុគីមីផ្សំដែលជាទំនិញស្របច្បាប់ដោយបង្វែ ឬផលិតឲ្យក្លាយទៅជាសារធាតុញៀន ដូចនេះស្ថាប័នដែលពាក់ព័ន្ធលើការត្រួតពិនិត្យនេះគប្បីពិនិត្យអំពីបរិមាណ និងគោលបំណងក្នុងការនាំចេញ និងនាំចូលនូវសារធាតុគីមីនោះឲ្យបានត្រឹមត្រូវ និងតាមដានរាល់ការបម្លែងសារធាតុដែលជាជំនួញស្របច្បាប់នោះជៀសវាងការបង្វែសារធាតុនោះទៅជាសារធាតុញៀន។

៦-**ផ្តល់កញ្ចប់ថវិការ មធ្យោបាយ និងសម្ភារៈក្នុងការបំពេញភារកិច្ចរបស់មន្ត្រីមានសមត្ថកិច្ច៖** ដោយកញ្ចប់ថវិការនេះត្រូវមានលក្ខណៈមួយសមស្របទៅតាមបទល្មើស ដោយការស៊ើបអង្កេតមួយចំនួនតម្រូវឲ្យមាន ការប្រើប្រាស់ថវិការយ៉ាងច្រើនសម្រាប់ញុះញង់ឲ្យលក់នូវសារធាតុញៀននោះ ដែលថវិការទាំងនោះអាចត្រូវបានយកមកធ្វើជារូបភាពទិញលក់ ដោយក្នុងករណីមួយចំនួនថវិការត្រូវបានបាត់បង់ដោយសារការបង្ក្រាបមិនបានជោគជ័យ ឬករណីមួយចំនួនទៀតតម្រូវឲ្យមានការប្រើប្រាស់មធ្យោបាយផ្សេងៗ ក្នុងពេលប្រតិបត្តិការណ៍របស់មន្ត្រីនគរបាលយុត្តិធម៌។

# ឯកសារយោង

**១.លិខិតបទដ្ឋានគតិយុត្តជាតិ**

-រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ១៩៩៣។

-ក្រមព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៩។

-ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០១០។

-ច្បាប់ស្តីពីវិសោធនកម្មមាត្រា២៤៧ មាត្រា៣៦៨ មាត្រា៣៧២ និងមាត្រា៣៨២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០១៣។

-ច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ឆ្នាំ២០១១។

-ច្បាប់ស្តីពីយុត្តិធម៌អនីតិជន ឆ្នាំ២០១៦។

**២.លិខិតតូបករណ៍អន្តរជាតិស្តីពីសិទ្ធិមនុស្ស**

-សេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស របស់អង្គការសហប្រជាជាតិ ឆ្នាំ១៩៤៨។

**៣.ព្រះរាជក្រឹត្យ**

-ព្រះរាជក្រឹត្យលេខ នស/រកត/០៥០៩/៦០៨ ចុះថ្ងៃទី៣០ ខែឧសភា ឆ្នាំ២០០៩ ស្តីពីការរៀបចំ និងប្រព្រឹត្តទៅ នៃអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន។

**៤.អនុក្រឹត្យ**

-អនុក្រឹត្យលេខ ១៣ អនក្រ.បក ចុះថ្ងៃទី២២ ខែកុម្ភៈ ឆ្នាំ២០០៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់អគ្គលេខាធិការដ្ឋាន នៃអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន របស់រាជរដ្ឋាភិបាល។

**៥.ប្រកាស**

-ប្រកាសលេខ ០១០/ប្រក០៩ អ.ជ.ប.គ.ញ ស្តីពីតួនាទី ភារកិច្ច និងរចនាសម្ព័ន្ធ នាយកដ្ឋានអនុវត្តច្បាប់ នៃអគ្គលេខាធិការដ្ឋានអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន ចុះថ្ងៃទី១១ ខែមីនា ឆ្នាំ២០០៩ របស់អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន។

**៦.សេចក្តីសម្រេច និងសារលិខិត**

-សារលិខិតលេខ២៨ សលខ ចុះថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០២២ របស់រាជរដ្ឋាភិបាល។

-សេចក្តីសម្រេចស្តីពីការទទួលស្គាល់មន្ត្រីជំនាញក្នុងការធ្វើកោសលវិច័យគ្រឿងញៀន និងសារធាតុញៀនលេខ ១០កយ.សសរ/២១ ចុះថ្ងៃទី១៣ ខែមេសា ឆ្នាំ២០២១ របស់ក្រសួងយុត្តិធម៌។

**៧.សៀវភៅ**

-វចនានុក្រមសម្តេចព្រះសង្ឃរាជជួនណាត។

-លោកសាស្ត្រាចារ្យ រុន ពណ្ណរិទ្ធិ និងលោកស្រីសាស្ត្រាចារ្យ ចាំង ស៊ីណាត "នីតិវិធីព្រហ្មទណ្ឌ"។

-នាយឧត្តមសេនីយ៍ មាស វិរិទ្ធ អគ្គលេខាធិការ នៃអគ្គលេខាធិការដ្ឋានអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន "ការយល់ដឹងពីលក្ខណៈបច្ចេកទេសទាក់ទងនឹងបទល្មើសគ្រឿងញៀន"។

# ឧបសម្ព័ន្ធ

## បញ្ជីឧបសម្ព័ន្ធ

| លេខរៀង | បញ្ជីឧបសម្ព័ន្ធ |
|---|---|
| ឧបសម្ព័ន្ធទី១ | ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ |
| ឧបសម្ព័ន្ធទី២ | កំណត់ទទួលវត្ថុចាប់យក |
| ឧបសម្ព័ន្ធទី៣ | កំណត់ហេតុស្តីពីការបង្ហាញខ្លួនលើកដំបូង |
| ឧបសម្ព័ន្ធទី៤ | កំណត់ហេតុស្តីពីការពិភាក្សាដេញដោលចំពោះមុខ |
| ឧបសម្ព័ន្ធទី៥ | កំណត់ហេតុស្តីពីការសួរចម្លើយជនត្រូវចោទ |
| ឧបសម្ព័ន្ធទី៦ | ដីកាសម្រេចឲ្យឃុំខ្លួនបណ្តោះអាសន្ន |
| ឧបសម្ព័ន្ធទី៧ | ដីកាបង្គាប់ឲ្យឃុំខ្លួន |
| ឧបសម្ព័ន្ធទី៨ | ដីកាសម្រេចមិនឃុំខ្លួនបណ្តោះអាសន្ន |
| ឧបសម្ព័ន្ធទី៩ | ដីកាសម្រេចដាក់ជនត្រូវចោទឲ្យស្ថិតក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ |
| ឧបសម្ព័ន្ធទី១០ | ដីកាចាត់ឲ្យស៊ើបសួរជំនួស |
| ឧបសម្ព័ន្ធទី១១ | កំណត់ហេតុស្តីពីការបើក និងបិទសំណាកយកទៅធ្វើកោសលវិច័យ |
| ឧបសម្ព័ន្ធទី១២ | ដីកាចាត់តាំងអ្នកជំនាញ |
| ឧបសម្ព័ន្ធទី១៣ | អនុក្រឹត្យស្តីពីការបង្កើត និងប្រព្រឹត្តទៅនៃអគ្គលេខាធិការអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន |
| ឧបសម្ព័ន្ធទី១៤ | ចំណាត់ថ្នាក់នៃគ្រឿងញៀន |
| ឧបសម្ព័ន្ធទី១៥ | ដីកាបង្គាប់ឲ្យចូលខ្លួន |
| ឧបសម្ព័ន្ធទី១៦ | ដីកាបង្គាប់ឲ្យនាំខ្លួន |
| ឧបសម្ព័ន្ធទី១៧ | ដីកាបង្គាប់ឲ្យចាប់ខ្លួន |
| ឧបសម្ព័ន្ធទី១៨ | លិខិតជូនដំណឹងអំពីការបិទការស៊ើបសួរ |
| ឧបសម្ព័ន្ធទី១៩ | ដីកាបញ្ជូនសំណុំរឿងឲ្យពិនិត្យ |
| ឧបសម្ព័ន្ធទី២០ | ដីកាចាត់ឲ្យបំពេញកិច្ចស៊ើបសួរបន្ថែម |
| ឧបសម្ព័ន្ធទី២១ | ដីកាសន្និដ្ឋានស្ថាពរ |
| ឧបសម្ព័ន្ធទី២២ | ដីកាសម្រេចលើកលែងចោទប្រកាន់ |
| ឧបសម្ព័ន្ធទី២៣ | ដីកាបញ្ជូនសំណុំរឿងទៅជំនុំជម្រះ |
| ឧបសម្ព័ន្ធទី២៤ | ដីកាសម្រេចរក្សាជនជាប់ចោទក្នុងឃុំជាបណ្តោះអាសន្ន |
| ឧបសម្ព័ន្ធទី២៥ | លិខិតជូនដំណឹង ឬជូនព័ត៌មានស្តីពីការបញ្ជូនរឿងទៅជំនុំជម្រះ |
| ឧបសម្ព័ន្ធទី២៦ | សេចក្តីសម្រេចស្តីពីការទទួលស្គាល់មន្ត្រីជំនាញក្នុងការធ្វើកោសលវិច័យគ្រឿងញៀន និងសារធាតុញៀន របស់ក្រសួងយុត្តិធម៌ |

ឧបសម្ព័ន្ធទី១

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**អយ្យការអម**
**សាលាដំបូងរាជធានីភ្នំពេញ**

# ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ

## យើង ..... ព្រះរាជអាជ្ញារង នៃអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ

បានឃើញ សំណុំរឿងព្រហ្មទណ្ឌលេខ ... ចុះថ្ងៃទី ០២ ខែ មេសា ឆ្នាំ ២០១៩ របស់អយ្យការអមសាលាដំបូងរាជធានីភ្នំពេញ ។

បានឃើញ របាយការណ៍លេខ................... របស់មន្ទីរប្រឆាំងបទល្មើសគ្រឿងញៀននៃអគ្គស្នងការនគរបាលជាតិ ។

**ក្រោយពីបានពិនិត្យឯកសារខាងលើ**

យល់ឃើញថា មានតម្រុយសន្មតបានថា៖

១.នាមត្រកូល-នាមខ្លួន ..... ភេទប្រុស/ស្រី អាយុ...ឆ្នាំ មុខរបរ......... ជនជាតិខ្មែរ សាសនាព្រះពុទ្ធ ទីកន្លែងកំណើតនៅ... ទីលំនៅសព្វថ្ងៃស្នាក់នៅ.... រាជធានីភ្នំពេញ ឪពុកឈ្មោះ .... ម្ដាយឈ្មោះ ...... ប្រពន្ធឈ្មោះ .... មានកូនចំនួន០២ ទោសពីមុន.គ្មាន ជា-នីតិជន កំរិតវប្បធម៌..............។(ឃាត់ខ្លួន)

២.នាមត្រកូល-នាមខ្លួន ..... ភេទប្រុស/ស្រី អាយុ...ឆ្នាំ(គេចខ្លួន)

**បានប្រព្រឹត្តអំពើដូចតទៅ**

កាលពីថ្ងៃទី... ខែ... ឆ្នាំ២០.. វេលាម៉ោងប្រហែល២៣ និង៣០នាទី នៅត្រង់ចំណុចផ្លូវរថភ្លើង ក្រុមទី៣៩ ភូមិ៣ សង្កាត់ស្រះចក ខណ្ឌដូនពេញ រាជធានីភ្នំពេញ មានបទល្មើសព្រហ្មទណ្ឌមួយករណីកើតឡើង បង្ក ដោយជនត្រូវចោទឈ្មោះ ...... បានធ្វើសកម្មភាពលាក់ទុក ដាក់តាមខ្លួន ចរាចរ ចែកចាយ ដោយខុសច្បាប់នូវសារធាតុញៀន ហើយត្រូវបានកម្លាំងជំនាញមានសមត្ថកិច្ចធ្វើការឃាត់ខ្លួន និងដកហូតបានវត្ថុតាង (គ្រឿងញៀនក្រាមពណ៌សថ្លាប្រភេទមេតំហ្វេតាមីនចំនួន០៤កញ្ចប់ មានពីរកញ្ចប់តូច និងពីរបញ្ចប់ធំ) មានទម្ងន់ ១៩,៦៩(ដប់ប្រាំបួនក្បៀសហុកសិបប្រាំបួន)ក្រាម ជញ្ជីងសម្រាប់ថ្លឹងគ្រឿងញៀនចំនួន០២គ្រឿង, បំពង់សម្រាប់ច្រក គ្រឿងញៀនចំនួនមួយដើម, ថង់ប្លាស្ទិចតូចៗសម្រាប់ច្រកគ្រឿងញៀនមួយចំនួន, កញ្ចប់បារីម៉ាក MEVIUS ពណ៌ទឹកប៊ិកចំនួនមួយកញ្ចប់ ដាក់ស្ពែងតែម្ដង ។ បញ្ជាក់ នៅក្នុងអង្គហេតុនេះ ក៏មានជាប់ពាក់ព័ន្ធនឹងជនត្រូវចោទម្នាក់ទៀតឈ្មោះ .... ភេទប្រុស អាយុប្រហែល២៧ឆ្នាំ ដែលតែងតែយកថ្នាំញៀនលក់មកឲ្យជនត្រូវចោទឈ្មោះ ....... ដើម្បី ធ្វើការលក់ដូរ និងចែកចាយបន្ត។

អំពើខាងលើជាបទល្មើស ៖ ***រក្សាទុក ដឹកជញ្ជូន និងជួញដូរដោយខុសច្បាប់នូវសារធាតុញៀន*** ប្រព្រឹត្តនៅចំណុចផ្លូវរថភ្លើង ក្រុមទី៣៩ ភូមិ០៣ សង្កាត់ស្រះចក ខណ្ឌដូនពេញ រាជធានីភ្នំពេញ កាលពីថ្ងៃទី.. ខែ.. ឆ្នាំ២០.. តាមបញ្ញត្តិ**មាត្រា៤០** នៃច្បាប់ស្ដីពីការត្រួតពិនិត្យគ្រឿងញៀន។

**បានឃើញ** មាត្រា ៤៤ និង ១២៤ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ។

**ហេតុដូច្នេះសម្រេច**

**បើកការស៊ើបសួរលើអង្គហេតុខាងលើ ៖**

☐ ដាក់ឲ្យស្ថិតក្រោមការពិនិត្យលើ និងស្នើសុំ ៖

១.ឈ្មោះ ........... ភេទ....... អាយុ.......ឆ្នាំ (ឃាត់ខ្លួន)

២.ឈ្មោះ ........... ភេទ....... អាយុ.......ឆ្នាំ (គេចខ្លួន)

ពីបទ៖ **រក្សាទុក ដឹកជញ្ជូន និងជួញដូរដោយខុសច្បាប់នូវសារធាតុញៀន** ប្រព្រឹត្តនៅចំណុចផ្លូវរថភ្លើង ក្រុមទី៣៩ ភូមិ០៣ សង្កាត់ស្រះចក ខណ្ឌដូនពេញ រាជធានីភ្នំពេញ កាលពីថ្ងៃទី.. ខែ.. ឆ្នាំ២០.. តាមបញ្ញត្តិ**មាត្រា៤០** នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន

□ដាក់ឲ្យស្ថិតក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ

□ដាក់ឲ្យស្ថិតក្រោមការឃុំខ្លួនបណ្ដោះអាសន្នលើជនសង្ស័យខាងលើ

ថ្ងៃ.......................... ខែអាសាឍ ឆ្នាំ..... ឯកស័ក ព.ស ២៥៦៦

រាជធានីភ្នំពេញ ថ្ងៃទី... ខែ... ឆ្នាំ ២០...

**តំណាងអយ្យការ**

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូង និង អយ្យការអម
សាលាដំបូងរាជធានីភ្នំពេញ

## កំណត់ហេតុទទួលវត្ថុចាប់យក(១)

ពីរពាន់ម្ភៃមួយ ខែតុលា ថ្ងៃទីម្ភៃបី វេលាម៉ោងប្រាំបី និងសាមសិបប្រាំនាទីព្រឹក
នៅលេខាធិការដ្ឋានរដ្ឋបាលសាលាដំបូងរាជធានីភ្នំពេញ ។

យើង ក្រឡាបញ្ជីទទួលបន្ទុកឃ្លាំងវត្ថុចាប់យក ជា**អ្នកទទួល**
លោក មន្ត្រីនគរបាលយុត្តិធម៌ នៃមន្ទីរប្រឆាំងគ្រឿងញៀន(ក៥)ជា**អ្នកប្រគល់** ។
ដោយមានការចូលរួមពីជនសង្ស័យចំនួន៤នាក់ រួមមាន៖

ជនសង្ស័យឈ្មោះ
ជនសង្ស័យឈ្មោះ
ជនសង្ស័យឈ្មោះ
ជនសង្ស័យឈ្មោះ

ពាក់ព័ន្ធនឹងបទល្មើស **ដឹកជញ្ជូន និងជួញដូរដោយខុសច្បាប់នូវសារធាតុញៀន** ប្រព្រឹត្តនៅចំណុចភោជនីយដ្ឋាន រាជធានីភ្នំពេញ កាលពីថ្ងៃទី១៩ ខែតុលា ឆ្នាំ២០២១ វេលាម៉ោង១៣និង៥០នាទី ។

យើងបានពិនិត្យផ្ទៀងផ្ទាត់វត្ថុចាប់យក តាមកំណត់ហេតុចាប់យកសម្ភារៈ វត្ថុតាងលេខ០៧៦គណហ ចុះថ្ងៃ ទី១៩ ខែតុលា ឆ្នាំ២០២១ ,កំណតហេតុឃាត់ខ្លួនជាក់ស្ដែងលេខ , ថ្ងៃទី១៩ ខែតុលា ឆ្នាំ២០២១ របស់មន្ទីរប្រឆាំងគ្រឿងញៀន ដែលទាក់ទងនឹងសំណុំរឿងព្រហ្មទណ្ឌលេខ: ចុះថ្ងៃទី២២ ខែតុលា ឆ្នាំ២០២១ ឃើញដូចខាងក្រោម៖

| | | | | |
|---|---|---|---|---|
| ☐ អចលនវត្ថុ | ☐ ប្រាក់ | ☐ គ្រឿងញៀន | ☐ អាវុធ/គ្រឿងផ្ទុះ | |
| ☐ រថយន្ត | ☐ ម៉ូតូ | ☐ កុំព្យូទ័រ/ទូរទស្សន៍ | ☐ ទូរស័ព្ទ | ☐ ផ្សេងៗ |

១-កេសដែក ពណ៌ខៀវ មានបិតសៀលកំណត់ហេតុបិទកេសដែកវត្ថុតាង ដែលមានសរសេរថា ប្រភេទក្រាមពណ៌សថ្លា **ទម្ងន់២៨៤៧.០១ (ពីរពាន់ប្រាំបីរយសែសិបប្រាំពីរកណ្ដក់សញ្ញាសូន្យមួយ) ក្រាម (មេតំហ្វេតាមីន)** ដោយមានការចូលរួមផ្ដិតស្នាមមេដៃជនសង្ស័យឈ្មោះ

២-ទូរស័ព្ទដៃម៉ាក OPPO ពណ៌ខ្មៅ ចាសមិនដណោរការ ចនួន១គ្រឿង ត្រូវបានវេចខ្ចប់ដាក់ ក្នុងស្រោមសំបុត្របិតជិត ពណ៌គគីរ ចំនួន០១ ដែលមានផ្ដិតស្នាមមេដៃទទួលស្គាល់ពីជនសង្ស័យឈ្មោះ និងមានការចូលរួមចុះហត្ថលេខាពីសមត្ថកិច្ច និង ក្រឡាបញ្ជីផ្នែកវត្ថុចាប់យក។

៣-ទូរស័ព្ទដៃម៉ាក OPPO ពណ៌ខ្មៅ ចាស់មិនដំណើរការ ចំនួន១គ្រឿង ត្រូវបានវេចខ្ចប់ដាក់ ក្នុងស្រោមសំបុត្របិតជិត ពណ៌គគីរ ចំនួន០១ ដែលមានផ្ដិតស្នាមមេដៃទទួលស្គាល់ពីជនសង្ស័យឈ្មោះ និងមានការចូលរួមចុះ ហត្ថលេខាពីសមត្ថកិច្ច និង ក្រឡាបញ្ជីផ្នែកវត្ថុចាប់យក។

៤-ទូរស័ព្ទដៃម៉ាក VIVO ពណ៌ផ្ទៃមេឃ ចាស់បែកតួរ មិនដំណើរការ ចំនួន១គ្រឿង ត្រូវបានវេចខ្ចប់ដាក់ ក្នុងស្រោមសំបុត្របិតជិត ពណ៌គគីរ ចំនួន០១ ដែលមានផ្ដិតស្នាមមេដៃទទួលស្គាល់ពីជនសង្ស័យឈ្មោះ និងមានការចូល រួមចុះ ហត្ថលេខាពីសមត្ថកិច្ច និង ក្រឡាបញ្ជីផ្នែកវត្ថុចាប់យក។

៥-ទូរស័ព្ទដៃម៉ាក realme ពណ៌ក្រហម មិនដំណើរការ ចំនួន១គ្រឿង ត្រូវបានវេចខ្ចប់ដាក់ ក្នុងស្រោមសំបុត្របិតជិត ពណ៌គគីរ ចំនួន០១ ដែលមានផ្ដិតស្នាមមេដៃទទួលស្គាល់ពីជនសង្ស័យឈ្មោះ ងមានការចូលរួមចុះ ហត្ថលេខាពីសមត្ថកិច្ច និង ក្រឡាបញ្ជីផ្នែកវត្ថុចាប់យក។

៦-អត្តសញ្ញាប័ណ្ណសញ្ជាតិខ្មែរ លេខ០១១៨០៧៣៦៥ មានឈ្មោះ ។

៧-អត្តសញ្ញាប័ណ្ណសញ្ជាតិខ្មែរ លេខ០៧០

ក្រៅពីវត្ថុតាងដូចបានរៀបរាប់ខាងលើ យើងមិនបានទទួលអ្វីទៀតឡើយ ។

យើងធ្វើកំណត់ហេតុនេះ ដើម្បីទុកជាសំអាងក្នុងសំណុំរឿងព្រហ្មទណ្ឌលេខៈ ចុះថ្ងៃទី២២ ខែតុលា ឆ្នាំ២០២១ របស់សាលាដំបូងរាជធានីភ្នំពេញតាមផ្លូវច្បាប់តទៅ ។

បញ្ឈប់កំណត់ហេតុនេះនៅវេលាម៉ោងប្រាំបី និងហាសិបនាទីព្រឹកនាថ្ងៃខែឆ្នាំដដែល ។ (បញ្ជា)

**អ្នកប្រគល់** **ក្រឡាបញ្ជី** **ជនសង្ស័យ**

**បានឃើញ និង បង្គាប់ឲ្យរក្សាទុកតាមនីតិវិធី**
**តំណាងអយ្យការ**

ឧបសម្ព័ន្ធទី៣

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

សាលាដំបូងរាជធានីភ្នំពេញ

សំណុំរឿងព្រហ្មទណ្ឌលេខៈ ...
ចុះថ្ងៃទី.....
សំណុំរឿងស៊ើបសួរលេខៈ ...
ចុះថ្ងៃទី....

# កំណត់ហេតុស្តីពីការបង្ហាញខ្លួនលើកដំបូង

(មាត្រា ១៤៣ មាត្រា ១៤៤ មាត្រា ២៤០ និងមាត្រា ២៤១ នៃក្រមនីតិវិធីព្រហ្មទណ្ឌ)

ឆ្នាំពីរពាន់ម្ភៃពីរ ខែឧសភា ថ្ងៃទីប្រាំមួយ វេលាម៉ោងដប់ និងសូន្យនាទីព្រឹក។

លោកស្រី ............ ចៅក្រមស៊ើបសួរសាលាដំបូងរាជធានីភ្នំពេញ

អមដោយលោក ................ ក្រឡាបញ្ជីសាលាដំបូងរាជធានីភ្នំពេញ

បុគ្គលដែលនៅចំពោះមុខយើង បានផ្តល់នូវព័ត៌មានអំពីអត្តសញ្ញាណដូចខាងក្រោម៖

ឈ្មោះ **..........** ភេទប្រុស/ស្រី អាយុ.......ឆ្នាំ ជនជាតិខ្មែរ មុខរបរ...... ទីកន្លែងកំណើតនៅ ខេត្ត... មានទីលំនៅមុនឃាត់ខ្លួនស្នាក់នៅ.......... រាជធានីភ្នំពេញ នៅលីវ ប្រពន្ធ/ប្តីឈ្មោះ .......... មានកូន......នាក់ឪពុកឈ្មោះ **.........** (ស្លាប់/រស់) ម្តាយឈ្មោះ **..........** (ស្លាប់/រស់) ជានីតិជន/អនីតិជន ទោសពីមុនគ្មាន/មាន(ធ្លាប់ជាប់........)។

☐ ជននេះ ចេះនិយាយ ចេះអាន ចេះសរសេរអក្សរខ្មែរ

☐ជននេះ ☐ មិនចេះនិយាយ ☐ មិនចេះអាន ☐ មិនចេះសរសេរអក្សរខ្មែរ (អត់ចេះ)

បន្ទាប់ពីបានផ្ទៀងផ្ទាត់អត្តសញ្ញាណរបស់ជននេះ យើងបានប្រាប់ដល់ជននេះឱ្យដឹងយ៉ាងច្បាស់អំពីរឿងរ៉ាវដែលព្រះរាជអាជ្ញាបានប្តឹងមកយើង តាមរយៈដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរលេខ **...........** ចុះថ្ងៃទី.... ខែ.... ឆ្នាំ២០២២ ដែលជាហេតុនាំឱ្យមានការបង្ហាញជននេះនៅចំពោះមុខយើងព្រមទាំងប្រាប់ជននេះឱ្យដឹងអំពីបទចោទប្រកាន់ចំពោះរឿងរ៉ាវដូចខាងក្រោម៖

ពីបទ ***រក្សាទុក ដឹកជញ្ជូន និងជួញដូរដោយខុសច្បាប់ដោយសារធាតុញៀន*** ប្រព្រឹត្តនៅចំណុច...... រាជធានីភ្នំពេញ កាលពីថ្ងៃទី......ខែ....... ឆ្នាំ២០២២ តាមបញ្ញត្តិឱ្យផ្តន្ទាទោសតាមមាត្រា៤០ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។

☐ លោក **................** មេធាវី នៃជនត្រូវចោទដែលត្រូវបានកោះហៅ។

☐យើងបានប្រាប់ដល់ជននេះអំពីសិទ្ធិទទួលបានជំនួយមេធាវី ដែលជននេះអាចជ្រើសរើសពឹងមេធាវីដោយខ្លួនឯង ឬអាចសុំឱ្យគេចាត់តាំងមេធាវីណាម្នាក់ឱ្យរូបគាត់។

☐យើងបានប្រាប់ផងដែរដល់ជននេះថា ប្រសិនបើមិនធ្វើការជ្រើសរើសពឹងមេធាវីដោយខ្លួនឯងទេ មេធាវីមួយរូប នឹងត្រូវចាត់តាំងដោយឯកឯងដោយសារតែជននេះជាអនីតិជន។

+ជននេះបានប្រកាសប្រាប់ថា៖

☐ ខ្ញុំជ្រើសរើសមេធាវីដោយខ្លួនឯង

☐ ខ្ញុំស្នើសុំឱ្យចាត់តាំងមេធាវីមួយរូបឱ្យខ្ញុំ

☐ ខ្ញុំបដិសេធជំនួយពីមេធាវី

យើងបានប្រាប់ដល់ជនត្រូវចោទថា គាត់មានសិទ្ធិអាចនៅស្ងៀមមិនផ្តល់ចម្លើយក៏បាន ឬអាចធ្វើសេចក្តីប្រកាស ផ្សេងៗ ឬអាចឲ្យយើងសួរចម្លើយក៏បាន។

ជននេះបានប្រកាសប្រាប់ថា ខ្ញុំអាចឆ្លើយបានដោយខ្លួនឯងនៅពេលនេះចំពោះរឿងរ៉ាវដែលកើតឡើង។

លោកមេធាវី ......... បានផ្តល់សេចក្តីកត់សម្គាល់ការពារថា ៖ ............................................. ។

យើងបានជូនដំណឹងដល់ជននេះថា យើងសម្រេចដាក់គាត់ឲ្យស្ថិតនៅក្រោមការពិនិត្យ៖

☐ចំពោះអង្គហេតុទាំងអស់ដែលយើងបានប្រាប់ឲ្យដឹង។

ចំពោះតែអង្គហេតុដែលរៀបរាប់ខាងក្រោមដែលយើងបញ្ជាក់ប្រាប់ជននេះអំពីឈ្មោះនៃបល្មើសគឺពីបទពីបទ

ពីបទ **រក្សាទុក ដឹកជញ្ជូន និងជួញដូរដោយខុសច្បាប់ដោយសារធាតុញៀន** ប្រព្រឹត្តនៅចំណុច.............. រាជធានីភ្នំពេញ កាលពីថ្ងៃទី.....ខែ.... ឆ្នាំ២០២២ តាមបញ្ញត្តិឲ្យផ្តន្ទាទោសតាមមាត្រា៤០ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។

យើងបានប្រាប់ដល់ជនត្រូវចោទអំពីសិទ្ធិក្នុងការជ្រើសរើសមេធាវីសម្រាប់នីតិវិធីបន្ទាប់មកទៀត ហើយប្រសិន បើមិនបានធ្វើការជ្រើសរើសមេធាវីដោយខ្លួនឯងទេ នឹងបើសិនជាមានសំណើសុំយើងនឹងចាត់តាំងមេធាវីមួយរូបជូន (សម្រាប់តែក្នុងករណីដែលជនត្រូវចោទមិនបានជ្រើសរើសពឹងពាក់មេធាវីដោយខ្លួនឯង និងមិនបានស្នើសុំឲ្យចាត់តាំងមេធាវីឲ្យ)។

+ជននេះបានប្រកាសប្រាប់ថា៖

☐ខ្ញុំជ្រើសរើសមេធាវីដោយខ្លួនឯង

☐ខ្ញុំស្នើសុំឲ្យចាត់តាំងមេធាវីមួយរូបឲ្យខ្ញុំ

☐ខ្ញុំបដិសេធជំនួយពីមេធាវី

☐យើងបានប្រាប់ដល់ជនត្រូវចោទថា គាត់អាចសុំឲ្យបិទការស៊ើបសួរបាននៅក្រោយពេលផុតរយៈពេលមួយឆ្នាំ ដោយអនុវត្តតាមបទបញ្ញត្តិនៃមាត្រា ២៨៦ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។

☐យើងបានប្រាប់ដល់ជនត្រូវចោទថា នៅថ្ងៃនេះ យើងសម្រេចដាក់គាត់ឲ្យនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ និងប្រាប់គាត់អំពីកាតព្វកិច្ចទាំងឡាយដែលគាត់ត្រូវគោរព។

☐យើងបានប្រាប់ដល់ជនត្រូវចោទថា យើងសម្រេចមិនឃុំខ្លួនជាបណ្តោះអាសន្ន។

☐យើងបានប្រាប់ដល់ ជនត្រូវចោទថា៖

គាត់ត្រូវប្រកាសប្រាប់ពីអាសយដ្ឋានដែលអាចជាអាសដ្ឋានផ្ទាល់ខ្លួន ឬជាអាសយដ្ឋានរបស់តតិយជនណាម្នាក់ ដែលទទួលបន្ទុកទទួលយកលិខិត ដែលបញ្ជូនទៅឲ្យគាត់ ប្រសិនបើគាត់អាចផ្តល់ឲ្យភ្ជាមនូវការព្រមព្រៀងជាលាយ លក្ខណ៍អក្សររបស់តតិយជននោះ។

អាសយដ្ឋានដែលត្រូវប្រកាសត្រូវមានទីតាំងស្ថិតនៅ **(អាសយដ្ឋានខាងលើ)**។

ជនត្រូវចោទបានប្រកាសអាសយដ្ឋានដូចខាងក្រោម៖

☐អាសយដ្ឋាននេះ ជាអាសយដ្ឋាន បន្ទប់ជួល។

☑យើងបានប្រកាសដល់ជនត្រូវចោទបន្ថែម៖

រហូតដល់ការបិទការស៊ើបសួរ គាត់ត្រូវប្រាប់យើងគ្រប់ការផ្លាស់ប្តូរអាសយដ្ឋាន ដែលបានប្រកាសប្រាប់ខាងលើដោយការប្រកាសជាថ្មី ឬដោយលិខិតអនុសិដ្ឋ។

គ្រប់ការជូនដំណឹង ឬការឲ្យដំណឹងដែលបញ្ជូនទៅអាសយដ្ឋាន ដែលបានប្រកាសប្រាប់ចុងក្រោយបង្អស់ត្រូវចាត់ទុកថាជូនដំណឹងដល់បុគ្គលជនត្រូវចោទ។

☐យើងបានឲ្យជនត្រូវចោទអានឡើងវិញនូវសេចក្តីប្រកាសទាំងអស់របស់ខ្លួន ដែលយើងបានកត់ចម្លងចូលក្នុងកំណត់ហេតុនេះ ហើយបើមិនបដិសេធត្រង់ចំណុចណាទេ ឲ្យចុះហត្ថលេខាលើកំណត់ហេតុនេះ។

☐យើងបានអានស្តាប់ចប់សព្វគ្រប់ ហើយជនត្រូវចោទមិនមានបដិសេធចំណុចណាទេ និងបានចុះហត្ថលេខាជាមួយយើង និងក្រឡាបញ្ជី។

☐បានអានចប់សព្វគ្រប់ដោយអ្នកបកប្រែ ហើយជនត្រូវចោទមិនមានបដិសេធចំណុចណាទេ និងបានចុះហត្ថលេខាជាមួយយើងក្រឡាបញ្ជី និងអ្នកបកប្រែ។

**ជនត្រូវចោទ មេធាវី អ្នកបកប្រែ ក្រឡាបញ្ជី ចៅក្រមស៊ើបសួរ**

ឧបសម្ព័ន្ធទី៤

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

សាលាដំបូងរាជធានីភ្នំពេញ

សំណុំរឿងព្រហ្មទណ្ឌលេខ៖ ......

ចុះថ្ងៃទី.....

សំណុំរឿងស៊ើបសួរលេខ៖ ......

ចុះថ្ងៃទី....

# **<u>កំណត់ហេតុស្តីពី</u>**

# **<u>ការពិភាក្សាដេញដោលចំពោះមុខ</u>**

(មាត្រា ២០៣ និងមាត្រាបន្តបន្ទាប់ នៃក្រមនីតិវិធីព្រហ្មទណ្ឌ)

ឆ្នាំពីរពាន់ម្ភៃពីរ ខែឧសភា ថ្ងៃប្រាំមួយ វេលាដប់ និងសូន្យនាទីព្រឹក។

លោកស្រី ............ ចៅក្រមស៊ើបសួរសាលាដំបូងរាជធានីភ្នំពេញ

អមដោយលោក ........... ក្រឡាបញ្ជីសាលាដំបូងរាជធានីភ្នំពេញ

យោងតាមដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរលេខ **.........** ចុះថ្ងៃទី.... ខែ...... ឆ្នាំ២០២២។

បុគ្គលដែលនៅចំពោះមុខយើង បានផ្តល់នូវព័តមានអំពីអត្តសញ្ញាណដូចខាងក្រោម៖

ឈ្មោះ **..........** ភេទប្រុស/ស្រី អាយុ.......ឆ្នាំ ជនជាតិខ្មែរ មុខរបរ...... ទីកន្លែងកំណើតនៅ ខេត្តតាកែវ មានទីលំនៅមុនឃាត់ខ្លួនស្នាក់នៅ.......... រាជធានីភ្នំពេញ នៅលីវ ប្រពន្ធ/ប្តីឈ្មោះ .......... មានកូន......នាក់ឪពុកឈ្មោះ **.........** (ស្លាប់/រស់) ម្តាយឈ្មោះ **..........** (ស្លាប់/រស់) ជានីតិជន/អនីតិជន ទោសពីមុនគ្មាន/មាន(ធ្លាប់ជាប់........)។

ពីបទ ***រក្សាទុក ដឹកជញ្ជូន និងជួញដូរដោយខុសច្បាប់ដោយសារធាតុញៀន*** ប្រព្រឹត្តនៅចំណុច.............. រាជធានីភ្នំពេញ កាលពីថ្ងៃទី...ខែ...... ឆ្នាំ២០២២ តាមបញ្ញត្តិឲ្យផ្តន្ទាទោសតាមមាត្រា៤០ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។

ដោយមានលោក **.................** ដែលជនត្រូវចោទបានជ្រើសរើសពឹងពាក់ដោយខ្លួនឯង ឬដែលត្រូវបានចាត់តាំងដោយគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា បានមកបង្ហាញនៅចំពោះមុខយើង បន្ទាប់ពីបាន ពិគ្រោះមើលសំណុំរឿង និងបានធ្វើទំនាក់ទំនងដោយសេរីជាមួយ នឹងជនត្រូវចោទ នៅពេលបង្ហាញខ្លួនជាលើកដំបូង ។

យើងបានប្រាប់ដល់ជនត្រូវចោទថា៖

☐យើងមានបំណងសម្រេចឃុំខ្លួន ជនត្រូវចោទជាបណ្តោះអាសន្ន។

☐ជនត្រូវចោទអាចស្នើសុំពន្យាពេល ដើម្បីរៀបចំការពារខ្លួន។

☐យើងនឹងសម្រេចអំពីការឃុំខ្លួនបណ្តោះអាសន្ននៅថ្ងៃនេះ។

ជនត្រូវចោទបានប្រកាសប្រាប់ថា ៖

ការពិភាក្សាដេញដោលចំពោះ

មុខទាក់ទង និងការឃុំខ្លួនបណ្តោះអាសន្ន៖

☐ត្រូវបានធ្វើ

□ត្រូវបានលើកទៅថ្ងៃទី.... ខែ.......ឆ្នាំ..........តាមសំណូមពររបស់..........................................

តំណាងអយ្យការបានបង្ហាញនូវសេចក្តីសន្និដ្ឋានរបស់ខ្លួនដូចខាងក្រោម៖ សុំឲ្យតុលាការការសម្រេចឃុំខ្លួនជន ត្រូវចោទតាមនីតិវិធី។

ជនត្រូវចោទបង្ហាញសេចក្តីសន្និដ្ឋានរបស់ខ្លួនដូចខាងក្រោម៖ ខ្ញុំសុំជំទាស់ការឃុំខ្លួនបណ្តោះអាសន្នរបស់លោកស្រីចៅក្រមស៊ើបសួរ។

លោកមេធាវី ..................... បានបង្ហាញសេចក្តីសន្និដ្ឋានរបស់ខ្លួនដូចខាងក្រោម៖.......................។

យើងបានប្រាប់ដល់ជនត្រូវចោទថា យើងសម្រេចចេញដីកាសម្រេចឲ្យឃុំខ្លួនជនត្រូវចោទបណ្តោះអាសន្នដោយ មានសំអាងហេតុ ហើយយើងសម្រេចចេញដីកាបង្គាប់ឲ្យឃុំខ្លួននៅថ្ងៃនេះ។

□យើងបានឲ្យជនត្រូវចោទអានឡើងវិញនូវសេចក្តីប្រកាសទាំងអស់របស់ខ្លួន ដែលយើងបានកត់ចម្លងចូលក្នុងកំណត់ហេតុនេះ ហើយបើមិនបដិសេធត្រង់ចំណុចណាទេ ឲ្យចុះហត្ថលេខាលើកំណត់ហេតុនេះ។

□យើងបានអានស្តាប់ចប់សព្វគ្រប់ ហើយជនត្រូវចោទមិនមានបដិសេធចំណុចណាទេ និងបានចុះហត្ថលេខាជាមួយយើង និងក្រឡាបញ្ជី។

□បានអានចប់សព្វគ្រប់ដោយអ្នកបកប្រែ ហើយជនត្រូវចោទមិនមានបដិសេធចំណុចណាទេ និងបានចុះហត្ថលេខាជាមួយយើងក្រឡាបញ្ជី និងអ្នកបកប្រែ។

**ជនត្រូវចោទ មេធាវី អ្នកបកប្រែ ក្រឡាបញ្ជី ចៅក្រមស៊ើបសួរ**

ឧបសម្ព័ន្ធទី៥

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**សាលាដំបូងរាជធានីភ្នំពេញ**

# កំណត់ហេតុស្តីពីការសួរចម្លើយជនត្រូវចោទ

សំណុំរឿងព្រហ្មទណ្ឌលេខ៖ ......
ចុះថ្ងៃទី.....
សំណុំរឿងស៊ើបសួរលេខ៖ ......
ចុះថ្ងៃទី....

(១៤៥ និងមាត្រាបន្តបន្ទាប់ នៃក្រមនីតិវិធីព្រហ្មទណ្ឌ)

ឆ្នាំពីរពាន់ម្ភៃពីរ ខែឧសភា ថ្ងៃទីប្រាំមួយ វេលាម៉ោងដប់នាទីព្រឹក។

លោកស្រី .............. ចៅក្រមស៊ើបសួរសាលាដំបូងរាជធានីភ្នំពេញ

អមដោយលោក ......... ក្រឡាបញ្ជីសាលាដំបូងរាជធានីភ្នំពេញ

និងមានលោក **................** ជាមេធាវីការពារក្តីឲ្យជនត្រូវចោទ

បានមកបង្ហាញខ្លួនក្នុងនាមជនត្រូវចោទនៅក្នុងមន្ទីរស៊ើបសួរនៅចំពោះមុខយើងជនដែលមានសញ្ញាណដូចខាងក្រោម៖

ឈ្មោះ **..........** ភេទប្រុស/ស្រី អាយុ.......ឆ្នាំ ជនជាតិខ្មែរ មុខរបរ...... ទីកន្លែងកំណើតនៅ ខេត្តតាកែវ មានទីលំនៅមុនឃាត់ខ្លួនស្នាក់នៅ.......... រាជធានីភ្នំពេញ នៅលីវ ប្រពន្ធ/ប្ដីឈ្មោះ .......... មានកូន......នាក់ឪពុកឈ្មោះ **.........** (ស្លាប់/រស់) ម្ដាយឈ្មោះ **........** (ស្លាប់/រស់) ជានីតិជន/អនីតិជន ទោសពីមុនគ្មាន/មាន(ធ្លាប់ជាប់..........)។

☐ជននេះ៖ ☐ចេះនិយាយ ☐ចេះអាន ☐ចេះសរសេរអក្សរខ្មែរ (ចេះ)

☐ជននេះ៖ ☐មិនចេះនិយាយ ☐មិនចេះអាន ☐មិនេចះសរសេរអក្សរខ្មែរ

បន្ទាប់ពីបានផ្ទៀងផ្ទាត់អត្តសញ្ញាណរបស់ជននេះ យើងបានប្រាប់ដល់ជននេះឲ្យដឹងយ៉ាងច្បាស់អំពីរឿងរ៉ាវដែលព្រះរាជអាជ្ញាបានប្ដឹងមកយើង តាមរយៈដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរលេខ **..........** ចុះថ្ងៃទី......ខែ......។ ឆ្នាំ២០២២។

យើងបានសួរចម្លើយឈ្មោះនេះ ហើយឈ្មោះនេះបានឆ្លើយប្រាប់យើងដូចខាងក្រោមថា៖

សួរ-ឆ្លើយ៖ ខ្ញុំបាទអាចឆ្លើយបានដោយខ្លួនឯងចំពោះរឿងរ៉ាវដែលបានកើតឡើងនៅពេលនេះ បានដោយពុំមានមេធាវីការពារសិទ្ធិឲ្យខ្ញុំបាទ។

សួរ/ឆ្លើយ៖ ខ្ញុំបាទទទួលស្គាល់ចម្លើយដែលបានឆ្លើយនៅដំណាក់កាលមន្ត្រីនគរបាលយុត្តិធម៌តែសុំបដិសេធចំណុចដែលថាខ្ញុំបាទជួញដូរគ្រឿងញៀន ចំពោះចម្លើយនៅដំណាក់កាលអយ្យការ រក្សាទុកជាបានការដដែល។

សួរ/ឆ្លើយ៖ ....................................។

សួរ/ឆ្លើយ៖ វត្ថុតាងដែលបានដកហូតពីខ្ញុំមានដូចជាថ្នាំញៀនចំនួន១០កញ្ចប់ធំ រថយន្តម៉ាកតាកូម៉ាមួយគ្រឿង អត្តសញ្ញាណប័ណ្ណ០១សន្លឹក...............។

សួរ/ឆ្លើយ៖ ខ្ញុំបាទសំណូមពរសុំអោយតុលាការជួយបន្ធូរបន្ថយទោសឲ្យខ្ញុំបាទផង ខ្ញុំបាទដឹងខ្លួនខុសហើយ។

☐យើងបានឲ្យជនត្រូវចោទអានឡើងវិញនូវចម្លើយទាំងអស់របស់ខ្លួន ដែលយើងបានកត់ចម្លងចូលក្នុងកំណត់នេះ ហើយបើមិនបដិសេធគ្រង់ចំណុចណាទេ ឲ្យចុះហត្ថលេខាលើកំណត់ហេតុនេះ។

□បានអានចប់សព្វគ្រប់ ហើយជនត្រូវចោទមិនមានបដិសេធចំណុចណាទេ និងបានចុះហត្ថលេខាជាមួយយើង និងក្រឡាបញ្ជី។

បញ្ចប់កំណត់ហេតុនៅវេលាម៉ោងដប់មួយ និងសូន្យនាទីព្រឹក ថ្ងៃខែឆ្នាំដូចខាងលើ ។

**ជនត្រូវចោទ មេធាវី អ្នកបកប្រែ ក្រឡាបញ្ជី ចៅក្រមស៊ើបសួរ**

ឧបសម្ព័ន្ធទី៦

# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូងរាជធានីភ្នំពេញ

បន្ទប់ស៊ើបសួរ "..."

លេខ.........................

## ដីកាសម្រេចឲ្យឃុំខ្លួនបណ្តោះអាសន្ន

យើង ....... ចៅក្រមស៊ើបសួរនៃសាលាដំបូងរាជធានីភ្នំពេញ អមដោយលោក ......ជាក្រឡាបញ្ជី។

**បានឃើញមាត្រា២០៥** ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី.. ខែ.. ឆ្នាំ២០០៧។

**បានឃើញ**សំណុំរឿងព្រហ្មទណ្ឌលេខ **......** ចុះថ្ងៃទី... ខែ.. ឆ្នាំ២០២២ ។

**បានឃើញ**ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរលេខ **........** ចុះថ្ងៃទី...... ខែ....... ឆ្នាំ២០២២ របស់តំណាងអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ ។

**បានឃើញ**សំណុំរឿងស៊ើបសួរលេខ **.........** ចុះថ្ងៃទី.... ខែ...... ឆ្នាំ២០២២ ។

ដែលទាក់ទងនឹងជនត្រូវចោទឈ្មោះ ...... ភេទប្រុស/ស្រី អាយុ......ឆ្នាំ សញ្ជាតិខ្មែរ មុខរបរ...... ទីកន្លែងកំណើតនៅ...... ទីលំនៅមុនពេលឃាត់ខ្លួនស្នាក់នៅ...... រាជធានីភ្នំពេញ នៅលីវ/ប្រពន្ធ/ប្តីឈ្មោះ...... ឪពុកឈ្មោះ ...... (រ/ស) ម្តាយឈ្មោះ ...... (រ/ស) ជានីតិជន/អនីតិជន ទោសពីមុនគ្មាន/ធ្លាប់ជាប់......។

ជននេះត្រូវដាក់ឲ្យនៅក្រោមការពិនិត្យពីបទ៖ **រក្សាទុក ដឹកជញ្ជូន និងជួញដូរដោយខុសច្បាប់នូវសារធាតុញៀន** ប្រព្រឹត្តនៅ...... រាជធានីភ្នំពេញ កាលពីថ្ងៃទី...... ខែ...... ឆ្នាំ២០២២ តាមបញ្ញត្តិ**មាត្រា៤០** នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ។

-បានឃើញកំណត់ហេតុស្តីពីការបង្ហាញខ្លួនលើកដំបូង ។

-បានឃើញកំណត់ហេតុស្តីពីការពិភាក្សាដេញដោល និងការកត់សម្គាល់របស់ភាគី។

I-**<u>ស្ថានភាពអង្គហេតុ និងអង្គច្បាប់</u>**៖

**១**-ក្នុងករណីបច្ចុប្បន្នជនត្រូវចោទឈ្មោះ ...... ភេទប្រុស/ស្រី អាយុ......ឆ្នាំ សញ្ជាតិខ្មែរ ត្រូវបានចោទពីបទ **រក្សាទុក ដឹកជញ្ជូន និងជួញដូរដោយខុសច្បាប់នូវសារធាតុញៀន** ប្រព្រឹត្តនៅ...... រាជធានីភ្នំពេញ កាលពីថ្ងៃទី...... ខែ...... ឆ្នាំ២០២២ តាមបញ្ញត្តិ**មាត្រា៤០** នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀនតាមដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរលេខ **......** ចុះថ្ងៃទី.... ខែ... ឆ្នាំ២០២២ របស់តំណាងអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ។

**២**-តំណាងអយ្យការបានស្នើឲ្យឃុំខ្លួនលើជនត្រូវចោទឈ្មោះ **...........** ដោយសំអាងហេតុថា៖ ការឃុំខ្លួន បណ្តោះអាសន្នជាមូលហេតុតែមួយគត់ដើម្បីបញ្ចប់បទល្មើស ឬបង្ការបទល្មើសកុំឲ្យកើតជាថ្មី និងធានារក្សាជនត្រូវ ចោទទុកជូនតុលាការចាត់ការតាមនីតិវិធី។

**៣**-ជនត្រូវចោទឈ្មោះ **.........** ដែលបានដាក់ឲ្យស្ថិតក្រោមការពិនិត្យបានស្នើសុំឲ្យតុលាការធ្វើការបន្ធូរបន្ថយទោសដល់ខ្លួនផង។

II-**<u>សំអាងហេតុសេចក្តីសម្រេច:</u>**

**១**-ជនត្រូវចោទឈ្មោះ **....** ភេទប្រុស/ស្រី អាយុ....ឆ្នាំ សញ្ជាតិខ្មែរ ត្រូវបានចោទប្រកាន់ពីបទ**ឧក្រិដ្ឋ/មជ្ឈិម** ដែលច្បាប់កំណត់ដាក់ពន្ធនាគារស្មើ ឬលើសពី០១ (មួយ) ឆ្នាំ តាម**មាត្រា២០៤** នៃក្រមនីតិវិធីព្រហ្មទណ្ឌ។

**២-<u>យល់ឃើញថា:</u>** ការឃុំខ្លួនបណ្តោះអាសន្នជនត្រូវចោទ គឺជាមធ្យោបាយតែមួយគត់ដើម្បី:

☐ បញ្ចប់បទល្មើស ឬបង្ការបទល្មើសកុំឱ្យកើតជាថ្មី

☐ រារាំងកុំឱ្យមានការគាបសង្កត់លើសាក្សី ឬជនរងគ្រោះ

☐ រារាំងកុំឱ្យមានការត្រូវរ៉ូវគ្នារវាងជនត្រូវចោទ និងអ្នកសមគំនិត

☐ រក្សាភស្តុតាង ឬតម្រុយជាសម្ភារៈ

☑ ធានារក្សាជនត្រូវចោទ ទុកជូនតុលាការចាត់ការតាមនីតិវិធី

☐ ធានារក្សាសណ្តាប់ធ្នាប់សាធារណៈ កុំឱ្យមានការច្របូកច្របល់ដែលបណ្តាលមកពីបទល្មើស

ដោយសារមិនមានវិធានការត្រួតពិនិត្យតាមផ្លូវតុលាការណាមួយដែលមានលក្ខណៈតឹងរឹង និងមានប្រសិទ្ធិភាព អាចធានាឱ្យមានការបំពេញកិច្ចការប្រកបដោយប្រសិទ្ធិភាពចំពោះស្ថានភាពតម្រូវទាំងអស់នេះ ហើយមានតែការឃុំ ខ្លួនដែលជាមធ្យោបាយតែមួយគត់ដើម្បីសម្រេចនូវគោលដៅខាងលើ។

## <u>ហេតុដូច្នេះសម្រេច</u>

ឃុំខ្លួនជនត្រូវចោទឈ្មោះ **......** ភេទស្រី/ប្រុស អាយុ....ឆ្នាំ សញ្ជាតិខ្មែរ ជាបណ្តោះអាសន្នដែល

មានរយៈពេលអតិបរមា**០៤/០៦ខែ**។

រាជធានីភ្នំពេញ, ថ្ងៃទី...... ខែ...... ឆ្នាំ២០២២

**ចៅក្រមស៊ើបសួរ**

បានទទួលដំណឹង

រាជធានីភ្នំពេញ, ថ្ងៃទី...... ខែ...... ឆ្នាំ២០២២

**តំណាងអយ្យការ**

**ក្រឡាបញ្ជី**

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**សាលាដំបូងរាជធានីភ្នំពេញ**

បន្ទប់ស៊ើបសួរ "..."

លេខ....................

# <u>ដីកាបង្គាប់ឲ្យឃុំខ្លួន</u>

យើង ........... ចៅក្រមស៊ើបសួរនៃសាលាដំបូងរាជធានីភ្នំពេញ ។

**បានឃើញមាត្រា២០៦, មាត្រា២១៩, មាត្រា២២០, មាត្រា២២១** និង**មាត្រា២២២** នៃក្រមនីតិវិធីព្រហ្មទណ្ឌ។

**បានឃើញ**សំណុំរឿងព្រហ្មទណ្ឌលេខ **.........** ចុះថ្ងៃទី..... ខែ......... ឆ្នាំ២០២២ ។

**បានឃើញ**ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរលេខ **...........** ចុះថ្ងៃទី...... ខែ...... ឆ្នាំ២០២២ របស់ តំណាងអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ ។

**បានឃើញ**សំណុំរឿងស៊ើបសួរលេខ **........** ចុះថ្ងៃទី...... ខែ...... ឆ្នាំ២០២២ ។

**បានឃើញ**ដីកាសម្រេចឲ្យឃុំខ្លួនបណ្តោះអាសន្នលេខ ................ ចុះថ្ងៃទី.... ខែ.... ឆ្នាំ២០២២។

ដែលទាក់ទងនឹងជនត្រូវចោទឈ្មោះ ឈ្មោះ ...... ភេទប្រុស/ស្រី អាយុ......ឆ្នាំ សញ្ជាតិខ្មែរ មុខរបរ ...... ទីកន្លែងកំណើតនៅ...... ទីលំនៅមុនពេលឃាត់ខ្លួនស្នាក់នៅ...... រាជធានីភ្នំពេញ នៅលីវ/ប្រពន្ធ/ប្តីឈ្មោះ ...... ឪពុកឈ្មោះ ...... (រ/ស) ម្តាយឈ្មោះ ...... (រ/ស) ជានីតិជន/អនីតិជន ។

ឃាត់ខ្លួននៅថ្ងៃទី...... ខែ.... ឆ្នាំ២០២២ ។

ប្រវត្តិនៃការផ្តន្ទាទោសដោយតុលាការ៖ ............ ។

ជននេះត្រូវបានដាក់ឲ្យស្ថិតនៅក្រោមការពិនិត្យពីបទ៖ **រក្សាទុក ដឹកជញ្ជូន និងជួញដូរដោយខុសច្បាប់នូវសារធាតុញៀន** ប្រព្រឹត្តនៅ...... រាជធានីភ្នំពេញ កាលពីថ្ងៃទី...... ខែ...... ឆ្នាំ២០២២ តាមបញ្ញត្តិ**មាត្រា៤០** នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ។

## <u>បង្គាប់</u>

**១**-ឲ្យភ្នាក់ងារមានសមត្ថកិច្ចនៃកងកម្លាំងសាធារណៈធ្វើការនាំខ្លួនជនត្រូវចោទដែលមានឈ្មោះ **.........** ភេទប្រុស/ស្រី អាយុ.....ឆ្នាំ សញ្ជាតិខ្មែរ ទៅពន្ធនាគារ....... ដោយអនុវត្តឲ្យបានត្រឹមត្រូវតាមច្បាប់ ។

**២**-ឲ្យលោកប្រធានពន្ធនាគារ........ ទទួល និងឃុំខ្លួនជននេះរហូតដល់មានបទបញ្ជាថ្មីសម្រេច ផ្សេងពីនេះ ។

**៣**-ឲ្យគ្រប់ភ្នាក់ងារ នៃកងកម្លាំងសាធារណៈទាំងអស់ សហការអនុវត្តឲ្យបានល្អនៅពេលដីកានេះត្រូវបានបង្ហាញ ក្នុងករណីចាំបាច់ ។

ថ្ងៃ.............ខែ........ ឆ្នាំ...... ត្រីស័ក ព.ស.២៥៦៥

រាជធានីភ្នំពេញ, ថ្ងៃទី..... ខែ....... ឆ្នាំ២០២២

**ចៅក្រមស៊ើបសួរ**

ឧបសម្ព័ន្ធទី៨

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**សាលាដំបូងរាជធានីភ្នំពេញ**

បន្ទប់ស៊ើបសួរ "..."

លេខ...................

# <u>ដីកាសម្រេចមិនឃុំខ្លួនបណ្តោះអាសន្ន</u>

យើង ................. ចៅក្រមស៊ើបសួរនៃសាលាដំបូងរាជធានីភ្នំពេញ

អមដោយលោក ................ ជាក្រឡាបញ្ជី។

**បានឃើញ** មាត្រា **២០៧** នៃក្រមនីតិវិធីព្រហ្មទណ្ឌ។

**បានឃើញ** សំណុំរឿងព្រហ្មទណ្ឌលេខ **.........** ចុះថ្ងៃទី...... ខែ...... ឆ្នាំ២០......។

**បានឃើញ** ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរលេខ **.........** ចុះថ្ងៃទី...... ខែ...... ឆ្នាំ២០...... របស់ អយ្យការអមសាលាដំបូងរាជធានីភ្នំពេញ។

**បានឃើញ** សំណុំរឿងស៊ើបសួរលេខ **.........** ចុះថ្ងៃទី...... ខែ...... ឆ្នាំ២០......។

**<u>ក្រោយពីបានពិនិត្យសំណុំរឿងចប់សព្វគ្រប់ហើយ យល់ឃើញថា:</u>**

ជនត្រូវចោទឈ្មោះ ឈ្មោះ ...... ភេទប្រុស/ស្រី អាយុ......ឆ្នាំ សញ្ជាតិខ្មែរ មុខរបរ...... ទីកន្លែងកំណើតនៅ...... ទីលំនៅមុនពេលឃាត់ខ្លួនស្នាក់នៅ...... រាជធានីភ្នំពេញ នៅលីវ/ប្រពន្ធ/ប្តីឈ្មោះ...... ឪពុកឈ្មោះ ...... (រ/ស) ម្តាយឈ្មោះ ......(រ/ស) ជានីតិជន/អនីតិជន ទោសពីមុនគ្មាន។

ត្រូវបានចោទប្រកាន់ពីបទ៖ ***រក្សាទុកដោយខុសច្បាប់នូវសារធាតុញៀន*** ប្រព្រឹត្តនៅ...... រាជធានីភ្នំពេញ កាលពីថ្ងៃទី.... ខែ.... ឆ្នាំ២០២២ តាមបញ្ញត្តិ**មាត្រា៤០** នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។

## <u>យល់ឃើញថា</u>

១-ជនត្រូវចោទឈ្មោះ **.............** មានមុខរបរ និងទីលំនៅច្បាស់លាស់។

២-តាមស្មារតី**មាត្រា២០៣** នៃក្រមនីតិវិធីព្រហ្មទណ្ឌ ជាគោលការណ៍ជនត្រូវចោទត្រូវមានសេរីភាព។

ហេតុដូច្នេះ គប្បីពុំចាំបាច់ឃុំខ្លួនជនត្រូវចោទរូបនេះទេ តែត្រូវដាក់ជននេះឲ្យស្ថិតនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ។

៥-ការមិនឃុំខ្លួនជនត្រូវចោទរូបនេះ ពុំមានផលប៉ះពាល់ដល់ការស៊ើបសួរឡើយ។

## <u>ហេតុដូច្នេះសម្រេច</u>

១-មិនឃុំខ្លួនជាបណ្តោះអាសន្នលើជនត្រូវចោទឈ្មោះ **.....** ភេទ...... កើតឆ្នាំ....... សញ្ជាតិ.... (មានសារតាជាតិខាងលើ) ដោយអនុញ្ញាតឲ្យមានសេរីភាពធម្មតាវិញ ។ ប៉ុន្តែតម្រូវឲ្យឈ្មោះខាងលើចូលមកបង្ហាញខ្លួននៅ ចំពោះមុខចៅក្រមស៊ើបសួរនៃសាលដំបូងរាជធានីភ្នំពេញជាដរាបកាលណាមានដីកាបង្គាប់ឲ្យចូលខ្លួន។

២-ក្នុងករណីមិនសុខចិត្តនឹងសេចក្តីសម្រេចនេះ មានសិទ្ធិប្តឹងឧទ្ធរណ៍តាមកំណត់ច្បាប់។

ថ្ងៃ........................ ខែផល្គុន ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥

រាជធានីភ្នំពេញ, ថ្ងៃទី....... ខែមីនា ឆ្នាំ២០២២

**ក្រឡាបញ្ជី** **ចៅក្រមស៊ើបសួរ**

**បានទទួលដំណឹង**

ថ្ងៃ........................ ខែផល្គុន ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥

រាជធានីភ្នំពេញ, ថ្ងៃទី....... ខែមីនា ឆ្នាំ២០២២

**តំណាងអយ្យការ**

ឧបសម្ព័ន្ធទី៩

# ព្រះរាជាណាចក្រកម្ពុជា
# ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូងរាជធានីភ្នំពេញ

បន្ទប់ស៊ើបសួរ "..."

លេខ:...................

## ដីកាសម្រេចដាក់ជនត្រូវចោទ
## ឱ្យស្ថិតក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ

យើង .......... ចៅក្រមស៊ើបសួរនៃសាលាដំបូងរាជធានីភ្នំពេញ អមដោយលោក .... ជាក្រឡាបញ្ជី។

**បានឃើញ មាត្រា ២២៣** និង**មាត្រា ២២៦** ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧។

**បានឃើញ** សំណុំរឿងព្រហ្មទណ្ឌលេខ ...... ចុះថ្ងៃទី..... ខែ...... ឆ្នាំ២០.......។

**បានឃើញ** ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរលេខ ...... ចុះថ្ងៃទី..... ខែ...... ឆ្នាំ២០....... របស់អយ្យការអមសាលាដំបូងរាជធានីភ្នំពេញ។

**បានឃើញ** សំណុំរឿងស៊ើបសួរលេខ ...... ចុះថ្ងៃទី..... ខែ...... ឆ្នាំ២០.......។

**<u>ក្រោយពីបានពិនិត្យសំណុំរឿងយ៉ាងហ្មត់ចត់ និងត្រឹមត្រូវរួចហើយ យល់ឃើញថា:</u>**

ជនត្រូវចោទឈ្មោះ ឈ្មោះ ...... ភេទប្រុស/ស្រី អាយុ......ឆ្នាំ សញ្ជាតិខ្មែរ មុខរបរ...... ទីកន្លែងកំណើតនៅ...... ទីលំនៅមុនពេលឃាត់ខ្លួនស្នាក់នៅ...... រាជធានីភ្នំពេញ នៅលីវ/ប្រពន្ធ/ប្តីឈ្មោះ.... ឪពុកឈ្មោះ ...... (រ/ស) ម្តាយឈ្មោះ ......(រ/ស) ជានីតិជន/អនីតិជន ទោសពីមុនគ្មាន។

ត្រូវបានចោទប្រកាន់ពីបទ៖ **រក្សាទុកដោយខុសច្បាប់នូវសារធាតុញៀន** ប្រព្រឹត្តនៅ...... រាជធានីភ្នំពេញ កាលពីថ្ងៃទី...... ខែ...... ឆ្នាំ២០២២ តាមបញ្ញត្តិ**មាត្រា៤០** នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។

ឱ្យស្ថិតនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ ដោយតម្រូវឱ្យជនត្រូវចោទបំពេញនូវកាតព្វកិច្ចនៃការត្រួតពិនិត្យតាមផ្លូវតុលាការមានដូចខាងក្រោម:

- មិនត្រូវចេញក្រៅដែនដីនៃព្រះរាជាណាចក្រកម្ពុជា។
- មិនត្រូវផ្លាស់ប្តូរលំនៅឋានដោយគ្មានការអនុញ្ញាតពីចៅក្រមស៊ើបសួរឡើយ។
- ត្រូវឆ្លើយតបនឹងការកោះហៅពីគ្រប់បុគ្គលដែលមាននាមដូចតទៅ: ចៅក្រមស៊ើបសួរ ព្រះរាជអាជ្ញា ឬចៅក្រម ជំនុំជម្រះ។

ក្នុងករណីដែលជនត្រូវចោទគេចវេសដោយចេតនាមិនអនុវត្តតាមចំណុចខាងលើនេះ ចៅក្រមស៊ើបសួរនឹងចាប់ឃុំខ្លួនជនត្រូវចោទឡើងវិញ ដោយអនុវត្តតាម**មាត្រា២៣០** នៃក្រមនីតិវិធីព្រហ្មទណ្ឌ។

**ដីកាសម្រេចនេះមានប្រសិទ្ធិភាពអនុវត្តភ្លាម។**

ថ្ងៃ................ ខែផល្គុន ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥

រាជធានីភ្នំពេញ, ថ្ងៃទី...... ខែមីនា ឆ្នាំ២០២២

**ចៅក្រមស៊ើបសួរ**

**បានទទួលដំណឹង**

ថ្ងៃ.......... ខែផល្គុន ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥

រាជធានីភ្នំពេញ, ថ្ងៃទី....... ខែមីនា ឆ្នាំ២០២២

**តំណាងអយ្យការ**

**ក្រឡាបញ្ជី**

ឧបសម្ព័ន្ធទី១០

# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូងរាជធានីភ្នំពេញ

លេខ: ........

# ដីកាចាត់ឲ្យស៊ើបសួរជំនួស

យើង ................. ចៅក្រមស៊ើបសួរនៃសាលាដំបូងរាជធានីភ្នំពេញ។

-បានឃើញ**មាត្រា ១៣១ មាត្រា ១៧៣** និងមាត្រាពាក់ព័ន្ធនៃក្រមនីតិវិធីព្រហ្មទណ្ឌ។

-បានឃើញសំណុំរឿងព្រហ្មទណ្ឌលេខ **......** ចុះថ្ងៃទី....... ខែ...... ឆ្នាំ២០.......។

-បានឃើញដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរលេខ **......** ចុះថ្ងៃទី....... ខែ...... ឆ្នាំ២០....... របស់តំណាងអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ។

-បានឃើញសំណុំរឿងស៊ើបសួរលេខ **......** ចុះថ្ងៃទី....... ខែ...... ឆ្នាំ២០.......

ដែលទាក់ទងនឹងជនត្រូវចោទមានឈ្មោះដូចខាងក្រោម៖

ក-ឈ្មោះ **កខ** ភេទប្រុស អាយុ២៦ឆ្នាំ សញ្ជាតិខ្មែរ មុខរបរកម្មករសំណង់ ទីកន្លែងកំណើតនៅខេត្ត គយង ទីលំនៅមុនពេលឃាត់ខ្លួនស្នាក់នៅ រាជធានីភ្នំពេញ នៅលីវ ឪពុកឈ្មោះ ...... (ស) ម្ដាយឈ្មោះ ....... (ស) ជានីតិជន ទោសពីមុនគ្មាន។ **(ក្នុងឃុំ)**

ត្រូវដាក់ឲ្យស្ថិតនៅក្រោមការពិនិត្យពីបទ៖ ***រក្សាទុកដោយខុសច្បាប់នូវសារធាតុញៀន*** ប្រព្រឹត្តនៅចំណុច ......... រាជធានីភ្នំពេញ កាលពីថ្ងៃទី..... ខែ.... ឆ្នាំ២០... តាមបញ្ញត្តិ**មាត្រា៤០** នៃច្បាប់ស្ដីពីការត្រួតពិនិត្យគ្រឿងញៀន។

**ខ-ក្មេងៗមិនស្គាល់ឈ្មោះ** ភេទប្រុស សញ្ជាតិខ្មែរ មិនស្គាល់អាសយដ្ឋាន នៅម្តុំផ្លូវរថភ្លើងក្តាន់ពីរ។ **(គេចខ្លួនគ្មានសារតា)**

ត្រូវដាក់ឲ្យស្ថិតនៅក្រោមការពិនិត្យពីបទ៖ ***ជួញដូរដោយខុសច្បាប់នូវសារធាតុញៀន*** ប្រព្រឹត្តនៅ... ភ្នំពេញ កាលពីថ្ងៃទី..... ខែ...... ឆ្នាំ២០....... តាមបញ្ញត្តិ**មាត្រា៤០**នៃច្បាប់ស្ដីពីការត្រួតពិនិត្យគ្រឿងញៀន។

## សំអាងហេតុ:

១.កាលពីថ្ងៃទី..... ខែ......... ឆ្នាំ២០២២ វេលាម៉ោងប្រហែលដប់ប្រាំបី ជនត្រូវចោទឈ្មោះ **កខ** បានទិញគ្រឿងញៀនពី **ក្មេងៗមិនស្គាល់ឈ្មោះ** នៅម្តុំ.... រាជធានីភ្នំពេញ ក៏ត្រូវបានសមត្ថកិច្ច នៃមន្ទីរប្រឆាំងបទល្មើសគ្រឿងញៀន បង្ក្រាបជាក់ស្ដែង ដោយបានដកហូតវត្ថុតាងក្រោមពណ៌សថ្លាសង្ស័យជាគ្រឿងញៀនចំនួន០១កញ្ចប់ ទម្ងន់0,៦0(សូន្យក្បៀសហុកសិប)ក្រាម នាំយកមក សាកសួរ និងចាត់ការតាមនីតិវិធីច្បាប់។

២.ដើម្បីធានាដល់នីតិវិធីស៊ើបសួរប្រព្រឹត្តទៅឲ្យបានត្រឹមត្រូវតាមផ្លូវច្បាប់នោះតម្រូវឲ្យធ្វើកាស្រាវជ្រាវ រកសារតាជាតិរបស់ជនត្រូវចោទឈ្មោះ **ក្មេងៗមិនស្គាល់ឈ្មោះ** ភេទប្រុស សញ្ជាតិខ្មែរ មិនស្គាល់អាសយដ្ឋាននៅ ម្តុំផ្លូវរថភ្លើងក្តាន់ពីរ ត្រូវដាក់ឲ្យស្ថិតនៅក្រោមការពិនិត្យពីបទ៖ ***ជួញដូរដោយខុស***

**ច្បាប់នូវសារធាតុញៀន** ប្រព្រឹត្តនៅ...រាជធានីភ្នំពេញ កាលពីថ្ងៃទី... ខែ... ឆ្នាំ២០... តាមបញ្ញត្តិ**មាត្រា៤០** នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។

៣.ដើម្បីធានាដល់នីតិវិធីនៃការស៊ើបសួរអោយមានភាពជឿនលឿនទៅមុខ និងជាមូលដ្ឋាននៃការស៊ើបសួរ ព្រម ទាំងសម្រេចសេចក្តីឲ្យបានត្រឹមត្រូវ។

## <u>ហេតុដូច្នេះសម្រេច</u>

១-ប្រគល់សិទ្ធិជូន **ឯកឧត្តមនាយកមន្ទីរប្រឆាំងបទល្មើសគ្រឿងញៀន** ចាត់កំលាំងជំនាញចុះស្រាវជ្រាវ សាវតាជាតិលើ **ក្មេងៗមិនស្គាល់ឈ្មោះ** ភេទប្រុស សញ្ជាតិខ្មែរ មិនស្គាល់អាសយដ្ឋាន នៅម្តុំ.... ត្រូវដាក់ឲ្យស្ថិតនៅក្រោមការពិនិត្យពីបទ៖ **ជួញដូរដោយខុសច្បាប់នូវសារធាតុញៀន** ប្រព្រឹត្តនៅ...រាជធានីភ្នំពេញ កាលពីថ្ងៃទី... ខែ... ឆ្នាំ២០២២ តាមបញ្ញត្តិ**មាត្រា៤០** នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។

២-ក្រោយពីបំពេញកិច្ចស៊ើបសួរនេះចប់សព្វគ្រប់ត្រូវបញ្ជូនលទ្ធផលមក **សាលាដំបូងរាជធានីភ្នំពេញ** វិញឲ្យបានមុនថ្ងៃទី**.... ខែ...... ឆ្នាំ២០...។**

ថ្ងៃ.......... ខែ....... ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៥

រាជធានីភ្នំពេញ, ថ្ងៃទី.... ខែ... ឆ្នាំ២០...

**ចៅក្រមស៊ើបសួរ**

<u>ជូនភ្ជាប់មកជាមួយ</u>

-ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរលេខ **....អយធ** ចុះថ្ងៃទី../../២០.. របស់តំណាងអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ(ថតចម្លង) ១ច្បាប់

-របាយការណ៍លេខ **...** ចុះថ្ងៃទី../../២០... របស់មន្ទីរប្រឆាំងបទល្មើស គ្រឿងញៀន (ថតចម្លង)១ច្បាប់

ឧបសម្ព័ន្ធទី១១

# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូងរាជធានីភ្នំពេញ

សំណុំរឿងព្រហ្មទណ្ឌលេខ: ...

ចុះថ្ងៃទី...ខែ... ឆ្នាំ២០...

## កំណត់ហេតុបើក និងបិទដកសំណាកយកទៅធ្វើកោសលវិច័យ

ឆ្នាំពីរពាន់... ខែ.... ថ្ងៃទី.. វេលាម៉ោងប្រាំបួន និងសាមសិប នាទីព្រឹក នៅសាលាដំបូងរាជធានីភ្នំពេញ។

**ដោយមានសមាសភាពចូលរួមមាន៖**

-លោកស្រី ............ ចៅក្រមស៊ើបសួរសាលាដំបូងរាជធានីភ្នំពេញ។

-លោក .......... ព្រះរាជអាជ្ញារងអមសាលាដំបូងរាជធានីភ្នំពេញ។

-លោក ......... ក្រឡាបញ្ជីទទួលបន្ទុកឃ្លាំងវត្ថុចាប់យក។

-លោក ......... ក្រឡាបញ្ជីសាលាដំបូងរាជធានីភ្នំពេញ។

-លោកវរសេនីយ៍ត្រី ..................... មន្ត្រី នៃមន្ទីប្រឆាំងបទល្មើសគ្រឿងញៀន។

-លោកមេធាវី...........ជាមេធាវីការពារសិទ្ធិឱ្យជនត្រូវចោទឈ្មោះ...........។

-ជនត្រូវចោទឈ្មោះ ................ ភេទប្រុស/ស្រី អាយុ........ឆ្នាំ សញ្ជាតិ.......។

យើងបានយកកញ្ចប់វត្ថុតាងបង្ហាញដល់ជនត្រូវចោទឈ្មោះ **......** ភេទប្រុស/ស្រី អាយុ...ឆ្នាំ សញ្ជាតិ.. និង សមាសភាពចូលរួមបានពិនិត្យលើកញ្ចប់ស្រោមបិទជិត ហើយបញ្ជាក់ថា៖កញ្ចប់វត្ថុតាងដែលបានបង្ហាញនេះមាន សភាពល្អដូចដើម។

យើងបានធ្វើការកាត់កញ្ចប់វត្ថុតាងនេះ ឃើញមានក្រាមពណ៌សថ្លាទម្ងន់សរុប **២០,៧០** ក្រាម (ម្ភៃក្បៀស ចិត សិប) ក្រាម ហើយយើងបានធ្វើការបើកដកយកទម្ងន់ **២** ក្រាម (ពីរ) ក្រាម រួចបានរំលែកដាក់ចូលក្នុងកូនថង់តូចៗចំនួន **០៣** (បី) បិទជិត ហើយដាក់ចូលក្នុងស្រោមសំបុត្រពណ៌សចំនួន **០៣** (បី) បិទជិត ដែលមានស្នាមមេដៃជនត្រូវចោទ និង សមាសភាពចូលរួមទាំងអស់ដើម្បីបញ្ជូនទៅមន្ទីរពិសោធន៍នៃអគ្គលេខាធិការអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀនដើម្បីធ្វើកោសល្យវិច័យ។

ចំណែកវត្ថុចាប់យកដែលនៅសល់បានដាក់ចូលក្នុងកញ្ចប់ដដែលវិញ ហើយបិទជិតដោយស្កុតពណ៌សវិញ និង បានប្រគល់កញ្ចប់ដដែលឱ្យទៅក្រឡាបញ្ជីទទួលបន្ទុកឃ្លាំងតម្កល់វត្ថុចាប់យករក្សាទុកវិញ។

កំណត់ហេតុបញ្ចប់នៅម៉ោងដប់ និងសូន្យ នាទីព្រឹក នាថ្ងៃខែឆ្នាំដដែល។

| | | | | |
|---|---|---|---|---|
| **ជនត្រូវចោទ** | **មេធាវី** | **តំណាងអយ្យការ** | **ក្រឡាបញ្ជី** | **ចៅក្រមស៊ើប** |

ឧបសម្ព័ន្ធទី១២

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

សាលាដំបូងរាជធានីភ្នំពេញ

បន្ទប់ស៊ើបសួរ " ..."

លេខៈ ................

# ដីកាចាត់តាំងអ្នកជំនាញ

យើង ............ ចៅក្រមស៊ើបសួរនៃសាលាដំបូងរាជធានីភ្នំពេញ។

បានឃើញ**មាត្រា ១៦២, មាត្រា ១៦៣, មាត្រា ១៦៥** និងមាត្រាពាក់ព័ន្ធនៃក្រមនីតិវិធីព្រហ្មទណ្ឌ។

បានឃើញសេចក្តីសម្រេចស្តីពីការទទួលស្គាល់មន្ត្រីជំនាញក្នុងការធ្វើកោសលវិច័យគ្រឿងញៀន និងសារធាតុញៀន លេខ **១០កយ.សសរ/២១** ចុះថ្ងៃទី១៣ ខែមេសា ឆ្នាំ២០២១ របស់ទីស្តីការក្រសួងយុត្តិធម៌។

បានឃើញសំណុំរឿងព្រហ្មទណ្ឌលេខ **........** ចុះថ្ងៃទី... ខែ..... ឆ្នាំ២០.......។

បានឃើញដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរលេខ **........** ចុះថ្ងៃទី... ខែ..... ឆ្នាំ២០.......។

បានឃើញសំណុំរឿងស៊ើបសួរលេខ **.....** ចុះថ្ងៃទី... ខែ.... ឆ្នាំ២០.... របស់សាលាដំបូងរាជធានីភ្នំពេញ។

ដែលទាក់ទងនឹងជនត្រូវចោទឈ្មោះ **.......** ភេទប្រុស/ស្រី អាយុ.....ឆ្នាំ សញ្ជាតិខ្មែរ មុខរបរ.... ទីកន្លែងកំណើតនៅ ខេត្ត ... ទីលំនៅមុនពេលឃាត់ខ្លួនស្នាក់នៅ... រាជធានីភ្នំពេញ នៅលីវ ឪពុកឈ្មោះ ...... (ស) ម្តាយឈ្មោះ ....... (ស) ជានីតិជន ទោសពីមុនគ្មាន ត្រូវចោទប្រកាន់ពីបទ៖ **រក្សាទុកដោយខុសច្បាប់នូវសារធាតុញៀន** ប្រព្រឹត្តនៅ... រាជធានីភ្នំពេញ កាលពីថ្ងៃទី....... ខែ....... ឆ្នាំ២០... តាមបញ្ញត្តិ**មាត្រា៤០** នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។

## សំអាងហេតុ

**១**-កំណត់ហេតុធ្វើតេស្តបឋម និងវេចខ្ចប់វត្ថុតាង ចុះថ្ងៃទី... ខែ... ឆ្នាំ២០... របស់ជនត្រូវចោទឈ្មោះ **...**។

**៣**-ដើម្បីឲ្យតុលាការរកយុត្តិធម៌បានត្រឹមត្រូវ គប្បីសម្រេចចាត់តាំងអ្នកជំនាញឲ្យពិនិត្យសន្និដ្ឋាន និងវាយតម្លៃឲ្យបាន ច្បាស់ជាមុនសិន ។

## ហេតុដូច្នេះសម្រេច

**ចាត់តាំង៖**

**១**-លោកវេជ្ជបណ្ឌិត **...............** ប្រធានការិយាល័យបច្ចេកទេស។

**២**-លោកស្រី វិស្វករគីមី **............** ប្រធានការិយាល័យវិភាគវត្ថុ។

ជាអ្នកជំនាញ ដើម្បីធ្វើកោសលវិច័យលើវត្ថុចាប់យកដូចមាននៅក្នុងកំណត់ហេតុធ្វើតេស្តបឋម និងវេចខ្ចប់វត្ថុតាង ចុះថ្ងៃទី.... ខែ.... ឆ្នាំ២០....។ ដែលសង្ស័យថាមានសារធាតុញៀន។

ក្រោយពីបានអនុវត្តដីកានេះចប់សព្វគ្រប់ ត្រូវបញ្ជូនលទ្ធផលមកសាលាដំបូងរាជធានីភ្នំពេញ ឲ្យបានឆាប់តាមដែលអាចធ្វើបាន។

ថ្ងៃ....... ខែ....... ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៥

រាជធានីភ្នំពេញ, ថ្ងៃទី....... ខែ...... ឆ្នាំ២០......

**ចៅក្រមស៊ើបសួរ**

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ...១៣...អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការរៀបចំ និងការប្រព្រឹត្តទៅរបស់អគ្គលេខាធិការដ្ឋាន នៃអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន

### រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩៩៥/៦៥ ចុះថ្ងៃទី ៧ ខែ កញ្ញា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើតអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៦០៦/២៧៤ ចុះថ្ងៃទី ២៣ ខែ មិថុនា ឆ្នាំ ២០០៦ ស្តីពីការកែសម្រួលព្រះរាជក្រឹត្យលេខ សន/រកត/០៩៩៥/៦៥ ចុះថ្ងៃទី ៧ ខែ កញ្ញា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើតអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន
- តាមសំណើរបស់ប្រធានអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន

### សំរេច

## ជំពូក ១

## បទប្បញ្ញត្តិទូទៅ

**មាត្រា ១ :-**

អនុក្រឹត្យនេះកំណត់ តួនាទី មុខងារ សមត្ថកិច្ច និងរៀបចំរចនាសម្ព័ន្ធរបស់អគ្គលេខាធិការដ្ឋាននៃអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន ។

## ជំពូក ២

## តួនាទី មុខងារ សមត្ថកិច្ច និងរចនាសម្ព័ន្ធ

**មាត្រា ២ :-**

អគ្គលេខាធិការដ្ឋាននៃអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន មានតួនាទីដ៏សំខាន់ក្នុងការប្រមូលពត៌មាន និងចូលរួមប្រតិបត្តិការប្រឆាំងនឹងការដាំដុះ ការផលិត ការជួញដូរគ្រឿងញៀនខុសច្បាប់ និងសំរបសំរួលរាល់សកម្មភាពត្រួតពិនិត្យគ្រឿងញៀនរបស់អង្គភាពប្រតិបត្តិដទៃទៀត ដើម្បីធានាប្រសិទ្ធភាព និងសុវត្ថិភាពនៃការបង្ក្រាបគ្រឿងញៀនខុសច្បាប់នៅព្រះរាជាណាចក្រកម្ពុជា។ នៅក្នុងតួនាទីនេះ អគ្គលេខាធិការដ្ឋានមានមុខងារសំខាន់ៗ ដូចតទៅ ÷

១. រៀបចំជូនអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន និងរាជរដ្ឋាភិបាល នូវយុទ្ធសាស្ត្រ និងផែនការសកម្មភាព បង្ក្រាបការដាំដុះ ការផលិត ការជួញដូរគ្រឿងញៀនខុសច្បាប់ និងការប្រើបំពានគ្រឿងញៀន ដោយសំរបសំរួលឱ្យមានការចូលរួមយ៉ាងសកម្មពីសំណាក់ក្រសួង-ស្ថាប័ន និងអង្គការពាក់ព័ន្ធដទៃទៀត ។

២. តាមដានការអនុវត្តន៍គោលនយោបាយ សេចក្ដីសំរេចរបស់រាជរដ្ឋាភិបាល និងអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន ។

៣. ជំរុញ និងសំរបសំរួលវិធានការត្រួតពិនិត្យគ្រឿងញៀនដែលរៀបចំឡើងដោយក្រសួង-ស្ថាប័នពាក់ព័ន្ធ។

២- នាយកដ្ឋាន ផែនការ និងបណ្តុះបណ្តាល

៣- នាយកដ្ឋាន សហប្រតិបត្តិការអន្តរជាតិ

៤- នាយកដ្ឋានអនុវត្តច្បាប់

៥- នាយកដ្ឋាន នីតិកម្ម អប់រំ និងស្តារនីតិសម្បទា

៦- នាយកដ្ឋាន ស្រាវជ្រាវ និងត្រួតពិនិត្យ

៧- មន្ទីរពិសោធន៍គ្រឿងញៀន

អង្គការលេខរបស់អគ្គលេខាធិការដ្ឋាននៃអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន មានចែងនៅក្នុងតារាងឧបសម្ព័ន្ធនៃអនុក្រឹត្យនេះ ។

**មាត្រា ៥ :-**

អគ្គលេខាធិការដ្ឋាននៃអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន ត្រូវបានដឹកនាំ និងគ្រប់គ្រងដោយអគ្គលេខាធិការមួយរូបដែលមានអគ្គលេខាធិការរងជាជំនួយការ ។

**មាត្រា ៦ :-**

អគ្គលេខាធិការដ្ឋាននៃអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន មានសិទ្ធិធ្វើត្រាប្រើប្រាស់តាមសេចក្តីត្រូវការ ។

អគ្គលេខាធិការមានសិទ្ធិធ្វើសេចក្តីសំរេចតែងតាំង ឬ ផ្លាស់ប្តូរតំណែងនូវមន្ត្រីបុគ្គលិករបស់អគ្គលេខាធិការដ្ឋាន ចាប់ពីថ្នាក់ប្រធានផ្នែកចុះ។ ចំពោះការតែងតាំង ឬ ផ្លាស់ប្តូរតំណែងមន្ត្រីរាជការចាប់ពីអនុប្រធានការិយាល័យឡើងទៅ អគ្គលេខាធិការមានភារកិច្ចស្នើសុំប្រធានអាជ្ញាធរជាតិ ដើម្បីសំរេច ។

ក្នុងករណីចាំបាច់ អគ្គលេខាធិការ អាចមានសិទ្ធិជ្រើសរើសបុគ្គលិកជាប់កិច្ចសន្យាអោយមកបំពេញការងារនៅអគ្គលេខាធិការដ្ឋានតាមលក្ខខណ្ឌកំណត់ ។

## ជំពូក ៣
## នាយកដ្ឋាន

**មាត្រា ៧ :- នាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ មានភារកិច្ចដូចតទៅ ÷**

១. សំរបសំរួលរាល់សកម្មភាពរបស់អគ្គលេខាធិការដ្ឋាន ។

២. គ្រប់គ្រង និងចរាចរឯកសាររដ្ឋបាលផ្សេងៗរបស់អគ្គលេខាធិការដ្ឋាន ។

៣. សរុប និងធ្វើរបាយការណ៍សភាពការណ៍គ្រឿងញៀន និងសកម្មភាពការងាររបស់អាជ្ញាធរជាតិ អគ្គលេខាធិការដ្ឋាន និងគណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀនខេត្ត-ក្រុង ។

៤. គ្រប់គ្រងផ្នែករដ្ឋបាល ហិរញ្ញវត្ថុ និងមន្ត្រីបុគ្គលិករបស់អគ្គលេខាធិការដ្ឋាន ។

៥. លើក និងអនុវត្តគំរោងថវិកាប្រចាំឆ្នាំរបស់អគ្គលេខាធិការដ្ឋាន ។

៦. ប្រមូលផ្តុំចំណូល និងចំណាយរបស់អគ្គលេខាធិការដ្ឋាន ។

៧. តាមដាន និងរំលឹកការអនុវត្តន៍ថវិកា និងគ្រប់គ្រងគណនីរបស់អគ្គលេខាធិការដ្ឋាន ។

៨. គ្រប់គ្រងចលនទ្រព្យ អចលនទ្រព្យ សម្ភារៈ ធ្វើបញ្ជីសារពើភ័ណ្ឌរបស់អគ្គលេខាធិការដ្ឋាន ។

៩. រៀបចំ និងបើកប្រាក់បៀវត្សរ៍ជូនមន្ត្រីរាជការរបស់អគ្គលេខាធិការដ្ឋាន ។

១០. ទទួល និងបែងចែកបរិក្ខារ ជូនដល់អង្គភាពទៅតាមកម្មវិធីចំណាយរបស់អគ្គលេខាធិការដ្ឋាន ។

១១. រៀបចំនិងទទួលរាល់កិច្ចប្រជុំរបស់អគ្គលេខាធិការដ្ឋាននិងអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន។

១២. ធានាប្រសិទ្ធភាពផ្នែករដ្ឋបាលរបស់អគ្គលេខាធិការដ្ឋាន ។

នាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ ត្រូវបានដឹកនាំ និងគ្រប់គ្រងដោយប្រធាននាយកដ្ឋានមួយរូប និងមានអនុប្រធានជា ជំនួយការ ។

**មាត្រា ៨ :- នាយកដ្ឋានផែនការ និងបណ្តុះបណ្តាល មានភារកិច្ចដូចតទៅ ÷**

១. រៀបចំយុទ្ធសាស្ត្រ និងលើកផែនការ គោលនយោបាយក្នុងការបង្ក្រាបការដាំដុះ ការផលិត ការជួញដូរ ការនាំចេញ និងនាំចូល ការដឹកជញ្ជូន នូវគ្រឿងញៀនខុសច្បាប់ ដោយសហការជាមួយក្រសួង-ស្ថាប័ន និងអង្គការពាក់ព័ន្ធដទៃទៀត ។

២. រៀបចំគំរោងសកម្មភាព ដើម្បីអនុវត្តបទប្បញ្ញត្តិទាំងឡាយនៃអនុសញ្ញាទោល ស្តីពីគ្រឿងញៀន ឆ្នាំ ១៩៦១ ដែលបានធ្វើវិសោធនកម្មដោយពិធីសារ ឆ្នាំ ១៩៧២, អនុសញ្ញា ស្តីពីសារធាតុ

ដែលធ្វើអោយប៉ះពាល់ប្រព័ន្ធសរសៃប្រសាទ ឆ្នាំ ១៩៧១ និងអនុសញ្ញារបស់អង្គការសហប្រជាជាតិប្រឆាំងនឹងការចរាចរខុសច្បាប់នូវគ្រឿងញៀន និងសារធាតុដែលធ្វើអោយប៉ះពាល់ប្រព័ន្ធសរសៃប្រសាទ ឆ្នាំ ១៩៨៨ ។

៣. ពិនិត្យតាមដានការអនុវត្តន៍គោលនយោបាយ និងសេចក្តីសំរេចរបស់អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន ។

៤. រៀបចំផែនការថ្នាក់ជាតិ និងគ្រប់គ្រងគំរោងដោយសហការជាមួយក្រសួង-ស្ថាប័ន និងអង្គការពាក់ព័ន្ធដទៃទៀត ។

៥. រៀបចំ និងអនុវត្តនយោបាយ ស្តីពីការបណ្តុះបណ្តាលដល់មន្ត្រីបុគ្គលិករបស់អគ្គលេខាធិការដ្ឋានអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន និងក្រសួង-ស្ថាប័នពាក់ព័ន្ធ ។

៦. សហការជាមួយអង្គការជាតិ និងអន្តរជាតិដើម្បីយល់ដឹងអំពីគោលការណ៍របស់តំបន់ អនុតំបន់ និងអន្តរជាតិ ស្តីពីគ្រឿងញៀន ។

នាយកដ្ឋានផែនការ និងបណ្តុះបណ្តាល ត្រូវបានដឹកនាំ និងគ្រប់គ្រងដោយប្រធាននាយកដ្ឋានមួយរូប និងមានអនុប្រធាន ជាជំនួយការ ។

**មាត្រា ៩ :- នាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ មានភារកិច្ចដូចតទៅ ÷**

១. ទំនាក់ទំនងជាមួយនឹងរដ្ឋាភិបាលបរទេស និងអង្គការអនុតំបន់ ឬអន្តរជាតិនានា ។

២. បញ្ជូនទៅអគ្គលេខាធិការអង្គការសហប្រជាជាតិនូវអាស័យដ្ឋានរបស់អាជ្ញាធរមានសមត្ថកិច្ច ដើម្បីអនុវត្តបទប្បញ្ញត្តិនៃអនុសញ្ញាអន្តរជាតិ ។

៣. សហការជាមួយក្រសួង-ស្ថាប័នពាក់ព័ន្ធក្នុងការបញ្ជូនពត៌មាន និងស្ថិតិដែលកំណត់នៅក្នុងអនុសញ្ញាអន្តរជាតិ ទៅអង្គការសហប្រជាជាតិ និងអង្គការអន្តរជាតិដែលមានសមត្ថកិច្ច ។

៤. ចូលរួមក្នុងសកម្មភាពប្រចាំអនុតំបន់នានា ឬអន្តរជាតិ ។

នាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិត្រូវបានដឹកនាំ និងគ្រប់គ្រងដោយប្រធាននាយកដ្ឋានមួយរូប និងមានអនុប្រធានជាជំនួយការ ។

**មាត្រា ១០ :- នាយកដ្ឋានអនុវត្តច្បាប់ មានភារកិច្ចដូចតទៅ ÷**

១. ស្រាវជ្រាវ និងប្រមូលពត៌មានពាក់ពន្ធ័នឹងគ្រឿងញៀន ដោយសហការជាមួយក្រសួង-ស្ថាប័ន និងអង្គការពាក់ព័ន្ធដទៃទៀត ។

២. ត្រួតពិនិត្យ និងបង្រ្កាបការដាំដុះ ការផលិត ការនាំចូល ការនាំចេញ ការចែកចាយ ការឆ្លងកាត់ ឬសំចតគ្រឿងញៀន ឱសថដែលមានសារធាតុញៀន និងថ្នាំញៀនស្របច្បាប់កំណត់ដោយក្រសួងសុខាភិបាល ដោយសហការជាមួយ ក្រសួង-ស្ថាប័ន និងអង្គការពាក់ព័ន្ធដទៃទៀត ។

៣. តាមដាន និងអនុវត្តច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន និងសាលក្រមតុលាការដែលពាក់ព័ន្ធនឹងបទល្មើសគ្រឿងញៀន ។

៤. រៀបចំលិខិតបទដ្ឋានសុវត្ថិភាពស្តីពីការវេចខ្ចប់ ការប្រគល់ទទួល ការរក្សាទុក និងការកំទេចចោលគ្រឿងញៀនដែលចាប់បាន ដោយសហការជាមួយក្រសួង-ស្ថាប័ន និងអង្គការពាក់ព័ន្ធដទៃទៀត ។

៥ រៀបចំ និងគ្រប់គ្រងមជ្ឈមណ្ឌលពត៌មានគ្រឿងញៀន ។

៦. សំរបសំរួល និងចូលរួមក្នុងការបង្កើត និងអនុវត្តនូវកម្មវិធីប្រឆាំងនឹងការសំអាតប្រាក់ដែលបានមកពីជំនួញគ្រឿងញៀនខុសច្បាប់ ។

នាយកដ្ឋានអនុវត្តច្បាប់ត្រូវបានដឹកនាំ និងគ្រប់គ្រងដោយប្រធាននាយកដ្ឋានមួយរូប និងមានអនុប្រធានជាជំនួយការ ។

**មាត្រា ១១ :- នាយកដ្ឋាន នីតិកម្ម អប់រំ និងស្តារនីតិសម្បទា មានភារកិច្ចដូចតទៅ ÷**

១. រៀបចំ និងអនុវត្តកម្មវិធីអប់រំបង្ការ ទប់ស្កាត់ និងកាត់បន្ថយការប្រើប៉ពានគ្រឿងញៀននៅក្នុងប្រទេស ដោយសំរបសំរួល និងសហការឱ្យបានល្អជាមួយក្រសួង-ស្ថាប័ន និងអង្គការពាក់ព័ន្ធដទៃទៀត ។

២. រៀបចំ សំរបសំរួល និងអនុវត្តកម្មវិធីសំរាប់ទទួលព្យាបាល ស្តារនីតិសម្បទាអ្នកញៀនគ្រឿងញៀន និងជួយឱ្យពួកគេក្លាយទៅជាពលរដ្ឋល្អរបស់សង្គមដោយសហការជាមួយក្រសួង-ស្ថាប័ន និងអង្គការពាក់ព័ន្ធដទៃទៀត ។

៣. ជំរុញ និងលើកកំពស់ការយល់ដឹងពីបញ្ហាគ្រឿងញៀនដល់សហគមន៍នានា ដើម្បីរួមចំណែកក្នុងការជួយទប់ស្កាត់ការប្រើប៉ពានគ្រឿងញៀន ដោយសហការជាមួយក្រសួង-ស្ថាប័ន និងអង្គការពាក់ព័ន្ធដទៃទៀត។

៤. ជំរុញឱ្យមានការរៀបចំបង្កើតមជ្ឈមណ្ឌលព្យាបាល និងស្តារ នីតិសម្បទាអ្នកញៀនគ្រឿងញៀន ។

៥. ជំរុញការអនុវត្តន៍កម្មវិធីសមាហរណកម្មអ្នកញៀនគ្រឿងញៀនទៅក្នុងសង្គមជាតិវិញ ដោយសហការជាមួយក្រសួង-ស្ថាប័ន និងអង្គការពាក់ព័ន្ធដទៃទៀត ។

៦. អនុវត្តកិច្ចសហប្រតិបត្តិការ និងអន្តរាគមន៍គាំទ្រដល់សកម្មភាពអនុវត្តច្បាប់របស់ភ្នាក់ងារអនុវត្តច្បាប់ដទៃទៀត ស្របតាមនីតិវិធី ។

៧. តាក់តែងសេចក្តីព្រាងច្បាប់ ព្រះរាជក្រឹត្យ អនុក្រឹត្យ និងបទប្បញ្ញត្តិ ក្នុងវិស័យបង្ការនិងបង្ក្រាបការដាំដុះ ការផលិត ការជួញដូរគ្រឿងញៀន ដោយសហការជាមួយក្រសួង-ស្ថាប័ន និងអង្គការពាក់ព័ន្ធដទៃទៀត ។

៨. តាមដានការវិវត្តន៍នីតិក្រមរបស់រដ្ឋ និងលើកសំណើធ្វើវិសោធនកម្មច្បាប់ កែសំរួលព្រះរាជក្រឹត្យ អនុក្រឹត្យ និងបទប្បញ្ញត្តិផ្សេងៗដែលពាក់ព័ន្ធនឹងគ្រឿងញៀន ក្នុងន័យធ្វើអោយដំណើរការនៃការត្រួតពិនិត្យគ្រឿងញៀនកាន់តែមានប្រសិទ្ធភាព។

នាយកដ្ឋាន នីតិកម្ម អប់រំ និងស្តារនីតិសម្បទា ត្រូវបានដឹកនាំ និងគ្រប់គ្រងដោយប្រធាននាយកដ្ឋានមួយរូប និងមានអនុប្រធានជាជំនួយការ ។

**មាត្រា ១២ :- នាយកដ្ឋានស្រាវជ្រាវ និងត្រួតពិនិត្យ មានភារកិច្ចដូចតទៅ ÷**

១. ស្រាវជ្រាវ ក្តាប់សភាពការណ៍ ប្រមូលពត៌មានទូទៅដែលពាក់ព័ន្ធនឹងសារធាតុគីមី និងសារធាតុទាំងឡាយដែលប្រើប្រាស់សំរាប់ផ្សំគ្រឿងញៀន · ព្រមទាំងសារធាតុដែលធ្វើឱ្យប៉ះពាល់ប្រព័ន្ធសរសៃ

ប្រសាទ និងឱសថដែលមានសារធាតុញៀន សំដៅលើកវិធានការគ្រប់គ្រង ត្រួតពិនិត្យ និងទប់ស្កាត់ឱ្យមានប្រសិទ្ធភាព ។

២. សហការ និងចូលរួមក្នុងកិច្ចប្រតិបត្តិការជាមួយក្រសួង និងអង្គភាពពាក់ព័ន្ធដទៃទៀត ក្នុងការតាមដាន និងត្រួតពិនិត្យ សារធាតុដែលធ្វើឱ្យប៉ះពាល់ប្រព័ន្ធសរសៃប្រសាទ និងសារធាតុគីមីសំរាប់ផលិតគ្រឿងញៀន និងឱសថដែលមានសារធាតុញៀន និងថ្នាំញៀនស្របច្បាប់ កំណត់ដោយក្រសួងសុខាភិបាល ។

៣. សហការជាមួយអង្គភាពពាក់ព័ន្ធក្នុងការត្រួតពិនិត្យ តាមដាន និងទប់ស្កាត់ការនាំចេញ នាំចូល ការចរាចរ ការប្រើប្រាស់ ការផលិត ការស្តុកទុកនូវសារធាតុគីមីផ្សំគ្រឿងញៀន និងសារធាតុដែលធ្វើឱ្យប៉ះពាល់ប្រព័ន្ធសរសៃប្រសាទ ។

៤. សហការក្នុងការទប់ស្កាត់ការបង្វែរសារធាតុគីមីផ្សំ ពីជំនួញស្របច្បាប់ ទៅបំរើគោលដៅផលិតគ្រឿងញៀនខុសច្បាប់ ដោយសហការជាមួយក្រសួង-ស្ថាប័នពាក់ព័ន្ធ និងអង្គការដទៃទៀត ។

នាយកដ្ឋានស្រាវជ្រាវ និងត្រួតពិនិត្យត្រូវបានដឹកនាំ និងគ្រប់គ្រងដោយប្រធាននាយកដ្ឋានមួយរូប និងមានអនុប្រធានជាជំនួយការ ។

## ជំពូក ៤
## មន្ទីរពិសោធន៍គ្រឿងញៀន

**មាត្រា ១៣ :-**

មន្ទីរពិសោធន៍គ្រឿងញៀន មានភារកិច្ចដូចតទៅ :

១. ធ្វើវិភាគ ស្រាវជ្រាវ តាមបែបវិទ្យាសាស្ត្រ លើលក្ខណៈគីមី និងលក្ខណៈរូបនៃសារធាតុគ្រឿងញៀន និង គីមីផ្សំ គ្រឿងញៀនដែលបានកំណត់ក្នុងអនុសញ្ញារបស់អង្គការសហប្រជាជាតិ ច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀនកម្ពុជា នៅក្នុងរុក្ខជាតិ សារធាតុគីមី វត្ថុធាតុដែលមាននៅក្នុងសរីរាង្គមនុស្ស ចំណីអាហារ ភេសជ្ជៈ និង ឱសថបុរាណ/សម័យ ។

២. ធ្វើការវិភាគរកគុណភាព បរិមាណសារធាតុញៀន និងគីមីផ្សំគ្រឿងញៀនដែលក្រសួង-ស្ថាប័នមានសមត្ថកិច្ចប្រគល់ជូន និងផ្ដល់ជូននូវលទ្ធផលនៃការវិភាគទាំងនេះវិញ ។

៣. ធ្វើការផលិតសារធាតុប្រតិករសំរាប់ធ្វើតេស្តពណ៌ជំហានដំបូងលើសារធាតុញៀន និងសារធាតុគីមីផ្សំគ្រឿងញៀន ។

៤. ធ្វើការសិក្សាស្រាវជ្រាវរកសារធាតុញៀន ឬ សារធាតុគីមីផ្សំគ្រឿងញៀនថ្មី ឬ សារធាតុពុលផ្សេងទៀត ដែលនាំឱ្យប៉ះពាល់ដល់សុខភាព ដើម្បីដាក់ចូលទៅក្នុងតារាងត្រួតពិនិត្យសារធាតុគ្រឿងញៀននៅក្នុងច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ដោយសហការជាមួយក្រសួងសុខាភិបាល និងមន្ទីរពិសោធន៍ ផ្សេងៗទៀតដែលពាក់ព័ន្ធ ។

៥. ធ្វើការរក្សាទុក វិភាគ និង ប្រៀបធៀបទិន្នន័យ ស្តីពីលក្ខណៈរូប លក្ខណៈគីមី ដើម្បីរកពត៌មានចាំបាច់ដែលពាក់ព័ន្ធសំរាប់បំរើការងារស៊ើបអង្កេត ។

៦. លើកសំណើជូនអគ្គលេខាធិការដ្ឋាននៃអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន ស្តីពីការផលិត និងការធ្វើជំនួញឱសថសម័យ ឱសថបុរាណ គេសជ្ជៈ គ្រឿងស្រវឹង គ្រឿងបរិភោគនៅក្នុងប្រទេស និងថ្នាំស្របច្បាប់កំណត់ដោយក្រសួងសុខាភិបាល ដែលមន្ទីរពិសោធន៍គ្រឿងញៀនស្រាវជ្រាវរកឃើញថា មានសារធាតុគ្រឿងញៀនលើសកំរិតសុវត្ថិភាព ដែលបង្កឱ្យមានគ្រោះថ្នាក់ដល់សុខភាព និងសុវត្ថិភាពសង្គម ដើម្បីធ្វើការហាមឃាត់ ។

មន្ទីរពិសោធន៍គ្រឿងញៀនត្រូវបានដឹកនាំ និងគ្រប់គ្រងដោយប្រធានមន្ទីរពិសោធន៍មួយរូប និងមានអនុប្រធានជាជំនួយការ ។

## ជំពូក ៥
## អវសានប្បញ្ញត្តិ

**មាត្រា ១៤ :-**

រាល់អនុក្រឹត្យ និងសេចក្តីសំរេចពីមុនដែលផ្ទុយនឹងខ្លឹមសារនៃអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា ១៥ :-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង-ស្ថាប័ន និងអង្គភាពដែលពាក់ព័ន្ធនៃរាជរដ្ឋាភិបាល ត្រូវអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀងៗខ្លួន ។

**មាត្រា ១៦ :-**

អនុក្រឹត្យនេះ ចូលជាធរមានចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី[illegible] ឆ្នាំ ២០០៧

នាយករដ្ឋមន្ត្រី

**ហ៊ុន សែន**

បានយកសេចក្តីទៅជំរាបជូន សម្តេចនាយករដ្ឋមន្ត្រី

**ឧបនាយករដ្ឋមន្ត្រី**

**និងជាប្រធានអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន**

**ស ខេង**

**<u>កន្លែងទទួល</u> :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា ១៥
- ឯកសារ-កាលប្បវត្តិ

## រចនាសម្ព័ន្ធរបស់អគ្គលេខាធិការដ្ឋាន
## នៃអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន



**មាត្រា ៥.- ចំណាត់ថ្នាក់គ្រឿងញៀន**

គ្រឿងញៀនត្រូវបានធ្វើចំណាត់ថ្នាក់ដូចខាងក្រោមនេះ :

តារាងទី១ : រុក្ខជាតិនិងសារធាតុដែលបណ្តាលឲ្យមានគ្រោះថ្នាក់ធ្ងន់ធ្ងរ ហើយដែលពុំមានផលប្រយោជន៍ខាងវេជ្ជសាស្ត្រ ។

តារាងទី២ : រុក្ខជាតិ និងសារធាតុដែលបណ្តាលឲ្យមានគ្រោះថ្នាក់ធ្ងន់ធ្ងរ ប៉ុន្តែមានផលប្រយោជន៍ខាងវេជ្ជសាស្ត្រ ។

តារាងទី៣ : រុក្ខជាតិ និងសារធាតុដែលបណ្តាលឲ្យមានគ្រោះថ្នាក់ ប៉ុន្តែមានផលប្រយោជន៍ខាងវេជ្ជសាស្ត្រ។

តារាងទី៤ : សារធាតុគីមីផ្សេងៗទាំងឡាយ ដែលបានចាត់ថ្នាក់ក្នុងអនុសញ្ញារបស់អង្គការសហប្រជាជាតិ ប្រឆាំងនឹងការចរាចរគ្រឿងញៀនខុសច្បាប់ និងសារធាតុដែលធ្វើឲ្យប៉ះពាល់ប្រព័ន្ធសរសៃប្រសាទ ឆ្នាំ១៩៨៨ ឬក្នុងការអនុវត្តអនុសញ្ញានេះប្រឆាំងនឹងការចរាចរគ្រឿងញៀនខុសច្បាប់ ។





តារាងទី ៤ នេះ ត្រូវបានបែងចែកជាតារាងទី ៤ (I) និងតារាងទី៤ (II) ។

តារាងទាំង ៤ ខាងលើនេះ មានចែងលំអិតនៅក្នុងតារាងឧបសម្ព័ន្ធនៃច្បាប់នេះ ។

# តារាងឧបសម្ព័ន្ធ
# ថ្នាំញៀន និងសារធាតុមានឥទ្ធិពលលើប្រព័ន្ធសរសៃប្រសាទ និងសារធាតុសម្រាប់ផលិតគ្រឿងញៀន

List of Narcotic Drugs, Psychotropic Substances, and Substances used for drug manufacturing

**ក្នុងបញ្ជីនេះមាន** :

- សារធាតុខាងក្រោមនេះមានឈ្មោះរួមអន្តរជាតិ ឬឈ្មោះដែលប្រើក្នុងអនុសញ្ញាអន្តរជាតិជាធរមាន
- អ៊ីហ្សូមែរ (isomère) ក្នុងគ្រប់ករណីដែលអាចស្របនឹងរូបមន្តគីមីជាសារវន្តនៃសារធាតុទាំងនោះ លើកលែងតែមានអញ្ញត្រកម្មច្បាស់លាស់
- អេស្ទែរ (esters) និងអេទែរ (éthers) នៃសារធាតុទាំងនោះក្នុងគ្រប់ករណីទាំងអស់ដែលអាចមាន
- អំបិលនៃសារធាតុទាំងនេះ រួមទាំងអំបិលរបស់អេស្ទែរ (esters) អំបិលអេទែរ (ethers) និងអំបិលអ៊ីហ្សូមែរ (isomère) ក្នុងគ្រប់ករណីទាំងអស់ដែលអាចមាន
- ការរៀបចំផ្សំធ្វើសារធាតុទាំងនោះ លើកលែងតែមានអញ្ញត្រកម្មដូចមានចែងក្នុងច្បាប់នេះ
- ការរកឃើញសារធាតុថ្មីដោយក្រុមអ្នកបច្ចេកទេសវិទ្យាសាស្ត្រពាក់ព័ន្ធគ្រឿងញៀននៅព្រះរាជាណាចក្រកម្ពុជា ។

**តារាងទី ១** Table I

| **ភាសាខ្មែរ**<br>Khmer Language | **ភាសាបារាំង**<br>France Language | **ភាសាអង់គ្លេសបែបអាមេរិកាំង**<br>English Language |
|---|---|---|
| អាសេទ័រហ្វីន | ( Acétorphine ) | ( Acetorphine ) |
| កញ្ឆា ជ័រកញ្ឆា ប្រេងកញ្ឆា និងគ្រាប់កញ្ឆា | ( Cannabis, résine de cannabis, huile de cannabis et Grain de cannabis ) | ( Cannabis, cannabis resin, cannabis oil and cannabis seed ) |
| សេតូបេមីដូន | ( Cétobémidone ) | ( Ketobemidone ) |
| ដេហ្សូម័រហ្វីន | ( Désomorphine ) | ( Desomorphine ) |

| | | |
|---|---|---|
| អេទ័រហ្វីន | ( Etorphine ) | ( Etorphin ) |
| ហេរ៉ូអ៊ីន | ( Héroine ) | ( Heroin ) |
| អាសេទីល-អាល់ហ្វា-មេទីលហ្វង់តានីល | ( Acétyl-alpha-méthylfentanyl ) | ( Acelty-alpha-methylfentanyl ) |
| អាល់ហ្វាសេទីលមេតាដុល | ( Alphacétylméthadol ) | ( Alphacetylmethadol ) |
| អាល់ហ្វា-មេទីលហ្វង់តានីល | ( Alpha-méthylfentanyl ) | ( Alpha-methylfentanyl ) |
| បែតា-អ៊ីដ្រុកស៊ីហ្វង់តានីល | ( Bêta-hydroxyfentanyl ) | ( Beta-hydroxyfentanyl ) |
| បែតា-អ៊ីដ្រុកស៊ីមេទីល-៣-ហ្វង់តានីល | ( Bêta-hydroxyméthyl-3-fentanyl ) | ( Beta-hydroxymethyl-3-fentanyl ) |
| មេទីល-៣-ហ្វង់តានីល | ( Méthyl-3-fentanyl ) | ( Methyl-3-fentanyl ) |
| មេទីល-៣-ត្យូហ្វង់តានីល | ( Méthyl-3-thiofentanyl ) | ( Methyl-3-thiofentanyl ) |
| អឹម ប៉េ ប៉េ ប៉េ | ( MPPP ) | ( MPPP ) |
| ប៉ារ៉ា-ហ្លុយអ័រ៉ូហ្វង់តានីល | ( Para-fluorofentanyl ) | ( Para-fluorofentanyl ) |
| ប៉េ អឺ ប៉េ អា ប៉េ | ( PEPAP ) | ( PEPAP ) |
| ត្យូហ្វង់តានីល | ( Thiofentanyl ) | ( Thiofentanyl ) |
| ប្រ៊ោឡាំហ្វេតាមីន | ( Brolamfétamine ) | ( Brolamfetamine ) |
| កាទីណូន | ( Cathinone ) | ( Cathinone ) |
| ដេ អឺ តេ | ( DET ) | ( DET ) |
| ដេ អឹម អា | ( DMA ) | ( DMA ) |
| ដេ អឹម ហាស់ ប៉េ | ( DMHP ) | ( DMHP ) |
| ដេ អឹម តេ | ( DMT ) | ( DMT ) |
| ដេ អូ អឺ តេ | ( DOET ) | ( DOET ) |
| អេទីស៊ីក្លីឌីន | ( Eticyclidine ) | ( Eticyclidine ) |
| លីហ្សែហ្សីដ | ( Lysergide ) | ( Lysergide ) |
| អឹម ដេ អឹម អា | ( MDMA ) | ( MDMA ) |
| មេស្កាលីន | ( Mescaline ) | ( Mescaline ) |

| | | |
|---|---|---|
| មេទីល-៤-អាមីណូរិច | ( Méthyl-4-aminorex ) | ( 4-Methylaminorex ) |
| អឹម អឹម ដេ អា | ( MMDA ) | ( MMDA ) |
| អិន-អេទីល អឹម ដេ អា | ( N-éthyl MDA ) | ( N-Ethyl-MDA ) |
| អិន-អ៊ីដ្រុកស៊ី អឹម ដេ អា | ( N-hydroxy MDA ) | ( N-Hydroxy-MDA ) |
| ប៉ារ៉ាអ៊ិចហ្ស៊ីល | ( Parahexyl ) | ( Parahexyl ) |
| ប៉េ អឹម អា | ( PMA ) | ( PMA ) |
| ផ្ស៊ីឡូស៊ីន,ផ្ស៊ីឡូស៊ីន | ( Psilocine, Psilotsine ) | ( Psilocine, Psilotsin ) |
| ផ្ស៊ីឡូស៊ីប៊ីន | ( Psilocybine ) | ( Psilocybine ) |
| រ៉ូលីស៊ីគ្លីឌីន | ( Rolicyclidine ) | ( Rolicyclidine ) |
| អេស តេ ប៉េ | ( STP ) | ( STP ) |
| ដេ អូ អឹម | ( DOM ) | ( DOM ) |
| តេណាំហ្វេតាមីន | ( Ténamfétamine ) | ( Tenamfetamine ) |
| តេណូស៊ីគ្លីឌីន | ( Ténocyclidine ) | ( Tenocyclidine ) |
| តេត្រាអ៊ីដ្រូកានណាប៊ីណុល | ( Tétrahydrocannabinol ) | ( Tetrahydrocannabinol ) |
| តេ អឹម អា | ( TMA ) | ( TMA ) |
| ៤-អឹម តេ អា | ( 4-MTA) | ( 4-MTA) |

**តារាងទី ២** Table II

| ភាសាខ្មែរ Khmer Language | ភាសាបារាំង France Language | ភាសាអង់គ្លេសបែបអាមេរិកកាំង English Language |
|---|---|---|
| អាសេទីលឌីអ៊ីដ្រូកូដេអ៊ីន | ( Acétyldihydrocodéine ) | ( Acetyldihydrocodeine ) |
| អាសេទីលមេតាដុល | ( Acétylméthadol ) | ( Acetylmethadol ) |
| អាល់ហ្វង់តានីល | ( Alfentanil ) | ( Alfentanil ) |
| អាល់លីប្រ៉ូឌីន | ( Allylprodine ) | ( Allylprodine ) |
| អាល់ហ្វាមេប្រ៉ូឌីន | ( Alphaméprodine ) | ( Alphameprodine ) |

| | | |
|---|---|---|
| អាល់ហ្វាមេតាដុល | ( Alphaméthadol ) | ( Alphamethadol ) |
| អាល់ហ្វា-មេទីលត្យូហ្វង់តានីល | ( Alpha-méthylthiofentanyl ) | ( Alpha-methylthiofentanyl ) |
| អាល់ហ្វាប្រ៉ូឌីន | ( Alphaprodine ) | ( Alphaprodine ) |
| អានីឡេរីឌីន | ( Aniléridine ) | ( Anileridine ) |
| បង់ហ្សេទីឌីន | ( Benzéthidine ) | ( Benzethidine ) |
| បង់ហ្ស៊ីលម័រហ្វីន | ( Benzylmorphine ) | ( Benzylmorphine ) |
| បេតាសេទីលមេតាដុល | ( Bétacétylméthadol ) | ( Betacetylmethadol ) |
| បេតាមេប្រ៉ូឌីន | ( Bétaméprodine ) | ( Betameprodine ) |
| បេតាមេតាដូន | ( Bétaméthadone ) | ( Betamethadone ) |
| បេតាប្រ៉ូឌីន | ( Bétaprodine ) | ( Betaprodine ) |
| បេហ្ស៊ីត្រាមីដ | ( Bézitramide ) | ( Bezitramide ) |
| ប៊ុយទីរ៉ាត ដឺ ឌីអុកសាហ្វេទីល | ( Butyrate de dioxaphétyl ) | ( Dioxaphetyl butyrate ) |
| ក្លូនីតាហ្ស៊ែន | ( Clonitazène ) | ( Clonitazene ) |
| ស្លឹកកូកា | ( [ feuille de Coca ] ) | ( Coca leaf) |
| កូកាអ៊ីន | ( Cocaïne ) | ( Cocaine ) |
| កូដេអ៊ីន | ( Codéine ) | ( Codeine ) |
| កូដុកស៊ីម | ( Codoxime ) | ( Codoxime ) |
| ទឹកកំហាប់ដើមអាភៀន (ក្រួជាតិអាភៀនក្រៀម) | ( Concentré de paille de pavot ) | ( Concentrate of poppy straw ) |
| ដិចស្ត្រូម៉ូរ៉ាមីដ | ( Dextromoramide ) | ( Dextromoramide ) |
| ដិចស្ត្រូប្រ៉ូប៉ុកស៊ីហ្វែន | ( Dextropropoxyphène ) | ( Dextropropoxyphene ) |
| ឌីអំប្រ៉ូមីដ | ( Diampromide ) | ( Diampromide ) |
| ឌីអេទីលទីត្យាំប៊ុយតែន | ( Diéthylthiambutène ) | ( Diethylthiambutene ) |
| ឌីហ្វេណុកស៊ីន | ( Difénoxine ) | ( Difenoxin ) |
| ឌីអ៊ីដ្រូកូដេអ៊ីន | ( Dihydrocodéine ) | ( Dihydrocodeine ) |
| ឌីអ៊ីដ្រូម័រហ្វីន | ( Dihydromorphine ) | ( Dihydromorphine ) |

| | | |
|---|---|---|
| ឌីមេណុកសាដុល | ( Diménoxadol ) | ( Dimenoxadol ) |
| ឌីមេហ្វេបតានណុល | ( Dimépheptannol ) | (Dimepheptannol ) |
| ឌីមេទីលទីត្យាំប៊ុយតែន | ( Diméthylthiambutène ) | ( Dimethylthiambutene ) |
| ឌីហ្វេណុកស៊ីឡាត | ( Diphénoxylate ) | ( Diphenoxylate ) |
| ឌីពីប៉ាណូន | ( Dipipanone ) | ( Dipipanone ) |
| ដ្រូតេបាណុល | ( Drotébanol ) | ( Drotebanol ) |
| អិកហ្គូនីន, ជាតុក្លាយពីអេស្ទែរ របស់វា | ( Ecgonine, ses esthers dérivés ) | ( Ecgonine, and it derivative of esters ) |
| អេទីលមេទីលត្យាំប៊ុយតែន | (Ethylméthylthiambutène) | (Ethylmethylthiambutene) |
| អេទីលម័រហ្វីន | ( Ethylmorphine ) | ( Ethylmorphine ) |
| អេតូនីតាហ្សែន | ( Etonitazène ) | ( Etonitazene ) |
| អេតូហ្សេរីឌីន | ( Etozéridine ) | ( Etozeridine ) |
| ហ្វង់តានីល | ( Fentanyl ) | ( Fentanyl ) |
| ហ្វុយរ៉េទីឌីន | ( Furéthidine ) | ( Furethidine ) |
| អ៊ីដ្រូកូដូន | ( Hydrocodone ) | ( Hydrocodone ) |
| អ៊ីដ្រូម័រហ្វីណុល | ( Hydromorphinol ) | ( Hydromorphinol ) |
| អ៊ីដ្រូម័រហ្វូន | ( Hydromorphone ) | ( Hydromorphone ) |
| អ៊ីដ្រុកស៊ីប៉េទីឌីន | ( Hydroxypéthidine ) | ( Hydroxypethidine ) |
| អ៊ីហ្សូមេតាដូន | ( Isométhadone ) | ( Isomethadone ) |
| ឡេវ៉ូមេទ័រហ្វាន | ( Lévométhorphane ) | ( Levomethorphane ) |
| ឡេវ៉ូម៉ូរ៉ាមីដ | ( Lévomoramide ) | ( Levomoramide ) |
| ឡេវ៉ូហ្វេណាស៊ីលម័រហ្វាន | (Lévophénacylmorphane) | (Levophenacylmorphane) |
| ឡេវ័រហ្វាណុល | ( Lévorphanol ) | ( Levorphanol ) |
| មេតាហ្សូស៊ីន | ( Métazocine ) | (Metazocine ) |
| មេតាដូន | ( Méthadone ) | ( Methadone ) |
| (មេតាដូន, [illegible] [ឌីយ៉ាណូ-៤ ឌីមេទីឡាមីណូ-២ ឌីហ្វេនីល-៤, ៤ប៊ុយតាន] ) | | |

| | | |
|---|---|---|
| (Méthadone, intermédiaire de la [ cyano-4 diméthylamino-2 diphény1-4,4 butane ] )<br>(Methadone, intermediate [4-cyano-2-dimethylamino-4,4-diphenylbutane ] ) | | |
| មេទីលដេហ្ស័រហ្វីន | ( Méthyldésorphine ) | ( Methyldesorphine ) |
| មេទីលឌីអ៊ីដ្រូម័រហ្វីន | ( Méthyldihydromorphine ) | ( Methyldihydromorphine ) |
| មេតូប៉ុង | ( Métopon ) | ( Metopon ) |
| ម៉ូរ៉ាមីដ | ( Moramide ) | ( Moramide ) |
| ម័រហ្វេរីឌីន | ( Morphéridine ) | ( Morpheridine ) |
| ម័រហ្វីន | ( Morphine ) | ( Morphine ) |
| ម័រហ្វីននមេតូប្រោមីដ និងជាតុក្លាយពីម័រហ្វីនឯទៀតដែលមាន អាហ្សូត ប៉ង់តាវ៉ាឡង់<br>( Morphine méthobromide et autres dérivés morphiniques à azote pentavalent )<br>(Morphine methobromide and others derivative of morphine azotes pentavalent) | | |
| មីរ៉ូហ្វីន | ( Myrophine ) | ( Myrophine ) |
| នីកូកូឌីន | ( Nicocodine ) | ( Nicocodine ) |
| នីកូឌីកូឌីន | ( Nicodicodine ) | ( Nicodicodine ) |
| នីកូម័រហ្វីន | ( Nicomorphine ) | ( Nicomorphine ) |
| ណូរ៉ាស៊ីមេតាដុល | ( Noracyméthadol ) | ( Noracymethadol ) |
| ន័រកូដេអ៊ីន | ( Norcodéine ) | ( Norcodeine ) |
| ន័រឡេវ័រហ្វាណុល | ( Norlévorphanol ) | ( Norlevorphanol ) |
| ន័រមេតាដូន | ( Norméthadone ) | ( Normethadone ) |
| ន័រម័រហ្វីន | ( Normorphine ) | ( Normorphine ) |
| ន័រពីប៉ាណូន | ( Norpipanone ) | ( Norpipanone ) |
| អិន-អុកស៊ីម័រហ្វីន | ( N-oxymorphine ) | ( N-Oxymorphine ) |
| អាភៀន | ( Opium ) | ( Opium ) |
| អុកស៊ីកូដូន | ( Oxycodone ) | ( Oxycodone ) |
| អុកស៊ីម័រហ្វូន | ( Oxymorphone ) | ( Oxymorphone ) |
| ប៉េទីឌីន | ( Péthidine ) | ( Pethidine ) |
| (ប៉េទីឌីន, [illegible] ស៊ីយ៉ាណូ-៤ មេទីល-១ ហ្វេនីល-៤ ពីប៉េរីឌីន ]) | | |

( Péthidine intermédiaire A de la [ cyano-4 méthyi-1 phényl-4 piperidine ] )
( Pethidine, intermediaite A [4-Cyano-1-methyl-4-phenylpiperidine ] )

( ប៉េទីឌីន, អាំងទែរមេដ្យែ បេ ដឺឡា [ អេស្ទែរអេទីលិក ដឺឡាស៊ីតហ្វេនីល-៤ ពីប៉េរីឌីនកាបុកស៊ីលិក-៤] )
( Péthidine, intermédiaire B de la [ ester éthylique de l'acide phényl-4 pipéridine carboxylique-4 ] )
( Pethidine, intermediate B [4-phenylpiperidine-4-carboxylic acid ethyl ester ] )

( ប៉េទីឌីន, អាំងទែរមេដ្យែ សេ ដឺឡា [អាស៊ីដមេទីល-១ ហ្វេនីល-៤ ពីប៉េរីឌីន កាបុកស៊ីលិក-៤] )
( Péthidine, intermédiaire C de la [ acide méthyl-1 phényl-4 pipéridine carboxylique-4] )
( Pethidine, intermediate C [1-methyl-4-phenylpiperidine-4-carboxylic acid] )

| | | |
|---|---|---|
| ហ្វេណាំប្រ៉ូមីដ | ( Phénampromide ) | ( Phenampromide ) |
| ហ្វេណាដុកសូន | ( Phénadoxone ) | ( Phenadoxone ) |
| ហ្វេណាហ្សូស៊ីន | ( Phénazocine ) | ( Phenazocine ) |
| ហ្វេណូប៉េរីឌីន | ( Phénopéridine ) | ( Phenoperidine ) |
| ហ្វូលកូឌីន | ( Pholcodine ) | ( Pholcodine ) |
| ពីមីណូឌីន | ( Piminodine ) | ( Piminodine ) |
| ពីរីត្រាមីដ | ( Piritramide ) | ( Piritramide ) |
| ប្រ៉ូអឹបតាហ្ស៊ីន | ( Proheptazine ) | ( Proheptazine ) |
| ប្រ៉ូប៉េរីឌីន | ( Propéridine ) | ( Properidine ) |
| ប្រ៉ូពីរ៉ាម | ( Propiram ) | ( Propiram ) |
| រ៉ាសេមេទ័រហ្វាន | ( Racéméthorphane ) | ( Racemethorphane ) |
| រ៉ាសេម័ររ៉ាមីដ | ( Racémoramide ) | ( Racemoramide ) |
| រ៉ាសេម័រហ្វាន | ( Racémorphane ) | ( Racemorphane ) |
| ស៊ុយហ្វង់តានីល | ( Sufentanil ) | ( Sufentanil ) |
| តេបាកូន | ( Thébacone ) | ( Thebacone) |
| តេបាអ៊ីន | ( Thébaïne ) | ( Thebaine ) |
| ទីលីឌីន | ( Tilidine ) | ( Tilidine ) |
| ទ្រីមេប៉េរីឌីន | ( Triméperidine ) | ( Trimeperidine ) |
| អំហ្វេតាមីន | ( Amfétamine ) | ( Amfetamine ) |
| ដិចហ្សំហ្វេតាមីន | ( Dexamfétamine ) | ( Dexamfetamine ) |
| ហ្វេណេទីលលីន | ( Fénétylline ) | ( Fenetylline ) |
| ឡេវ៉ហ្វេតាមីន | ( Lévamfétamine ) | ( Levamfetamine ) |



www.law-society.asia 

| | | |
|---|---|---|
| មេក្លកកីឡូន | ( Mécloquelone ) | ( Mecloquelone ) |
| មេតំហ្វេតាមីន | ( Métamfétamine ) | ( Metamfetamine ) |
| មេតាកាឡូន | ( Méthaqualone ) | ( Methaqualone ) |
| មេទីលហ្វេនីដាត | ( Méthylphénidate ) | ( Methylphenidate ) |
| ហ្វេងស៊ីក្លីឌីន | ( Phencyclidine ) | ( Phencyclidine ) |
| ហ្វេងមេត្រាហ្ស៊ីន | ( Phenmétrazine ) | ( Phenmetrazine ) |
| រ៉ាសេម៉ាត ដឺ មេតំហ្វេតាមីន | ( Racémate de Métamfétamine ) | ( Metamfetamine Racemate ) |
| សេកូបារប៊ីតាល់ | ( Sécobarbital ) | ( Secobarbital ) |
| ២ សេ-បេ | ( 2-CB ) | ( 2 C-B ) |

**តារាងទី ៣ Table III**

| **ភាសាខ្មែរ**<br>Khmer Language | **ភាសាបារាំង**<br>France Language | **ភាសាអង់គ្លេសបែប អាមេរិកកាំង**<br>English Language |
|---|---|---|
| អាម៉ូបារប៊ីតាល់ | ( Amobarbital ) | ( Amobarbital ) |
| ប៊ុយប្រេន័រហ្វីន | ( Buprénorphine ) | ( Buprenorphine ) |
| ប៊ុយតាល់ប៊ីតាល់ | ( Butalbital ) | ( Butalbital ) |
| កាទីន | ( Cathine ) | ( Cathine ) |
| ស៊ីក្លូបារប៊ីតាល់ | ( Cyclobarbital ) | ( Cyclobarbital ) |
| គ្លុយតេទីមីដ | ( Glutéthimide ) | ( Glutethimide ) |
| ប៉ង់តាហ្សូស៊ីន | ( Pentazocine ) | ( Pentazocine ) |
| ប៉ង់តូបារប៊ីតាល់ | ( Pentobarbital ) | ( Pentobarbital ) |
| អាល់ឡូបារប៊ីតាល់ | ( Allobarbital ) | ( Allobarbital ) |
| អាល់ប្រ៉ាហ្សូឡាំ | ( Alprazolam ) | ( Alprazolam ) |
| អំហ្វេប្រ៉ាម៉ូន | ( Amfépramone ) | ( Amfepramone ) |
| បារប៊ីតាល់ | ( Barbital ) | ( Barbital ) |

ROYAUME DU CAMBODGE • LE MINISTRE DU PALAIS ROYAL

| | | |
|---|---|---|
